សម្ព័ន្ធខ្មែរជំរឿន
និងការពារសិទ្ធិមនុស្ស
លីកាដូ

LICADHO

Cambodian League for the Promotion and Defense of Human Rights



# បច្ចុប្បន្នភាពស្ថានភាព៖

## ការបៀតបៀនតាមប្រព័ន្ធផ្សព្វផ្សាយសង្គម នៅកម្ពុជា

របាយការណ៍ចេញផ្សាយ

ខែវិច្ឆិកា ឆ្នាំ២០២១

# បច្ចុប្បន្នភាពស្ថានភាព៖

## ការបៀតបៀនតាមប្រព័ន្ធផ្សព្វផ្សាយសង្គម នៅកម្ពុជា

របាយការណ៍ចេញផ្សាយ ខែវិច្ឆិកា ឆ្នាំ២០២១


**សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ**

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS


ស្នាដៃសិល្បៈដោយ Penkuro

# សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស
# (លីកាដូ)

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩២ អង្គការនេះ គឺជាអង្គការដែលស្ថិតនៅជួរមុខគេ ក្នុងកិច្ចការពារសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច និងសិទ្ធិសង្គមរបស់ប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា និងលើកកម្ពស់ការគោរពសិទ្ធិទាំងនេះពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា និងអង្គការនានា។ ដោយបានកសាងនូវ សមិទ្ធិផលល្អក្នុងអតីតកាល លីកាដូ បានបន្តដើរតួនាទីជាអ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋ និងធ្វើការឃ្លាំមើលស្ថានភាពសង្គមតាមរយៈកម្មវិធីឃ្លាំមើល និងការពារសិទ្ធិមនុស្ស ពីការិយាល័យកណ្តាលរបស់ខ្លួននៅរាជធានីភ្នំពេញ និងនៅតាមសាខាទាំង ១២ ខេត្តផ្សេងទៀត។

## កម្មវិធីឃ្លាំមើល និង**ការពារសិទ្ធិមនុស្ស**

### ឃ្លាំមើលការរំលោភសិទ្ធិមនុស្ស សិទ្ធិស្ត្រី និងសិទ្ធិកុមារ

បុគ្គលិកអង្គការលីកាដូ ធ្វើការឃ្លាំមើល និងស្រាវជ្រាវលើករណីរំលោភសិទ្ធិមនុស្ស ករណីរំលោភបំពានលើស្ត្រី និងកុមារ ហើយជនរងគ្រោះ ត្រូវបានផ្តល់សេវាជួយជ្រោមជ្រែង តាមរយៈការធ្វើអន្តរាគមន៍ជាមួយអាជ្ញាធរមូលដ្ឋាន និងមន្ត្រីតុលាការ។

### ជំនួយផ្នែកសេវាសុខភាព និងសេវាកម្មសង្គមកិច្ច

ក្រុមគ្រូពេទ្យផ្តល់សេវាសុខភាពដល់ជនជាប់ឃុំ និងមន្ត្រីពន្ធនាគារនៅជនបទ និងទីក្រុង ជនរងគ្រោះពីការរំលោភសិទ្ធិមនុស្ស និងគ្រួសារ ដែលស្ថិតនៅតំបន់តាំងទីលំនៅថ្មី។ ក្រុមការងារសេវាសង្គមធ្វើការវាយតម្លៃពីតម្រូវការរបស់ជនរងគ្រោះ និងក្រុមគ្រួសារ របស់អ្នកទាំងនោះ ហើយផ្តល់ជំនួយ សម្ភារៈ និងម្ហូបអាហារ រយៈពេលខ្លី។

### ការប្រឹក្សាផ្នែកច្បាប់ដល់ជនជាប់ឃុំ

អ្នកប្រឹក្សាផ្នែកច្បាប់ ផ្តល់ការប្រឹក្សាដល់ជនជាប់ឃុំនៅពន្ធនាគារនៅជនបទ និងទីក្រុង ដើម្បីធ្វើឲ្យប្រាកដថា ជនជាប់ឃុំទាំងនោះមានតំណាង ផ្នែកច្បាប់ នៅគ្រប់ដំណាក់កាលនៃនីតិវិធីដែលពាក់ព័ន្ធ។

### ការពិគ្រោះយោបល់ផ្នែកច្បាប់

ជនរងគ្រោះ ត្រូវបានផ្តល់ជូននូវការពិគ្រោះយោបល់ផ្នែកច្បាប់ ហើយចំពោះ ករណីសំខាន់ៗទទួលបាននូវកិច្ចការពារផ្នែកច្បាប់ ដែលផ្តល់ជូន ដោយក្រុមប្រឹក្សាផ្នែកច្បាប់ និងក្រុមមេធាវីការពារសិទ្ធិមនុស្ស។

## **កម្មវិធីលើកកម្ពស់ និង**ការទាក់ទាញមតិគាំទ្រ

### គាំទ្រសហជីព ក្រុមពលរដ្ឋមូលដ្ឋាន និង បណ្តាញនានា

ជួយដល់សហជីព ក្រុមពលរដ្ឋមូលដ្ឋាន និងសហគមន៍ ដែលរងគ្រោះ ដោយផ្តល់នូវកិច្ចការពារសេវាកម្មផ្នែកច្បាប់ និង

សេវាសុខភាព ព្រមទាំងជួយពង្រឹងសមត្ថភាពរបស់អ្នកទាំងនោះក្នុងការតស៊ូមតិ។

### ទាក់ទាញមតិគាំទ្រជាសាធារណៈ និងតាមសហគមន៍

ករណីរំលោភសិទ្ធិមនុស្ស ដែលអង្គការលីកាដូបានឃ្លាំមើល និងស្រាវជ្រាវ ត្រូវបានចងក្រងទុកនៅក្នុងប្រព័ន្ធផ្ទុកទិន្នន័យ ដើម្បីឲ្យមានភាពងាយស្រួលក្នុងការស្វែងរកព័ត៌មាន វិភាគ ផលិត ជារបាយការណ៍ (ការបោះពុម្ពជារបាយការណ៍ និងរបាយការណ៍សោតទស្សន៍) និងសម្រាប់ធ្វើការតស៊ូមតិផ្សេងៗទៀត។


**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**

លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក ប្រធានអង្គការសិទ្ធិមនុស្ស លីកាដូ
ផ្ទះលេខ ១៦ ផ្លូវ៩៩ រាជធានីភ្នំពេញ កម្ពុជា
ទូរសព្ទលេខ៖ (+៨៥៥)២៣ ៧២៧ ១០២/២១៦ ៦០២

អ៊ីម៉ែល៖ contact@licadho-cambodia.org
គេហទំព័រ៖ www.licadho-cambodia.org Facebook: www.facebook.com/licadho Twitter: www.twitter.com/licadho

# មាតិកា




និយមន័យ ទំព័រ១

ការរកឃើញសំខាន់ៗ ទំព័រ២

សេចក្តីផ្តើម ទំព័រ៥

តើអ្វីទៅជាការបៀតបៀនតាមប្រព័ន្ធអនឡាញ? ៦

ការបៀតបៀនតាមប្រព័ន្ធអនឡាញ និង សិទ្ធិមនុស្ស ទំព័រ៧

វិធីសាស្ត្រ ទំព័រ៨

នរណាខ្លះបានចូលរួមស្ទង់មតិ? ៩

ការរកឃើញ ទំព័រ១១

ទំនួលខុសត្រូវរបស់ក្រុមហ៊ុនប្រព័ន្ធផ្សព្វផ្សាយសង្គម និងអាជ្ញាធរកម្ពុជា ទំព័រ៤១

សេចក្តីសន្និដ្ឋាន ទំព័រ៤៤

អនុសាសន៍ ទំព័រ៤៥

អនុសាសន៍ទៅកាន់ក្រុមហ៊ុនប្រព័ន្ធផ្សព្វផ្សាយសង្គម ៤៥

អនុសាសន៍ទៅកាន់អាជ្ញាធរកម្ពុជា ៤៥

ឧបសម្ព័ន្ធទី ១៖ ការបែងចែកប្រភេទនៃការបៀតបៀនតាមប្រព័ន្ធអនឡាញ ដែលត្រូវបានរាយការណ៍ដោយអ្នកចូលរួមស្ទង់មតិ ទំព័រ៤៧




# និយមន័យ

**សកម្មជន៖** អ្នកការពារសិទ្ធិមនុស្ស សកម្មជនបរិស្ថាន សកម្មជននយោបាយ សកម្មជនដីធ្លី អ្នកដឹកនាំក្នុងសង្គមស៊ីវិល និង/ឬអ្នកដឹកនាំសហជីព ។

**ការទម្លាយព័ត៌មានឯកជន៖** ការលួចចែកចាយព័ត៌មានឯកជនរបស់នរណាម្នាក់ដូចជា លេខទូរស័ព្ទ អាសយដ្ឋាន ឬព័ត៌មានលម្អិតនៃអត្តសញ្ញាណ ដោយគ្មានការអនុញ្ញាត ។

**កម្មវិធីដែលជាកម្មសិទ្ធិរបស់ក្រុមហ៊ុនហ្វេសប៊ុក៖** ហ្វេសប៊ុក (Facebook) ឆាត (Messenger) អ៊ីនស្តាក្រាម (Instagram) និងវតសន៍អាប់(WhatsApp) ។ ថ្មីៗនេះ ក្រុមហ៊ុននេះបានប្រកាសឈ្មោះថ្មីមួយ ដោយផ្លាស់ប្តូរឈ្មោះក្រុមហ៊ុនពី "ហ្វេសប៊ុក" ទៅ "មេតា" ។

**យេនឌ័រ៖** តួនាទី អាកប្បកិរិយា សកម្មភាព និងបុគ្គលិកលក្ខណៈដែលត្រូវបានកំណត់នៅក្នុងសង្គមថា សមស្របសម្រាប់ ស្ត្រី ក្មេងស្រី បុរស និងក្មេងប្រុស ។

**ការបង្ហាញយេនឌ័រ៖** របៀបដែលមនុស្សម្នាក់បង្ហាញយេនឌ័រតាមរយៈរូបរាងខាងក្រៅរបស់ពួកគេ នៅក្នុងបរិបទនៃការកំណត់យេនឌ័រក្នុងសង្គម ។ នេះអាចរាប់បញ្ចូលអាកប្បកិរិយា និងរូបរាងខាងក្រៅដូចជា ការស្លៀកពាក់ សក់ ការតុបតែងខ្លួន ភាសាកាយវិការ សំឡេង ឈ្មោះ និងការហៅគ្នា ។

**អត្តសញ្ញាណយេនឌ័រ៖** អារម្មណ៍ជ្រាលជ្រៅ ឬញាណជាប់មកពីកំណើតនៃយេនឌ័ររបស់មនុស្សម្នាក់ ដែលបង្ហាញថាពួកគេជាភេទប្រុស ភេទស្រី ឬអ្វីផ្សេងទៀត ដោយអាចដូចគ្នា ឬខុសគ្នានឹងភេទពីកំណើតរបស់ពួកគេ ។

**អ្នកស្រឡាញ់ភេទដូចគ្នា៖** ស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្តូរភេទ និងអ្នកដែលមិនកំណត់អត្តសញ្ញាណយេនឌ័រផ្សេងទៀត ។

**ការបៀតបៀនតាមប្រព័ន្ធអនឡាញ៖** រាល់សកម្មភាពទាំងឡាយណាដែលស្តែងចេញ ឬអាចនាំឱ្យមាន ការប៉ះពាល់ឬការរងគ្រោះផ្នែករូបរាងកាយ ផ្លូវភេទ ផ្លូវចិត្ត ឬផ្នែកសង្គម ដែលត្រូវបានប្រព្រឹត្តជំរុញ ឬធ្វើឱ្យកាន់តែធ្ងន់ធ្ងរបន្ថែមទៀត ដោយការប្រើប្រាស់បច្ចេកវិទ្យាទំនាក់ទំនងព័ត៌មាន ដូចជាប្រព័ន្ធផ្សព្វផ្សាយសង្គម ទូរស័ព្ទចល័ត និងទូរស័ព្ទឆ្លាតវៃ ឬការប្រើប្រាស់អ៊ីនធឺណិតបែបទូលំទូលាយផ្សេងទៀត ។

**ប្រព័ន្ធផ្សព្វផ្សាយសង្គម៖** រាល់គេហទំព័រ កម្មវិធី ឬវេទិកាតាមប្រព័ន្ធអនឡាញ ដែលមានធាតុអន្តរបុគ្គល រួមមានកម្មវិធីប្រព័ន្ធផ្សព្វផ្សាយសង្គមតាមបែបប្រពៃណី កម្មវិធីផ្ញើសារ ឬហៅជាវីដេអូ កម្មវិធីល្បែងកម្សាន្ត កម្មវិធីណាត់ជួប កម្មវិធីប្រជុំឬពិភាក្សា និងកម្មវិធីជាច្រើនទៀត ។

**យុវជន៖** មនុស្សដែលមានអាយុចន្លោះពី ១៨ឆ្នាំ ទៅ ២៤ឆ្នាំ ។

[១] និយមន័យនេះត្រូវបានប្រើប្រាស់ក្នុងរបាយការណ៍នេះ ដោយផ្អែកលើនិន្នាការភេទ ក៏ដូចជាការបង្ហាញ និងអត្តសញ្ញាណយេនឌ័រ ដែលត្រូវបានរាយការណ៍ដោយអ្នកចូលរួមស្ទង់មតិ ។




ភាគរយនៃអ្នកចូលរួមស្ទង់មតិដែលធ្លាប់ជួបបទពិសោធន៍នៃការបៀតបៀនតាមប្រព័ន្ធអនឡាញ




ក្នុងចំណោមអ្នកចូលរួមស្ទង់មតិ ដែលធ្លាប់ជួបបទពិសោធន៍នៃការបៀតបៀនតាមប្រព័ន្ធអនឡាញ ដោយគិតពីភាគរយនៃអ្នកដែលត្រូវបានបៀតបៀនតាមរយៈកម្មវិធីយ៉ាងតិចមួយរបស់ក្រុមហ៊ុនហ្វេសប៊ុក




ភាគរយនៃអ្នកចូលរួមស្ទង់មតិដែលធ្លាប់បានឃើញនរណាម្នាក់ជួបការបៀតបៀនតាមប្រព័ន្ធអនឡាញ

សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ បានស្ទង់មតិជាមួយមនុស្សជាង ៧០០នាក់ ព្រមទាំងបាន សម្ភាសបែបស៊ីជម្រៅជាមួយមនុស្សចំនួន ១២នាក់ ដើម្បីសិក្សាអំពីការបៀតបៀនតាមប្រព័ន្ធអនឡាញ ។ នេះគឺជាអ្វីដែលយើងបានរកឃើញ៖

**ប្រព័ន្ធផ្សព្វផ្សាយសង្គមគឺមានសារៈសំខាន់សម្រាប់ជីវិតរស់នៅរបស់មនុស្ស ។** ស្ទើរតែគ្រប់អ្នកឆ្លើយតបទាំងអស់នៅក្នុងការស្ទង់មតិបានរាយការណ៍ថា ពួកគេប្រើប្រាស់ជាទៀងទាត់ជាមួយកម្មវិធីហ្វេសប៊ុក (៩៧%) កម្មវិធីឆាត (៨៤%) និងកម្មវិធីថេលេក្រាម ឬTelegram (៨៣%) ។ ភាគច្រើនពួកគេប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមដើម្បីទទួលបានព័ត៌មាន និងអានព័ត៌មាន រក្សាទំនាក់ទំនងជាមួយអ្នកផ្សេងទៀត ក៏ដូចជាដើម្បីធ្វើការងារ ឬការសិក្សា ។ ៣៦% នៃអ្នកឆ្លើយតប ប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម ដើម្បីបញ្ចេញមតិអំពីអ្វីដែលមានសារៈសំខាន់សម្រាប់ពួកគេ ដោយបុរសទំនងជាបញ្ចេញមតិច្រើនជាងស្ត្រី ។

**ការបៀតបៀនតាមប្រព័ន្ធអនឡាញកើតមានញឹកញាប់៖** ៣៨% នៃមនុស្សដែលបានចូលរួមស្ទង់មតិ បានជួបបទពិសោធន៍នៃការបៀតបៀនតាមប្រព័ន្ធអនឡាញ ។ ក្រុមអ្នកស្រឡាញ់ភេទដូចគ្នា សកម្មជន និងយុវជនបានរាយការណ៍ពីអត្រានៃការបៀតបៀនតាមប្រព័ន្ធអនឡាញច្រើនជាងគេ ។ ខណៈដែលស្ត្រី និងបុរស បានរាយការណ៍ពីការបៀតបៀនតាមប្រព័ន្ធអនឡាញក្នុងអត្រាស្មើគ្នា ប៉ុន្តែប្រភេទ និងផលប៉ះពាល់នៃការបៀតបៀនជារឿយៗ គឺមានលក្ខណៈខុសគ្នា ។ លើសពីនេះ ៥៤% នៃអ្នកឆ្លើយតបបានឃើញមនុស្សផ្សេងទៀត ធ្លាប់ទទួលរងការបៀតបៀនតាមប្រព័ន្ធអនឡាញ ហើយភាគច្រើនអ្នកទាំងនោះគឺជាស្ត្រី ។

**ការបៀតបៀនផ្លូវភេទ គឺជាប្រភេទនៃការបៀតបៀនតាមប្រព័ន្ធអនឡាញដែលត្រូវបានរាយការណ៍ច្រើនជាងគេ ។** ២០% នៃស្ត្រីដែលបានរាយការណ៍ពីការទទួលបានសារជាអក្សរ រូបភាព វីដេអូ ឬសំណើបែបផ្លូវភេទដែលពួកគេពុំបានស្នើសុំ ។ តួលេខនេះកើនដល់ ២៤% សម្រាប់ស្ត្រីដែលមានអាយុចន្លោះពី ១៨ឆ្នាំ ដល់ ២៤ឆ្នាំ និងកាន់តែខ្ពស់ថែមទៀតសម្រាប់ក្រុមអ្នកស្រឡាញ់ភេទដូចគ្នា ។ ប្រភេទនៃការបៀតបៀនដែលកើតមានញឹកញាប់ជាងគេផ្សេងទៀតមានដូចជា ការលួចចូលប្រើប្រាស់ ការរើសអើង និងការធ្វើឱ្យខ្មាសគេ ។

**ការរើសអើងកើតមានញឹកញាប់ ជាពិសេសសម្រាប់អ្នកស្រឡាញ់ភេទដូចគ្នា ។** ២៣%នៃអ្នកស្រឡាញ់ភេទដូចគ្នា ដែលបានចូលរួមស្ទង់មតិ បានរាយការណ៍ថា ពួកគេធ្លាប់ត្រូវបានរើសអើងតាមប្រព័ន្ធអនឡាញ ដែលក្នុងនោះ ពួកគេចំនួន ៩៣% បានជួបការរើសអើងតាមប្រព័ន្ធអនឡាញលើសពីម្តង ។

**កម្មវិធីដែលជាកម្មសិទ្ធិរបស់ក្រុមហ៊ុនហ្វេសប៊ុក គឺជាកម្មវិធីចម្បងគេដែលកើតមានការបៀតបៀនតាមប្រព័ន្ធអនឡាញ ។ ៩៥%នៃអ្នកចូលរួមស្ទង់មតិដែលបានរាយការណ៍ពីការបៀតបៀនតាមប្រព័ន្ធអនឡាញ រងការបៀតបៀនតាមរយៈសេវាកម្មនៃកម្មវិធីយ៉ាងតិចមួយដែលជាកម្មសិទ្ធិរបស់ក្រុមហ៊ុនហ្វេសប៊ុក ។** ថេលេក្រាមគឺជាកម្មវិធីផ្ញើសារដែលមានការបៀតបៀនច្រើនជាងគេផងដែរ បន្ទាប់ពីកម្មវិធីរបស់ក្រុមហ៊ុនហ្វេសប៊ុក ។

**មនុស្សកំពុងត្រូវបានដាក់គោលដៅ ដោយសារអ្វីដែលពួកគេគិត និងថាពួកគេជាអ្នកណា ។** ក្នុងចំណោមអ្នកឆ្លើយតបដែលបានជួបបទពិសោធន៍នៃការបៀតបៀនតាមប្រព័ន្ធអនឡាញ ២៣%នៃពួកគេរាយការណ៍ថា ពួកគេត្រូវបានដាក់គោលដៅពាក់ព័ន្ធនឹងទស្សនៈ ឬមតិយោបល់របស់ពួកគេ ១៩%រាយការណ៍ថា ពួកគេត្រូវបានដាក់គោលដៅពាក់ព័ន្ធនឹងយេនឌ័រ ឬការបង្ហាញយេនឌ័ររបស់ពួកគេ និង១៨%ទៀតរាយការណ៍ថា ពួកគេត្រូវ

បានដាក់គោលដៅពាក់ព័ន្ធនឹងពណ៌សម្បុរ ឬរូបរាងខាងក្រៅរបស់ពួកគេ ។

**ជនប្រព្រឹត្តបទល្មើសជារឿយៗគឺជា ជនប្លែកមុខ ឬមិនស្គាល់អត្តសញ្ញាណ ហើយភាគច្រើនត្រូវបានជឿជាក់ថាជាបុរស ។** ៦៥%នៃអ្នកចូលរួមស្ទង់មតិដែលបានរាយការណ៍ពីការបៀតបៀនតាមប្រព័ន្ធអនឡាញ ជឿជាក់ថា ពួកគេត្រូវបានដាក់គោលដៅ ដោយបុរសម្នាក់ ខណៈដែល២៣%ជឿជាក់ថា ពួកគេត្រូវបានដាក់គោលដៅដោយស្ត្រីម្នាក់ ដោយអ្នកខ្លះបានរាយការណ៍ពីការបៀតបៀនដោយមនុស្សជាច្រើនដែលមានយេនឌ័រខុសៗគ្នា និងដោយអ្នកផ្សេងទៀតដែលមិនត្រូវបានស្គាល់អត្តសញ្ញាណយេនឌ័រច្បាស់លាស់ ។

**អាជ្ញាធរកម្ពុជា តាមដាន និងធ្វើទុក្ខបុកម្នេញសកម្មជន និងអ្នកផ្សេងទៀត ដើម្បីគាបសង្កត់សេរីភាព នៃការបញ្ចេញមតិតាមប្រព័ន្ធអនឡាញ ។** អ្នកចូលរួមស្ទង់មតិមួយចំនួន បានរាយការណ៍ថា អាជ្ញាធរបានកោះហៅពួកគេទៅសាកសួរ បង្គាប់ឱ្យពួកគេលុបការបង្ហោះសាររបស់ពួកគេ ឬឱ្យសុំទោសពីអ្វីដែលពួកគេបានបង្ហោះនៅលើប្រព័ន្ធអនឡាញ ព្រមទាំងដាក់គោលដៅលើសកម្មជនដោយមិនសមស្រប ។

**ការបៀតបៀនតាមប្រព័ន្ធអនឡាញ កំពុងរុញច្រានមនុស្សឱ្យឈប់ប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម ។** ៣៦%នៃអ្នកចូលរួមស្ទង់មតិដែលធ្លាប់ជួបបទពិសោធន៍នៃការបៀតបៀនតាមប្រព័ន្ធអនឡាញ បានកាត់បន្ថយការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម ឈប់ប្រើប្រាស់ទាំងស្រុង ឬលុបចោលគណនីរបស់ពួកគេក្រោយពីត្រូវបានធ្វើទុក្ខបុកម្នេញ ដោយក្នុងនោះ ស្ត្រីទំនងជាមានអត្រាឈប់ប្រើប្រាស់ច្រើនជាងបុរស ។ ជាពិសេស យុវជនទំនងដកខ្លួនពីការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម ដោយសារការបៀតបៀនតាមប្រព័ន្ធអនឡាញ ។ ក្នុងចំណោមយុវជនចូលរួមស្ទង់មតិដែលបានរងការបៀតបៀនតាមប្រព័ន្ធអនឡាញ ៥៣%នៃពួកគេ បានរាយការណ៍ថា បានកាត់បន្ថយការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម ។

**ការបៀតបៀនតាមប្រព័ន្ធអនឡាញអាចនាំឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់ជីវិតរស់នៅផ្ទាល់ ។** ក្នុងចំណោមអ្នកចូលរួមស្ទង់មតិដែលបានរាយការណ៍ពីបទពិសោធន៍នៃការបៀតបៀនតាមប្រព័ន្ធអនឡាញ ៨០%នៃពួកគេបានកើតទុក្ខតិចតួច ឬខ្លាំង ហើយ៧១% បានរាយការណ៍ពីផលប៉ះពាល់អវិជ្ជមានយ៉ាងតិចមួយ ។ ២៧%នៃអ្នកចូលរួមស្ទង់មតិដែលបានជួបបទពិសោធន៍នៃការបៀតបៀនតាមប្រព័ន្ធអនឡាញ បានរាយការណ៍ពីភាពភ័យខ្លាចទៅលើសុវត្ថិភាពបុគ្គលរបស់ពួកគេ ឬសុវត្ថិភាពរបស់មនុស្សដែលស្និទ្ធនឹងពួកគេ២៤%បានរាយការណ៍ពីអារម្មណ៍នៃការដកខ្លួន ឬឃ្លាតឆ្ងាយពីសង្គម និង១៩%បានរាយការណ៍ពីការបាត់បង់ទំនុកចិត្តលើខ្លួនឯងជាងមុន ។ អ្នកឆ្លើយតបមួយចំនួន បានរាយការណ៍ពីផលប៉ះពាល់ធ្ងន់ធ្ងរដោយសារការបៀតបៀនតាមប្រព័ន្ធអនឡាញ ដោយក្នុងនោះ ១៣%នៃពួកគេ បានរាយការណ៍ពីគ្រោះថ្នាក់លើរូបរាងកាយ ឬអំពើហិង្សាក្រៅប្រព័ន្ធអនឡាញ ១១%បានរាយការណ៍ពីបញ្ហាក្នុងការស្វែងរកការងារការសិក្សា ទីលំនៅ ឬសេវាកម្មផ្សេងៗ និង៤%ទៀត បានរាយការណ៍ពីការគិតធ្វើអត្តឃាត ។ យុវជន និងអ្នកស្រឡាញ់ភេទដូចគ្នា បានរាយការណ៍ញឹកញាប់ជាងគេអំពីផលប៉ះពាល់អវិជ្ជមាន ខណៈដែលសកម្មជនភាគច្រើនទំនងជាភ័យខ្លាចចំពោះសុវត្ថិភាពបុគ្គលរបស់ពួកគេ ។

## *អនុសាសន៍សំខាន់ៗ*

*អាជ្ញាធរកម្ពុជា និងក្រុមហ៊ុនប្រព័ន្ធផ្សព្វផ្សាយសង្គម គួរដើរតួជាអ្នកដឹកនាំក្នុងការបញ្ឈប់ការបៀតបៀនតាមប្រព័ន្ធអនឡាញ អនុសាសន៍ទាំងស្រុង មាននៅផ្នែកចុងក្រោយនៃរបាយការណ៍នេះ។*

### *អនុសាសន៍ទៅកាន់ក្រុមហ៊ុនប្រព័ន្ធផ្សព្វផ្សាយសង្គម*

- *សូមបង្កើនការការពារលំនាំដើមជាអតិបរមា ។ អនុវត្តការកំណត់ឯកជនភាព និងសុវត្ថិភាពជាលំនាំដើមដែលផ្តល់ការការពារជាអតិបរមាប្រឆាំងនឹងការបៀតបៀនតាមប្រព័ន្ធអនឡាញ។*

- *សូមកំណត់ទីតាំងមុខងារសុវត្ថិភាព និងធានាថា មុខងារទាំងនោះគឺងាយស្រួលក្នុងការស្វែងរក និងប្រើប្រាស់។ ធ្វើឱ្យលក្ខខណ្ឌទាំងអស់នៃការប្រើប្រាស់ ស្តង់ដារសហគមន៍ ការកំណត់ឯកជនភាពនិងសុវត្ថិភាព យន្តការនៃការរាយការណ៍ សម្ភារៈគាំទ្រ និងរបាយការណ៍ប្រកបដោយតម្លាភាពជាភាសាខ្មែរ ។ សកម្មក្នុងការលើកកម្ពស់ការយល់ដឹងអំពីករណីទាំងអស់នេះ ។*

- *សូមបង្កើនតម្លាភាព៖ ចេញផ្សាយរបាយការណ៍ស្តីពីកម្ពុជាប្រកបដោយតម្លាភាព ដោយភ្ជាប់ជាមួយនឹងព័ត៌មានលម្អិតអំពីចំនួនរាយការណ៍ពីអ្នកប្រើប្រាស់ សកម្មក្នុងការចាត់វិធានការលើមាតិកាសំណើរបស់រាជរដ្ឋាភិបាល ការរឹតត្បិតផ្អែកតាមច្បាប់កម្ពុជា ប្រភេទនៃរបាយការណ៍ សំណើ ការរឹតត្បិត ឬមាតិកា និងវិធានការដាក់លាក់របស់ក្រុមហ៊ុន ។*

### *អនុសាសន៍ទៅកាន់អាជ្ញាធរកម្ពុជា*

- *សូមបញ្ឈប់ការបៀតបៀនតាមប្រព័ន្ធអនឡាញ ។ សូមដោះលែងឱ្យបានឆាប់រហ័ស និងដោយគ្មានលក្ខខណ្ឌនូវសកម្មជនទាំងអស់ និងអ្នកផ្សេងទៀត ដែលត្រូវបានឃុំខ្លួនក្នុងពន្ធនាគារដោយសារការប្រើប្រាស់សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិរបស់ពួកគេតាមប្រព័ន្ធអនឡាញ ។ សូមបញ្ឈប់ការធ្វើទុក្ខបុកម្នេញលើស្ត្រីភេទពាក់ព័ន្ធនឹងជម្រើសនៃការស្លៀកពាក់ ឬការសម្តែងមតិរបស់ពួកគេលើប្រព័ន្ធអនឡាញ ។*

- *សូមបញ្ឈប់ការតាមដានដ៏លើសលប់ និងគ្មានតម្លាភាព ។ សូមនិរាករណ៍ ឬធ្វើវិសោធនកម្មច្បាប់ស្តីពីទូរគមនាគមន៍ ប្រកាសអន្តរក្រសួងលេខ ១៧០ និងអនុក្រឹត្យលេខ២៣ស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ ។ សូមបោះបង់ចោលសេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន និងសេចក្តីព្រាងច្បាប់ស្តីសណ្តាប់ធ្នាប់សាធារណៈ ។*

- *សូមបង្កើនសមត្ថភាពក្នុងការបញ្ឈប់ការបៀតបៀនតាមប្រព័ន្ធអនឡាញ ។ សូមបណ្តុះបណ្តាលជាប្រចាំចំពោះអាជ្ញាធរមូលដ្ឋាន នគរបាល ព្រះរាជអាជ្ញា ចៅក្រម មេធាវី និងគ្រូបង្រៀន ស្តីពីអក្ខរកម្មប្រព័ន្ធឌីជីថលការបៀតបៀនតាមប្រព័ន្ធអនឡាញការទប់ស្កាត់ការឆ្លើយតប និងក្របខ័ណ្ឌផ្លូវច្បាប់ផ្សេងទៀតដែលមានស្រាប់ ។*

**ការឆ្លើយតបដើម្បីដោះស្រាយបញ្ហាបៀតបៀនតាមប្រព័ន្ធអនឡាញគឺមិនគ្រប់គ្រាន់** ។ អ្នកឆ្លើយតបត្រឹម ១៦% ប៉ុណ្ណោះ ដែលធ្លាប់ត្រូវបានបៀតបៀនតាមប្រព័ន្ធអនឡាញក្នុងករណីជាច្រើនហើយមានអារម្មណ៍ថា ករណីរបស់ពួកគេត្រូវបានដោះស្រាយដោយពេញលេញ និងយុត្តិធម៌ ។ ការឆ្លើយតបញឹកញាប់ជាងគេចំពោះការបៀតបៀនតាមប្រព័ន្ធអនឡាញ គឺជា ការផ្តាច់ទំនាក់ទំនងជាមិត្ត ឬប្លុក (រាំងខ្ទប់) ជនប្រព្រឹត្តបទល្មើស ឬការបង្ហោះសាររបស់ពួកគេ ឬបង្កើនការកំណត់ឯកជនភាព ឬសុវត្ថិភាព ។ ទោះបីជាយ៉ាងណាក៏ដោយ អ្នកផ្តល់បទសម្ភាសន៍ជាច្រើន បានលើកឡើងថា ការប្លុកគឺមិនគ្រប់គ្រាន់ដើម្បីបញ្ឈប់ជនល្មើសទាំងស្រុងពីការបៀតបៀនពួកគេតាមប្រព័ន្ធអនឡាញទេ ។ ៧៦% នៃអ្នកចូលរួមស្ទង់មតិ គិតថា តួអង្គសំខាន់យ៉ាងតិចមួយ គួរចាត់វិធានការឱ្យបានច្រើនជាងនេះ ដើម្បីបញ្ឈប់ការបៀតបៀនតាមប្រព័ន្ធអនឡាញ ជាពិសេសគឺអាជ្ញាធរ និងក្រុមហ៊ុនប្រព័ន្ធផ្សព្វផ្សាយសង្គម ។

**ក្រុមហ៊ុនប្រព័ន្ធផ្សព្វផ្សាយសង្គម និងអាជ្ញាធរកម្ពុជា គួរបំពេញទំនួលខុសត្រូវរបស់ខ្លួនក្នុងការការពារសិទ្ធិមនុស្សតាមប្រព័ន្ធអនឡាញ** ។ បញ្ហាជាច្រើនដែលបានលើកឡើងនៅក្នុងរបាយការណ៍នេះ ត្រូវបានក្រុមហ៊ុនប្រព័ន្ធផ្សព្វផ្សាយដឹងឮរួចហើយ ជាពិសេសគឺក្រុមហ៊ុនហ្វេសប៊ុក ប៉ុន្តែពួកគេនៅតែពុំទាន់ចាត់វិធានការឱ្យមានប្រសិទ្ធភាព ទៅលើបញ្ហាទាំងនោះ ។ លក្ខខណ្ឌប្រើប្រាស់ ការកំណត់ឯកជនភាពនិងសុវត្ថិភាព និងមុខងាររាយការណ៍របស់ក្រុមហ៊ុនប្រព័ន្ធផ្សព្វផ្សាយសង្គម ជារឿយៗតែងមានភាពភាន់ច្រឡំ មិនអាចប្រើប្រាស់បាន ឬគ្មានប្រសិទ្ធភាព ។ លក្ខខណ្ឌទាំងនេះមិនអាចប្រើប្រាស់ជាភាសាខ្មែរ ដែលធ្វើឱ្យប្រជាពលរដ្ឋខ្មែរមានសិទ្ធិគ្រប់គ្រងតិចតួចលើសុវត្ថិភាពរបស់ខ្លួន ។ ស្រដៀងគ្នានេះដែរ ដំណើរការរាយការណ៍របស់ក្រុមហ៊ុនហ្វេសប៊ុក គឺមានភាពពិបាកក្នុងការប្រើប្រាស់ការឆ្លើយតប គឺមានភាពយឺតយ៉ាវ ហើយអ្នកប្រើប្រាស់ទទួលបានការធ្វើបច្ចុប្បន្នភាពតិចតួចប៉ុណ្ណោះអំពីដំណើរការរបស់ពួកគេ ។ តម្លាភាពប្រសើរជាងនេះគឺត្រូវការជាចាំបាច់ ។ នៅខែតុលា និងខែវិច្ឆិកា ឆ្នាំ២០២១ អង្គការលីកាដូ បានផ្ញើសារទៅក្រុមហ៊ុនហ្វេសប៊ុក ដើម្បីចែករំលែកការរកឃើញសំខាន់ៗនៃរបាយការណ៍នេះ ព្រមទាំងស្នើសុំព័ត៌មាន និងតម្លាភាពបន្ថែមទៀត ។ ក្រុមហ៊ុនហ្វេសប៊ុក មិនបានឆ្លើយតបប្រកបដោយអត្ថន័យនោះទេ ។

# សេចក្តីផ្តើម

ការបៀតបៀនតាមប្រព័ន្ធអនឡាញដោយបុគ្គល និងតួអង្គរដ្ឋនៅក្នុងប្រទេសកម្ពុជា កំពុងធ្វើឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិសិទ្ធិឯកជនភាព សិទ្ធិទទួលបានព័ត៌មាន និងសិទ្ធិជាច្រើនទៀត ។ អ៊ីនធឺណិត និងប្រព័ន្ធផ្សព្វផ្សាយសង្គម ដែលមានសក្តានុពល ក្នុងការភ្ជាប់ទំនាក់ទំនងរវាងបុគ្គល និងលើកកម្ពស់ការចូលរួមដ៏សកម្មរបស់ប្រជាពលរដ្ឋ និងនយោបាយ កំពុងត្រូវបានរារាំងដោយការតាមដាន និងការធ្វើទុក្ខបុកម្នេញពីសំណាក់អាជ្ញាធរ ក៏ដូចជាការរើសអើង ការបៀតបៀនផ្លូវភេទ ការគំរាមកំហែង និងទម្រង់ផ្សេងទៀតនៃការបៀតបៀនតាមប្រព័ន្ធអនឡាញពីសំណាក់បុគ្គលឯកជន ។ ដោយសារសេរីភាពសារព័ត៌មាននៅកម្ពុជា ត្រូវបានរឹតត្បិតយ៉ាងខ្លាំង ខណៈដែលប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី ត្រូវបានគ្រប់គ្រងយ៉ាងទូលំទូលាយដោយអ្នកមានទំនាក់ទំនងជិតស្និទ្ធជាមួយគណបក្សកាន់អំណាច ប្រព័ន្ធផ្សព្វផ្សាយសង្គមគឺជា កន្លែងដែលមានសារៈសំខាន់មួយ សម្រាប់ប្រជាពលរដ្ឋកម្ពុជា ដើម្បីទទួលបានព័ត៌មាន និងចូលរួមក្នុងកិច្ចពិភាក្សានយោបាយ ។ ប៉ុន្តែការបៀតបៀនតាមប្រព័ន្ធអនឡាញ កំពុងរុញច្រានមនុស្សឱ្យឈប់ប្រើប្រាស់ប្រព័ន្ធអនឡាញ និងអាចមានផលវិបាកធ្ងន់ធ្ងរនៅក្រៅប្រព័ន្ធអនឡាញ សម្រាប់អ្នកដែលធ្លាប់ជួបការបៀតបៀន ។

ការបៀតបៀនតាមប្រព័ន្ធអនឡាញ អាចធ្វើឱ្យប៉ះពាល់ដល់ប្រជាពលរដ្ឋកម្ពុជាប្រមាណ ៨,៨៦លាននាក់ (ច្រើនជាងពាក់កណ្តាលនៃប្រជាជនសរុប) ដែលប្រើប្រាស់អ៊ីនធឺណិត គិតត្រឹមខែមករា ឆ្នាំ២០២១ ។ ប្រទេសកម្ពុជា មានបណ្តាញតភ្ជាប់ចល័តចំនួន ២១លាន ហើយ៩០%នៃអ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមចូលប្រើប្រាស់សេវាកម្មទាំងនេះតាមរយៈទូរស័ព្ទឆ្លាតវៃតែប៉ុណ្ណោះ ។ ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមបានកើនឡើងចំនួន ២៤%ក្នុងឆ្នាំ២០២០ ខណៈដែលការប្រើប្រាស់អ៊ីនធឺណិតបន្តពង្រីកវិសាលភាពនៅទូទាំងប្រទេស ។ ការរឹតត្បិតដោយសារជំងឺកូវីដ-១៩ ការកើនឡើងនៃអត្រាអ្នកគ្មានការងារធ្វើ ការអូសបន្លាយពេលនៃការបិទសាលារៀន បានផ្លាស់ប្តូរជីវិតរស់នៅរបស់មនុស្សឱ្យប្រើប្រាស់ប្រព័ន្ធអនឡាញកាន់តែច្រើនថែមទៀត ។

ការកើនឡើងនៃការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម នាំឱ្យមានកង្វល់អំពីការកើនឡើង នៃការបៀតបៀនតាមប្រព័ន្ធអនឡាញ។ ការសិក្សាមួយរបស់ LIRNEasia ក្នុងឆ្នាំ២០១៨ បានរកឃើញថា ២៩%នៃអ្នកប្រើប្រាស់អ៊ីនធឺណិតជាស្ត្រី និង២៣%នៃអ្នកប្រើប្រាស់អ៊ីនធឺណិតជាបុរសនៅក្នុងប្រទេសកម្ពុជា បានជួបបទពិសោធន៍នៃការបៀតបៀនតាមប្រព័ន្ធអនឡាញ ។[៥] ខណៈដែលការបៀតបៀន




[២] របាយការណ៍ស្តីពី "ឌីជីថល ឆ្នាំ២០២១ នៅកម្ពុជា" ចេញផ្សាយដោយលោក Simon Kemp កាលពីថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ២០២១ ។ ដកស្រង់ពី៖ https://datareportal.com/reports/digital-2021-cambodia

[៣] ដូចគ្នាខាងលើ ។

[៤] ដូចគ្នាខាងលើ ។

[៥] របាយការណ៍ស្តីពី "AfterAccess៖ ការទទួលបាន និងការប្រើប្រាស់បច្ចេកវិទ្យាទំនាក់ទំនងព័ត៌មាននៅតំបន់អាស៊ី និងសកលលោកខាងត្បូង" ចេញផ្សាយដោយ LIRNEasia ទំព័រទី៦៣ ក្នុងឆ្នាំ២០១៨ ។ ដកស្រង់ពី៖ https://lirneasia.net/wp-content/uploads/2018/10/LIRNEasia-AfterAccess-Asia-Report.pdf របាយការណ៍នេះផ្តល់និយមន័យការបៀតបៀនតាមប្រព័ន្ធអនឡាញថាជា ការដែលត្រូវបាន ហៅឈ្មោះបែបហិង្សា រិះគន់ឬធ្វើឱ្យខ្មាសគេដោយចេតនាតាមមធ្យោបាយផ្សេងទៀត គំរាមកំហែងដោយផ្ទាល់ បៀតបៀនផ្លូវភេទ ឬការទាក់ទងរំខានម្តងហើយម្តងទៀត ។

តាមប្រព័ន្ធអនឡាញ ត្រូវបានទទួលស្គាល់ច្រើនឡើងៗថាជាបញ្ហាសកលមួយ ការសិក្សាលក្ខណៈអន្តរជាតិជាច្រើនទៅលើប្រធានបទនេះមិនបានរួមបញ្ចូលប្រទេសកម្ពុជាទេ ។[៦]

ការស្រាវជ្រាវនេះ ត្រូវបានធ្វើឡើង ដើម្បីយល់ដឹងឱ្យបានច្រើនអំពីអ្នកដែលកំពុងប្រឈមនឹងការបៀតបៀនតាមប្រព័ន្ធអនឡាញនៅក្នុងប្រទេសកម្ពុជា ប្រភេទនៃការបៀតបៀន ដែលកើតមានញឹកញាប់ជាងគេ ផលប៉ះពាល់នៃការបៀតបៀនតាមប្រព័ន្ធអនឡាញនិងដំណោះស្រាយដែលអាចទៅរួច ដើម្បីដោះស្រាយបញ្ហាទាំងនេះ ។

## តើអ្វីទៅជាការបៀតបៀនតាមប្រព័ន្ធអនឡាញ?

យើងឱ្យនិយមន័យការបៀតបៀនតាមប្រព័ន្ធអនឡាញថា រាល់សកម្មភាពទាំងឡាយណាដែលស្តែងចេញ ឬអាចនឹងនាំឱ្យមាន ការប៉ះពាល់ ឬការរងគ្រោះផ្នែករូបរាងកាយ ផ្លូវភេទ ផ្លូវចិត្ត ឬផ្នែកសង្គម ដែលត្រូវបានប្រព្រឹត្ត ជំរុញ ឬធ្វើឱ្យកាន់តែធ្ងន់ធ្ងរបន្ថែមទៀត ដោយការប្រើប្រាស់បច្ចេកវិទ្យាទំនាក់ទំនងព័ត៌មាន ដូចជាប្រព័ន្ធផ្សព្វផ្សាយសង្គម ទូរស័ព្ទចល័ត និងទូរស័ព្ទឆ្លាតវៃ ឬការប្រើប្រាស់អ៊ីនធឺណិតបែបទូលំទូលាយផ្សេងទៀត ។

និយមន័យនេះ ផ្អែកលើនិយមន័យនៃអំពើហិង្សាតាមប្រព័ន្ធអនឡាញប្រឆាំងនឹងស្ត្រី និងកុមារ ដែលកំណត់ដោយអ្នករាយការណ៍ពិសេសនៃអង្គការសហប្រជាជាតិស្តីពីអំពើហិង្សាលើស្ត្រីភេទ ផលប៉ះពាល់ និងផលវិបាកនៃអំពើហិង្សា ។ ការបៀតបៀនតាមប្រព័ន្ធអនឡាញក្នុងករណីជាច្រើន គឺជាសកម្មភាពនៃអំពើហិង្សាផ្អែកយេនឌ័រ ដែលត្រូវបានប្រព្រឹត្តទៅលើស្ត្រី ដោយសារនាងគឺជាស្ត្រី ឬដែលប៉ះពាល់ស្ត្រីដោយមិនសមស្រប ។[៧]

ប្រភេទសំខាន់ៗនៃការបៀតបៀនតាមប្រព័ន្ធអនឡាញ ដែលយើងមានបំណងដើម្បីសិក្សាមានដូចជា៖

- ការរើសអើង ឬភាសាបែបរើសអើង
- ការចែកចាយ រូបភាពឬវីដេអូឯកជន (អាក្រាត ស្រើបស្រាល រួមសង្វាស) ដោយគ្មានការយល់ព្រម
- ការបែកធ្លាយ (ការលួចចែកចាយព័ត៌មានឯកជនរបស់នរណាម្នាក់ ដូចជា លេខទូរស័ព្ទ អាសយដ្ឋាន ឬព័ត៌មានលម្អិតនៃអត្តសញ្ញាណ ដោយគ្មានការអនុញ្ញាត)
- ការលួចចូល ឬការចូលទៅប្រើប្រាស់គណនីមួយ ដោយគ្មានការអនុញ្ញាត
- ការក្លែងអត្តសញ្ញាណក្នុងគោលបំណងធ្វើឱ្យខូចខាតដល់នរណាម្នាក់ (ដូចជាការបង្កើតគណនីក្លែងក្លាយ ឬការផ្ញើសារដោយប្រើប្រាស់ឈ្មោះអ្នកដទៃ)
- ការធ្វើឱ្យខ្មាសគេដោយចេតនា
- ការរឹតត្បិតរបស់អាជ្ញាធរលើការបញ្ចេញមតិតាមប្រព័ន្ធអនឡាញ ដូចជា ការកោះហៅទៅសាកសួរពីការបង្ហោះសារ តាមប្រព័ន្ធអនឡាញ ការបង្គាប់ឱ្យលុបចោលសារបង្ហោះ ឬឱ្យធ្វើលិខិតសុំទោស
- ការបៀតបៀនផ្លូវភេទ (ការទទួលសារជាអក្សរ រូបភាព ឬវីដេអូ ឬសំណើបែបផ្លូវភេទ ដែលពុំបានស្នើសុំ)
- ការផ្សព្វផ្សាយកុហកអំពីនរណាម្នាក់
- ការគំរាមកំហែង

[៦] សូមមើលឧទាហរណ៍ "អំពើហិង្សាតាមប្រព័ន្ធអនឡាញប្រឆាំងនឹងស្ត្រីភេទក្នុងតំបន់អាស៊ី៖ ការសិក្សាក្នុងប្រទេសជាច្រើន" ចេញផ្សាយដោយអង្គការសហប្រជាជាតិដើម្បីស្ត្រី ក្នុងឆ្នាំ២០២០ ដកស្រង់ពី៖ https://asiapacific.unwomen.org/-/media/field%20office%20eseasia/docs/publications/2020/12/ap-ict-vawg-report-7dec20.pdf?la=en&vs=4251 និង "សេរីភាពនៅលើប្រព័ន្ធអនឡាញ? បទពិសោធន៍នៃការបៀតបៀនតាមប្រព័ន្ធអនឡាញរបស់ស្ត្រីវ័យក្មេង និងក្មេងស្រី" ចេញផ្សាយដោយ Plan International ក្នុងឆ្នាំ២០២០ ដកស្រង់ពី៖ https://plan-international.org/publications/freetobeonline និង "ការវាស់វែងការរាលដាលនៃអំពើហិង្សាតាមប្រព័ន្ធអនឡាញប្រឆាំងស្ត្រីភេទ" ចេញផ្សាយដោយ The Economist Intelligence Unit ក្នុងឆ្នាំ២០២១ ដកស្រង់ពី៖ https://onlineviolencewomen.eiu.com/

[៧] របាយការណ៍របស់អ្នករាយការណ៍ពិសេសនៃអង្គការសហប្រជាជាតិស្តីពីអំពើហិង្សាប្រឆាំងនឹងស្ត្រីភេទ ផលប៉ះពាល់ និងផលវិបាកនៃអំពើហិង្សាតាមប្រព័ន្ធអនឡាញប្រឆាំងនឹងស្ត្រី និងក្មេងស្រី តាមការយល់ឃើញផ្នែកសិទ្ធិមនុស្ស លេខ A/HRC/38/47 កថាខណ្ឌទី ២២ ដល់ ២៣ ចេញផ្សាយឆ្នាំ ២០១៨ ដកស្រង់ពី៖ https://undocs.org/A/HRC/38/47

# ការបៀតបៀនតាមប្រព័ន្ធអនឡាញ និងសិទ្ធិមនុស្ស

សិទ្ធិមនុស្ស ដែលត្រូវបានការពារ នៅក្រៅប្រព័ន្ធអនឡាញគួរត្រូវបានការពារនៅលើប្រព័ន្ធអនឡាញផងដែរ ។[៨] រចនាសម្ព័ន្ធសង្គម សេដ្ឋកិច្ច នយោបាយ និងរចនាសម្ព័ន្ធអំណាចផ្សេងទៀត ដែលគំរាមកំហែងសិទ្ធិមនុស្សនៅក្រៅប្រព័ន្ធអនឡាញ ជារឿយៗគំរាមកំហែងបន្ថែមទៀតតាមប្រព័ន្ធអនឡាញដូចគ្នា ។ ការបៀតបៀនតាមប្រព័ន្ធអនឡាញ អាចរំលោភសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ សិទ្ធិជួបជុំនិងប្រមូលផ្តុំគ្នា សិទ្ធិទទួលបានព័ត៌មាន ការចូលរួមក្នុងជីវភាពនយោបាយ និងវប្បធម៌ សិទ្ធិគ្មានការរើសអើង សេរីភាពជំនឿសាសនា ការអប់រំ សិទ្ធិកុមារ និងសិទ្ធិផ្សេងៗច្រើនទៀត ។ អ្នកប្រើប្រាស់អ៊ីនធឺណិតក៏មានសិទ្ធិក្នុងការការពារប្រឆាំងនឹងការជ្រៀតជ្រែកខុសច្បាប់ទៅលើការសន្ទនា និងឯកជនភាពរបស់ពួកគេ ក៏ដូចជាការវាយប្រហារដោយមិនត្រឹមត្រូវលើកិត្តិយសរបស់ពួកគេ ។[៩]

អាជ្ញាធរកម្ពុជាមានកាតព្វកិច្ច ក្នុងការការពារសិទ្ធិទាំងនេះ តាមរយៈរដ្ឋធម្មនុញ្ញ និងការផ្តល់សច្ចាប័នទៅលើកតិកាសញ្ញាអន្តរជាតិជាច្រើនផ្សេងទៀត។[១០] ស្រដៀងគ្នានេះដែរ រាជរដ្ឋាភិបាលបានប្តេជ្ញាក្នុងការដោះស្រាយការរើសអើងចំពោះស្ត្រីភេទ និងអំពើហិង្សាផ្អែកយេនឌ័រ ដែលអ្នកជំនាញនៃអង្គការសហប្រជាជាតិបានទទួលស្គាល់ថា អាចកើតឡើងទាំងនៅតាមប្រព័ន្ធអនឡាញ និងក្រៅប្រព័ន្ធអនឡាញ ។[១១]

ការការពារសិទ្ធិទាំងនេះ ក៏ជាទំនួលខុសត្រូវរបស់ក្រុមហ៊ុនអ៊ីនធឺណិត និងប្រព័ន្ធផ្សព្វផ្សាយសង្គមផងដែរ ។ គោលការណ៍ណែនាំស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស បានបង្កើតឱ្យមានស្តង់ដារសកល សម្រាប់តួអង្គវិស័យឯកជនដើម្បីជៀសវាងធ្វើឱ្យប៉ះពាល់ ឬចូលរួមឱ្យមានផលប៉ះពាល់អវិជ្ជមានលើសិទ្ធិមនុស្ស ចាត់វិធានការចាំបាច់ទាំងអស់ដោយហ្មត់ចត់ទប់ស្កាត់ឬកាត់បន្ថយផលប៉ះពាល់ដែលជាប់ពាក់ព័ន្ធនឹងការប្រតិបត្តិការឬសេវាកម្មរបស់ពួកគេ ផ្តល់ការកែតម្រូវ រាយការណ៍ពីរបៀបដែលផលប៉ះពាល់ត្រូវបានដោះស្រាយ និងយន្តការផ្សេងទៀត ។[១២] វិធានការចាំបាច់ត្រូវចាប់ផ្តើមជាមួយការធ្វើធុរកិច្ចដែលពាក់ព័ន្ធនឹង "ទិដ្ឋភាពសិទ្ធិមនុស្សដែលចាត់វិធានការទៅលើផលប៉ះពាល់ បែបអវិជ្ជមានចំពោះប្រជាពលរដ្ឋ ដែលអាចកើតមានឡើង និងកំពុងកើតមានឡើងជាក់ស្តែង" ដើម្បីដោះស្រាយនិងទប់ស្កាត់ផលប៉ះពាល់ទាំងនោះ គួបផ្សំនឹងសកម្មភាពក្រោយការរកឃើញការតាមដានប្រសិទ្ធភាព និងការទំនាក់ទំនងពីរបៀបដែលផលប៉ះពាល់ត្រូវបានដោះស្រាយ ។[១៣] អំណះអំណាងដើម្បីឱ្យក្រុមហ៊ុនអ៊ីនធឺណិត អនុវត្តនិងយល់ដឹងឱ្យបានពេញលេញនូវគោលការណ៍ណែនាំគឺរឹងមាំ ដោយសារ "តួនាទីលើសលប់របស់ពួកគេក្នុងជីវិតសាធារណៈជាសកល" ដូចបានលើកឡើងដោយអ្នករាយការណ៍ពិសេសនៃអង្គការសហប្រជាជាតិស្តីពីការលើកកម្ពស់ និងការពារសេរីភាពនៃគំនិត និងការសម្តែងមតិ ។[១៤]

ទោះបីជាយ៉ាងណាក៏ដោយ ការដោះស្រាយការបៀតបៀនតាមប្រព័ន្ធអនឡាញ មិនគួរត្រូវបានប្រើប្រាស់ដោយមិនត្រឹមត្រូវ ដើម្បីជាសម្អាងហេតុនៃការរំលោភសេរីភាពជាមូលដ្ឋាននោះទេ ។ ការឆ្លើយតបចំពោះការបៀតបៀនតាមប្រព័ន្ធអនឡាញ គួរត្រូវបានធ្វើឡើងដោយប្រុងប្រយ័ត្នក្នុងការពិចារណាទៅលើករណីលើកលែងតាមផ្លូវច្បាប់ដែលបានបង្កើតឡើង ដើម្បីទប់ស្កាត់ការរឹតត្បិតដោយមិនសមស្រប ឬការធ្វើឱ្យប៉ះពាល់បន្ថែមទៀតទៅលើសេរីភាពជាមូលដ្ឋានតាមប្រព័ន្ធអនឡាញ ។ ការរឹតត្បិតណាមួយទៅលើសេរីភាពនៃការបញ្ចេញមតិ ការជួបជុំឬប្រមូលផ្តុំគ្នាតាមប្រព័ន្ធអនឡាញ ត្រូវតែផ្តល់ដោយច្បាប់ដែលមានលក្ខណៈចង្អៀត និងជាក់លាក់ ដោយមានគោលបំណងស្របច្បាប់មួយ និងគោរពគោលការណ៍នៃភាពចាំបាច់ និងភាពសមស្រប ។ ការរឹតត្បិតត្រូវធ្វើឡើងដោយស្ថាប័នឯករាជ្យ និងធានាពីលទ្ធភាពនៃការជំទាស់ និងដំណោះស្រាយចំពោះការរឹតត្បិតដោយមិនត្រឹមត្រូវ ។[១៥]

---

[៨] ដំណោះស្រាយក្រុមប្រឹក្សាសិទ្ធិមនុស្ស លេខ 32/13 កថាខណ្ឌទី១ ។ ដកស្រង់ពី៖ https://ap.ohchr.org/documents/dpage_e.aspx?si=A/HRC/RES/32/13

[៩] មាត្រា១៧ នៃកតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងនយោបាយ (ICCPR)

[១០] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ធានាថា "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយ ទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ (មាត្រា៣១) ។ សូមមើល មាត្រា៣២ មាត្រា៣៥ មាត្រា៣៨ មាត្រា៤០ដល់មាត្រា៤៣ មាត្រា៤៥ មាត្រា៤៨ និងមាត្រា៦៥ ។ ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នទៅលើ ICCPR អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW) កតិកាសញ្ញាស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ (ICESCR) អនុសញ្ញាស្តីពីសិទ្ធិកុមារ អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិជនពិការ និងផ្សេងទៀត ។

[១១] គណៈកម្មការស្តីពី ការលុបបំបាត់នៃការរើសអើងប្រឆាំងនឹងអនុសាសន៍ទូទៅរបស់ស្ត្រី លេខ. ៣៥ កថាខណ្ឌទី២០ ចេញផ្សាយឆ្នាំ២០១៧ ដកស្រង់ពី៖ https://tbinternet.ohchr.org/Treaties/CEDAW/Shared%20Documents/1_Global/CEDAW_C_GC_35_8267_E.pdf និងរបាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីអំពើហិង្សាប្រឆាំងនឹងស្ត្រីភេទ ផលប៉ះពាល់នៃហិង្សា និងផលវិបាកនៃអំពើហិង្សាតាមប្រព័ន្ធអនឡាញប្រឆាំងនឹងស្ត្រី និងក្មេងស្រី តាមការយល់ឃើញផ្អែកសិទ្ធិមនុស្ស លេខ A/HRC/38/47 កថាខណ្ឌទី ៩៣ ចេញផ្សាយឆ្នាំ ២០១៨ ដកស្រង់ពី៖ https://undocs.org/A/HRC/38/47

[១២] សូមមើល "គោលការណ៍ណែនាំស្តីពី ធុរកិច្ច និងសិទ្ធិមនុស្ស៖ ការអនុវត្តក្របខ័ណ្ឌការពារ គោរព និងដំណោះស្រាយ នៃអង្គការសហប្រជាជាតិ" ចេញផ្សាយឆ្នាំ២០១១ ។ ដកស្រង់ពី៖ https://www.ohchr.org/documents/publications/guidingprinciplesbusinesshr_en.pdf

[១៣] របាយការណ៍របស់ក្រុមការងារស្តីពីបញ្ហាសិទ្ធិមនុស្ស និងសាជីវកម្មឆ្លងដែន និងសហគ្រាសអាជីវកម្មផ្សេងទៀត លេខ. A/73/163 កថាខណ្ឌទី៤៣ ចេញផ្សាយឆ្នាំ២០១៨ ដកស្រង់ពី៖ https://ap.ohchr.org/documents/dpage_e.aspx?si=A/73/163

[១៤] របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីការលើកកម្ពស់ និងការការពារសិទ្ធិសេរីភាពនៃគំនិត និងការបញ្ចេញមតិ លេខ. A/HRC/38/35 កថាខណ្ឌទី១០ ចេញផ្សាយឆ្នាំ២០១៨ ។ ដកស្រង់ពី៖ https://undocs.org/A/HRC/38/35

[១៥] មាត្រា១៩(៣) និងមាត្រា២២(២) នៃ ICCPR និងរបាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីការលើកកម្ពស់ និងការការពារសិទ្ធិសេរីភាពនៃគំនិត និងការបញ្ចេញមតិ លេខ. A/HRC/17/27 កថាខណ្ឌទី៦៩ ចេញផ្សាយដោយ Frank La Rue ឆ្នាំ២០១១ ។ ដកស្រង់ពី៖ https://undocs.org/A/HRC/17/27

កាលពីខែកក្កដា និងខែសីហា ឆ្នាំ២០២១ មនុស្សចំនួន ៧១៨នាក់ បានចូលរួមក្នុងការស្ទង់មតិតាមប្រព័ន្ធអនឡាញមួយ ដែលចែកចាយដោយអង្គការលីកាដូ ។ ការស្ទង់មតិត្រូវបានចែកចាយជាភាសាខ្មែរតែប៉ុណ្ណោះ ដោយមានសំណួរបែបជ្រើសរើសចំនួន ២៧ និងសំណួរចម្លើយខ្លីៗចំនួនពីរ សម្រាប់អ្នកចូលរួមដូចជា ប្រវត្តិ ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម បទពិសោធន៍នៃការបៀតបៀនតាមប្រព័ន្ធអនឡាញ ផលប៉ះពាល់នៃការបៀតបៀន និងការឆ្លើយតបរបស់ពួកគេទៅលើការបៀតបៀននោះប្រសិនបើមាន ។ ការចូលរួមត្រូវបានកម្រិតសម្រាប់តែមនុស្សពេញវ័យដែលមានអាយុចាប់ពី១៨ឆ្នាំ ឡើងទៅតែប៉ុណ្ណោះ ដោយសារបញ្ហាលំបាកនៃការស្នើសុំការព្រមព្រៀងពីឪពុកម្តាយ ឬអាណាព្យាបាល មុនពេលកូនៗរបស់ពួកគាត់ចូលរួមក្នុងការស្ទង់មតិ ។ ការស្ទង់មតិនេះ បានពន្យល់អំពីគោលបំណងនៃការស្រាវជ្រាវ និងរបៀបដែលការរកឃើញត្រូវប្រើប្រាស់ ។ ការចូលរួមត្រូវបានធ្វើឡើងដោយមិនបង្ហាញអត្តសញ្ញាណ ធ្វើឡើងដោយស្ម័គ្រចិត្ត និងពុំមានការផ្តល់គ្រឿងលើកទឹកចិត្តទេ ។ សំណួរដែលត្រូវឆ្លើយជាចាំបាច់គឺមានតែសំណួរ ដើម្បីបញ្ជាក់ពីការយល់ព្រមរបស់អ្នកឆ្លើយតបក្នុងការចូលរួមស្ទង់មតិនេះ និងបញ្ជាក់ថាពួកគេមានអាយុចាប់ពី១៨ឆ្នាំឡើងតែប៉ុណ្ណោះ ។

ការស្ទង់មតិត្រូវបានបើក សម្រាប់មនុស្សគ្រប់យេនឌ័រទាំងអស់ និងត្រូវបានចែកចាយទៅដល់អ្នកចូលរួមច្រើនជាង ២៥ក្រុម និងបណ្តាញ ដូចជា សហជីព សហគមន៍ ក្រុមយុវជន និស្សិតសាកលវិទ្យាល័យ និងអង្គការមិនមែនរដ្ឋាភិបាល ។ ក្រុមទាំងនេះត្រូវបានជ្រើសរើស ដើម្បីលើកកម្ពស់ឱ្យមានអ្នកឆ្លើយតបចម្រុះគ្នាដោយផ្អែកលើអាយុ យេនឌ័រ និន្នាការភេទ ទីតាំង មុខរបរ និងបុគ្គលិកលក្ខណៈផ្សេងទៀត ។ ការស្ទង់មតិ មិនត្រូវបានចែកចាយជាសាធារណៈតាមប្រព័ន្ធអនឡាញទេ ដោយសារការព្រួយបារម្ភពីសុវត្ថិភាព និងគុណភាពនៃការស្រាវជ្រាវ ។

ការរកឃើញត្រូវបានបែងចែកជាបុគ្គលិកលក្ខណៈ ដែលមានអត្តសញ្ញាណមួយចំនួន ហើយភាគច្រើនត្រូវបានបែងចែកជា ស្ត្រី បុរស យុវជន សកម្មជន និងអ្នកស្រឡាញ់ភេទដូចគ្នា ។ អ្នកឆ្លើយតបជាច្រើនស្ថិតក្នុងចំណោមលើសពីមួយនៃក្រុមទាំងនេះ ។

កាលពីខែសីហា និងខែកញ្ញា មនុស្សចំនួន ១២នាក់ (ស្ត្រី ៧នាក់ បុរស៤នាក់ និងក្មេងស្រីម្នាក់) ត្រូវបាន សម្ភាស ដើម្បីសិក្សាបន្ថែមអំពីបទពិសោធន៍របស់ពួកគេ ។ មានតែមនុស្សដែលធ្លាប់បានទទួលរងការបៀតបៀនតាមប្រព័ន្ធអនឡាញប៉ុណ្ណោះដែលត្រូវបានអញ្ជើញឱ្យចូលរួមធ្វើបទសម្ភាសន៍ ។ អ្នកផ្តល់បទសម្ភាសន៍ត្រូវបានជ្រើសរើស ដោយផ្អែកលើបទពិសោធន៍ខុសៗគ្នា ។ ភាគច្រើននៃអ្នកចូលរួមផ្តល់បទសម្ភាសន៍ គឺជាអ្នកដែលបានឆ្លើយតបនៅក្នុងការស្ទង់មតិ និងបានស្ម័គ្រចិត្តផ្តល់ព័ត៌មានទំនាក់ទំនងលម្អិត សម្រាប់ការសួរនាំបន្ថែម ។ មនុស្ស២នាក់ ត្រូវបានអញ្ជើញឱ្យចូលរួមក្នុងកិច្ចសម្ភាសន៍ បន្ទាប់ពីពួកគេបានមកស្វែងរកការគាំទ្រពីអង្គការលីកាដូ ក្រោយពីជួបបទពិសោធន៍នៃការបៀតបៀនតាមប្រព័ន្ធអនឡាញ ។ បទសម្ភាសន៍បានចំណាយពេលចន្លោះពី ៣៥នាទី ទៅមួយម៉ោង ។ ទម្រង់ព្រមព្រៀងសម្ភាសន៍ត្រូវបានធ្វើឡើងជាមួយអ្នកចូលរួមដែលមានអាយុពេញវ័យ មុនពេលធ្វើកិច្ចសម្ភាសន៍នីមួយៗ ។ ទម្រង់ព្រមព្រៀងសម្ភាសន៍របស់ឪពុកម្តាយឬអាណាព្យាបាល និងការយល់ព្រមត្រូវបានធ្វើឡើងជាមួយកុមារដែលបានចូលរួមផ្តល់កិច្ចសម្ភាសន៍ ។ រាល់ព័ត៌មានអត្តសញ្ញាណ ត្រូវបានដកចេញពីរបាយការណ៍ ហើយឈ្មោះត្រូវបានប្តូរ នៅគ្រប់ករណីសិក្សា ដើម្បីធានាឯកជនភាព និងការការពារអ្នកចូលរួមពីការធ្វើទុក្ខបុកម្នេញផ្សេងៗដែលអាចកើតមានឡើង ។

## ដែនកំណត់

ការរកឃើញនេះ មិនមែនជាឧទាហរណ៍តំណាងឱ្យបទពិសោធន៍របស់មនុស្សគ្រប់គ្នានៅក្នុងប្រទេសកម្ពុជាទេ ។

កុមារអាយុក្រោម១៨ឆ្នាំ ភាគច្រើនមិនត្រូវបានដាក់បញ្ចូលនៅក្នុងការស្រាវជ្រាវទេ ទោះបីជាពួកគេទំនងជាកំពុងស្ថិតក្នុងហានិភ័យខ្ពស់នៃការបៀតបៀនតាមប្រព័ន្ធអនឡាញ ដោយសារបញ្ហាប្រឈមក្នុងការទទួលបានទម្រង់ព្រមព្រៀងពីឪពុកម្តាយឬអាណាព្យាបាលរបស់ពួកគេ មុនពេលកុមារចូលរួមការស្ទង់មតិនេះ ។ បញ្ហាប្រឈមទាំងនេះ កាន់តែពិបាកថែមទៀតដោយសារការទប់ស្កាត់ជំងឺកូវីដ-១៩ ដែលមិនអាចឱ្យអង្គការលីកាដូជួបប្រជុំជាមួយក្រុមកុមារ និងឪពុកម្តាយឬអាណាព្យាបាលរបស់ពួកគេដោយផ្ទាល់ ។ ការស្រាវជ្រាវបន្ថែមទៀត គឺមានភាពចាំបាច់ ដើម្បីសិក្សាពីបទពិសោធន៍របស់កុមារពាក់ព័ន្ធនឹងការបៀតបៀនតាមប្រព័ន្ធអនឡាញនៅកម្ពុជា ។

ការស្ទង់មតិ អាចចូលប្រើប្រាស់បានដោយមនុស្សដែលមានកម្រិតអក្ខរកម្មខ្ពស់ និងអាចប្រើប្រាស់អ៊ីនធឺណិត តាមរយៈឧបករណ៍ដូចជាទូរស័ព្ទ ឬកុំព្យូទ័រយួរដៃ តែប៉ុណ្ណោះ ។ នេះទំនងជាចំណែកនៃការចូលរួមច្រើនលើសលប់នៃមនុស្សដែលរស់នៅក្នុងទីក្រុង ក្នុងចំណោមអ្នកឆ្លើយតបនៅក្នុងការស្ទង់មតិនេះ ។ ក្រុមដែលមិនអាចចូលរួមស្ទង់មតិនេះ ក៏ទំនងជាប្រឈមនឹងការបៀតបៀនតាមប្រព័ន្ធអនឡាញផងដែរ ហើយការស្រាវជ្រាវបន្ថែមទៀតដោយប្រើប្រាស់វិធីសាស្ត្រផ្សេងៗទៀត នឹងបំពេញបន្ថែម ទៅលើការយល់ដឹងពីការបៀតបៀនតាមប្រព័ន្ធអនឡាញនៅក្នុងប្រទេសកម្ពុជា ។

## នរណាខ្លះបានចូលរួមស្ទង់មតិ?

ក្នុងចំណោមអ្នកឆ្លើយតបក្នុងការស្ទង់មតិចំនួន ៧១៨នាក់ ភាគច្រើននៃពួកគេគឺជាស្ត្រី ដែលរស់នៅក្នុងទីក្រុង និងទីប្រជុំជន (សូមមើលតួលេខទី ២ និងទី៣) ។ អ្នកឆ្លើយតបមានអាយុចាប់ពី ១៨ឆ្នាំ ដល់ ៦០ឆ្នាំ ហើយភាគច្រើនមានអាយុ ២០ជាង និង៣០ជាង (សូមមើលតួលេខទី៤) ។ អ្នកឆ្លើយតបបានរាយការណ៍ពីមុខរបរ ឬការងារជាង ២០ប្រភេទ ដោយភាគច្រើនមានមុខរបរច្រើនជាងមួយ (សូមមើលតារាងទី១) ។ ២០%នៃពួកគេ គឺជាសកម្មជន រួមមានអ្នកដែលបានកំណត់អត្តសញ្ញាណខ្លួនឯងថាជា អ្នកការពារសិទ្ធិមនុស្ស អ្នកដឹកនាំសហជីព អ្នកដឹកនាំក្នុងសង្គមស៊ីវិល សកម្មជនដីធ្លី សកម្មជនបរិស្ថាន និង/ឬសកម្មជននយោបាយ (តួលេខទី៥) ។ ៩%នៃអ្នកឆ្លើយតបកំណត់អត្តសញ្ញាណថាជា អ្នកស្រឡាញ់ភេទដូចគ្នា ។

### តួលេខទី១៖ សេចក្ដីសង្ខេបនៃអ្នកចូលរួមស្ទង់មតិ




*អ្នកឆ្លើយតបម្នាក់អាចស្ថិតនៅក្នុងក្រុមច្រើន*

### តួលេខទី២ ៖ អ្នកចូលរួមស្ទង់មតិផ្អែកតាមយេនឌ័រ




### តួលេខទី៣៖ អ្នកចូលរួមស្ទង់មតិផ្អែកតាមតំបន់




*ចំនួនសរុបលើសពី១០០% ដោយសារការបង្គត់លេខ*

### តួលេខទី៤ ៖ ក្រុមអាយុរបស់អ្នកឆ្លើយតបក្នុងការស្ទង់មតិ




*អ្នកឆ្លើយតបផ្សេងទៀតមិនបានឆ្លើយសំណួរនេះទេ*

**តួលេខទី៥៖ អ្នកឆ្លើយតបក្នុងការស្ទង់មតិតាមប្រភេទនៃសកម្មជន**

**៨០**
អ្នកការពារសិទ្ធិមនុស្ស

**៤១**
អ្នកដឹកនាំសហជីព

**១៨**
អ្នកដឹកនាំក្នុងសង្គមស៊ីវិល

**១២**
សកម្មជនដីធ្លី

**១០**
សកម្មជនបរិស្ថាន

**២**
សកម្មជននយោបាយ

*អ្នកឆ្លើយតបម្នាក់អាចស្ថិតនៅក្នុងក្រុមច្រើន*

**តារាងទី១៖ មុខរបរដែលត្រូវបានរាយការណ៍ច្រើនជាងគេរបស់អ្នកឆ្លើយតប ក្នុងការស្ទង់មតិ**

| មុខរបរ | ចំនួនអ្នកឆ្លើយតប | ភាគរយនៃអ្នកឆ្លើយតប |
|---|---|---|
| ក្រុមហ៊ុនឯកជន | ៤៣០ | ៦០% |
| សិស្ស ឬនិស្សិត | ១០៣ | ១៤% |
| បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល | ៧១ | ១០% |
| កម្មករ កម្មការិនីរោងចក្រ | ២៨ | ៤% |
| អ្នកបើកបរ | ២៧ | ៤% |
| មេផ្ទះ អាណាព្យាបាល ឬ ឪពុកម្តាយ | ២៣ | ៣% |
| អាហារ ឬសេវាកម្ម | ២០ | ៣% |
| កសិករ ឬធ្វើកសិកម្ម | ១៩ | ៣% |
| អ្នកលក់ដូរ | ១៦ | ២% |
| គ្រូបង្រៀន | ១២ | ២% |
| អ្នកបម្រើសេវាកម្សាន្ត ឬអ្នករកស៊ីផ្លូវភេទ | ៩ | ១% |
| អ្នកធ្វើការតាមផ្ទះ | ៩ | ១% |
| អ្នកលក់ដូរតាមអនឡាញ | ៨ | ១% |
| មន្ត្រីរាជការ ឬរាជរដ្ឋាភិបាល | ៨ | ១% |
| មន្ត្រីរាជការ ឬរាជរដ្ឋាភិបាល | ៨ | ១% |
| អ្នកឥតការងារធ្វើ | ៨ | ១% |
| វិស័យទេសចរណ៍ | ៥ | <១% |
| អ្នកសារព័ត៌មាន | ៥ | <១% |
| កម្មករសំណង់ | ៤ | <១% |
| ផ្សេងៗ | ៣៥ | ៥% |

*អ្នកឆ្លើយតបម្នាក់អាចមានមុខរបរច្រើន*

**តួលេខទី៦៖ ក្រុមអ្នកស្រឡាញ់ភេទដូចគ្នាដែលឆ្លើយតបក្នុងការស្ទង់មតិ ដោយគិតតាមនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ**



## ប្រព័ន្ធផ្សព្វផ្សាយសង្គមគឺមានសារៈសំខាន់សម្រាប់ជីវិតរស់នៅរបស់មនុស្ស

ជារឿយៗ មនុស្សប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម ក្នុងគោលបំណងច្រើន ដែលធ្វើឱ្យប៉ះពាល់ជាខ្លាំងចំពោះការចាកចេញ ឬឈប់ប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម ដោយសារការបៀតបៀនតាមប្រព័ន្ធអនឡាញ ។ ជិតមួយភាគបីនៃអ្នកឆ្លើយតប តែងបង្ហោះសារ ឬចែករំលែកមាតិកា ជារឿយៗ (សូមមើលតួលេខទី៧) ។[១១]

ស្ទើរតែគ្រប់អ្នកឆ្លើយតបទាំងអស់រាយការណ៍ថា តែងប្រើប្រាស់ជាទៀងទាត់នូវកម្មវិធីហ្វេសប៊ុក កម្មវិធីឆាត និងកម្មវិធីថេលេក្រាម ប៉ុន្តែកម្មវិធីផ្សេងទៀតក៏ពេញនិយមផងដែរ ។ អ្នកឆ្លើយតបមួយចំនួនតូចរាយការណ៍ថា ពួកគេលេងកម្មវិធីល្បែងកម្សាន្តជាទៀងទាត់ដូចជា Mobile Legends: Bang Bang និង PUBG ឬប្រើប្រាស់កម្មវិធីណាត់ជួបដូចជា Tinder ឬ Grindr ។ ជាពិសេសយុវជនបានរាយការណ៍ពីសារៈសំខាន់នៃប្រព័ន្ធផ្សព្វផ្សាយសង្គម (សូមមើលតួលេខទី៨ និងទី៩)។

**តួលេខទី៧៖ អ្នកចូលរួមស្ទង់មតិ ផ្អែកលើភាពញឹកញាប់នៃការបង្ហោះ ឬចែករំលែកមាតិកាលើប្រព័ន្ធផ្សព្វផ្សាយសង្គម**






[១១] នៅក្នុងការស្ទង់មតិទាំងមូល អ្នកឆ្លើយតបអាចយល់អត្ថន័យពាក្យគន្លឹះដោយខ្លួនឯងដូចជា "ញឹកញាប់" "ម្តងម្កាល" និង"មិនធ្លាប់" ដើម្បីឆ្លុះបញ្ចាំងពីអ្វីដែលពួកគេយល់ថាមានសារៈសំខាន់ ។

### តួលេខទី៨៖ អ្នកចូលរួមស្ទង់មតិ ផ្អែកលើការប្រើប្រាស់ជាទៀងទាត់នៃកម្មវិធីប្រព័ន្ធផ្សព្វផ្សាយសង្គម




*អនុញ្ញាតឱ្យមានចម្លើយច្រើន ការឆ្លើយសំណួរមិនមែនជាកាតព្វកិច្ចទេ*

៨១%នៃអ្នកឆ្លើយតបបានរាយការណ៍ថា ពួកគេប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមក្នុងគោលបំណងច្រើនលើសពីមួយ ។ គោលបំណងទូទៅជាងគេគឺ ដើម្បីទទួលបានព័ត៌មាន ឬអានព័ត៌មាន ជាពិសេសសម្រាប់យុវជន ។ ករណីនេះគឺមានសារៈសំខាន់ខ្លាំង ដោយសារតែការរឹតត្បិតលំហសេរីភាពសារព័ត៌មាន និងការគ្រប់គ្រងទាំងស្រុងរបស់រាជរដ្ឋាភិបាលទៅលើប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណីដូចជាកាសែត និងទូរទស្សន៍[១៧] ជាដើម ។ គោលបំណងទូទៅផ្សេងទៀតក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមគឺ ដើម្បីរក្សាទំនាក់ទំនងជាមួយមិត្តភក្តិ និងគ្រួសារ និងដើម្បីសាលារៀន សាកលវិទ្យាល័យ ឬការងារ (សូមមើលតួលេខទី៩) ។ ៣៦%នៃអ្នកឆ្លើយតបប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម ដើម្បីសម្តែងមតិអំពីអ្វីដែលមានសារៈសំខាន់សម្រាប់ពួកគេ ប៉ុន្តែបុរស៤៨%ធ្វើដូច្នេះ បើប្រៀបធៀបទៅនឹងស្ត្រីគឺមានតែ ៣០%ប៉ុណ្ណោះ ។ អ្នកឆ្លើយតបក៏បានរាយការណ៍ថា ពួកគេប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម ដើម្បីធ្វើសកម្មភាពផ្នែកសេដ្ឋកិច្ចដូចជា ទិញ និងលក់ និងផ្សព្វផ្សាយផលិតផល ឬសេវាកម្មផ្សេងៗ ។

**តួលេខទី៩៖ អ្នកចូលរួមស្ទង់មតិ ដោយផ្អែកលើហេតុផលនៃការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម**




*អនុញ្ញាតឱ្យមានចម្លើយច្រើន ការឆ្លើយសំណួរមិនមែនជាកាតព្វកិច្ចទេ*

[១៧] កម្ពុជាជាប់ចំណាត់ថ្នាក់លេខ ១៤៤ ក្នុងចំណោម១៨០ប្រទេសនៅក្នុង "សន្ទស្សន៍សេរីភាពសារព័ត៌មានពិភពលោកឆ្នាំ២០២១" ដោយ Reporters Without Borders ដកស្រង់ពី៖ https://rsf.org/en/cambodia ។ សូមមើល៖ "របាយការណ៍ស្តីពី ស្ថានភាពសារព័ត៌មានកម្ពុជាឆ្នាំ២០២០" ដោយ សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា ចេញផ្សាយឆ្នាំ២០២១ ដកស្រង់ពី៖ https://www.camboja.net/wp-content/uploads/2021/03/Cambodian-Journalism-Situation-Report-2020.pdf

"ខ្ញុំប្រើបណ្ដាញសង្គម ព្រោះវាជាការចែករំលែកព័ត៌មានពីយើងទៅអ្នកដទៃ និងដឹងព័ត៌មានពីក្រៅមកវិញ" ។

បុរសម្នាក់អាយុជាង ៣០ឆ្នាំ

"មូលហេតុដែលខ្ញុំប្រើប្រាស់បណ្ដាញសង្គមគឺខ្ញុំចង់ឃើញពីសង្គមខាងក្រៅ...ដោយសារតែខ្ញុំត្រូវការស្រាវជ្រាវក្នុងការសិក្សា។ដោយសារតែឥឡូវមានតែរឿងកូវីដចឹងព័ត៌មានដែលខ្ញុំផុសគឺមានតែទាក់ទងជាមួយនឹងការការពារជាមួយនឹងកូវីដ" ។

ស្ត្រីម្នាក់អាយុជាង ២០ឆ្នាំ

"ខ្ញុំធ្វើការនៅកាស៊ីណូពីមុន ប៉ុន្តែគេបិទដោយសារកូវីដ តាំងពីខែកុម្ភៈ ។ ឥឡូវខ្ញុំលក់អនឡាញ ដូចជា កាបូប ស្បែកជើង ខោអាវ" ។

ស្ត្រីម្នាក់អាយុជាង ២០ឆ្នាំ

"ខ្ញុំប្រើវាដើម្បីចែកចាយព័ត៌មានឱ្យសាធារណជន និងបងប្អូននៅក្នុងសង្គម ឱ្យដឹងឮពីបញ្ហាកើតមានឡើងនៅក្នុងតំបន់នេះ...បញ្ហាដែលកើតមានឡើងនៅក្នុងសហគមន៍យើងខ្ញុំមានដូចជា បញ្ហាដីធ្លី ការរំលោភសិទ្ធិមនុស្ស ការកាប់បំផ្លាញព្រៃឈើ ការរឹតត្បិតសិទ្ធិសេរីភាព..." ។

បុរសម្នាក់អាយុជាង ២០ឆ្នាំ

"សម័យអនឡាញហ្នឹង ជីវិតផ្ញើខ្លួនទៅលើបណ្ដាញសង្គមហ្នឹងតែម្ដង ទាំងរៀននៅសាលា ទាំងរៀនជាមួយអង្គការអីផ្សេងៗគឺគេធ្វើអនឡាញទាំងអស់" ។

បុរសម្នាក់អាយុជាង ២០ឆ្នាំ

"អ្វីដែលខ្ញុំចូលចិត្តប្រើជាងគេគឺហ្វេសប៊ុក...ខ្ញុំប្រើវាជាមួយមិត្តភក្តិជិតស្និទ្ធ និងគ្រួសារ...ភាគច្រើនខ្ញុំផុសពាក់ព័ន្ធជាមួយការងារខ្ញុំ គឺដោយសារតែខ្ញុំមានសរសេរប្លុក Blog" ។

ស្ត្រីម្នាក់អាយុជាង ៣០ឆ្នាំ

"ខ្ញុំប្រើវាទំនាក់ទំនងជាមួយមិត្តភក្តិនៅក្រៅប្រទេស ហើយយើងចង់ធ្វើ Business Online អ៊ីចឹង ដូចជាលក់ឡេ គ្រឿងលើមុខ ទើបតែចាប់ផ្ដើម" ។

ស្ត្រីម្នាក់អាយុជាង ៣០ឆ្នាំ

"ពេលឃើញអំពីបញ្ហា ខ្ញុំចូលចិត្តចែករំលែក" ។

ស្ត្រីម្នាក់អាយុជាង ២០ឆ្នាំ

## ការបៀតបៀនតាមប្រព័ន្ធអនឡាញកើតមានញឹកញាប់

**តួលេខទី១០៖ ភាគរយនៃក្រុមស្ទង់មតិនីមួយៗ ដែលធ្លាប់ត្រូវបានបៀតបៀនតាមប្រព័ន្ធអនឡាញ**




ក្នុងចំណោមអ្នកចូលរួមស្ទង់មតិ ដែលធ្លាប់ត្រូវបានបៀតបៀនតាមប្រព័ន្ធអនឡាញ ៦៧%នៃពួកគេបានរាយការណ៍ថា បានប្រឈមមុខនឹងការបៀតបៀនលើសពីម្តង ហើយ៤០%ត្រូវបានបៀតបៀនតាមគេហទំព័រ ឬកម្មវិធីជាច្រើន ។ ៣៨%នៃអ្នកដែលធ្លាប់ត្រូវបានបៀតបៀនតាមប្រព័ន្ធអនឡាញ បានជួបប្រឈមនឹងការបៀតបៀនដំបូងក្នុងរយៈពេល ២ឆ្នាំចុងក្រោយ មានន័យថា ការបៀតបៀនតាមប្រព័ន្ធអនឡាញគឺជាបញ្ហាមួយដែលកំពុងកើនឡើង ។ ការទទួលសារជាអក្សរ រូបភាព ឬវីដេអូ ឬសំណើបែបផ្លូវភេទ ដែលពុំបានស្នើសុំ គឺជាប្រភេទនៃការបៀតបៀនតាមប្រព័ន្ធអនឡាញច្រើនជាងគេ ដែលត្រូវបានរាយការណ៍ ។ ប្រភេទនៃការបៀតបៀនដែលកើតមានញឹកញាប់ជាងគេបន្ទាប់មានដូចជា ការលួចចូលប្រើប្រាស់ ឬការប្រើប្រាស់គណនីដោយគ្មានការអនុញ្ញាត ការរើសអើង និងការធ្វើឱ្យខ្មាសគេដោយចេតនា ( សូមមើលតួលេខទី១១ និងឧបសម្ព័ន្ធទី១ សម្រាប់ការបែងចែកប្រភេទនៃការបៀតបៀនតាមប្រព័ន្ធអនឡាញ ដែលត្រូវបានរាយការណ៍ដោយអ្នកចូលរួមស្ទង់មតិ) ។

**តួលេខ១១៖ ភាគរយនៃអ្នកចូលរួមស្ទង់មតិ ដែលធ្លាប់ត្រូវបានបៀតបៀនតាមប្រព័ន្ធអនឡាញតាមប្រភេទខុសៗគ្នា**




*អនុញ្ញាតឱ្យមានចម្លើយច្រើន ការឆ្លើយសំណួរមិនមែនជាកាតព្វកិច្ចទេ*

**តួលេខទី១២៖ ភាគរយនៃក្រុមស្ទង់មតិនីមួយៗដែលបានរងការគំរាមកំហែងតាមប្រព័ន្ធអនឡាញ**




ក្នុងចំណោមអ្នកឆ្លើយតបចំនួន ៣០នាក់ ដែលបានរាយការណ៍ថា ត្រូវបានគំរាមកំហែងតាមប្រព័ន្ធអនឡាញក្នុងនោះមាន១៩នាក់បានរាយការណ៍ថា បានរងការគំរាមកំហែងច្រើនជាងម្តង ។ ពួកគេបានរាយការណ៍ពីការគំរាមសម្លាប់ ការគំរាមប្រើប្រាស់អំពើហិង្សាលើរូបរាងកាយ និងហិង្សាផ្លូវភេទ ការគំរាមកំហែងផ្នែកសេដ្ឋកិច្ច និងការគំរាមកំហែងផ្សេងទៀត (សូមមើលតារាងទី២) ។ សកម្មជនបានរាយការណ៍ថា បានរងការគំរាមកំហែងញឹកញាប់ជាងអ្នកចូលរួមស្ទង់មតិផ្សេងៗទៀត (សូមមើលតួលេខទី១២) ។ ការស្រាវជ្រាវនេះ មិនបានសួរសំណួរជាក់លាក់អំពីការបោកបញ្ឆោតតាមប្រព័ន្ធអនឡាញទេ ប៉ុន្តែករណីនេះត្រូវបានលើកឡើងជាការព្រួយបារម្ភដោយអ្នកចូលរួមស្ទង់មតិចំនួន ១១នាក់ និងអ្នកផ្តល់បទសម្ភាសន៍ពីរនាក់ ។

៥៤%នៃអ្នកឆ្លើយតបទាំងអស់ បានរាយការណ៍ថា បានឃើញមនុស្សផ្សេងទៀត ត្រូវបានបៀតបៀនតាមប្រព័ន្ធអនឡាញ ។ ក្នុងចំណោមនេះ ពួកគេចំនួន ៨៦% បានឃើញស្រ្តីធ្លាប់ទទួលរងការបៀតបៀនតាមប្រព័ន្ធអនឡាញ ហើយ២៦% បានឃើញបុរសធ្លាប់ទទួលរងការបៀតបៀនតាមប្រព័ន្ធអនឡាញ ដោយមានអ្នកឆ្លើយតបខ្លះបានឃើញមនុស្សជាច្រើនទទួលរងការបៀតបៀនតាមប្រព័ន្ធអនឡាញ ។ យុវជនមានអត្រាខ្ពស់ជាងគេ (៦៣%) ដែលត្រូវបានរាយការណ៍ពីការប្រទះឃើញ អ្នកដទៃត្រូវបានបៀតបៀនតាមប្រព័ន្ធអនឡាញ ។

ខណៈដែលការស្រាវជ្រាវបន្ថែមទៀតគឺជាការចាំបាច់ ដើម្បីសិក្សាពីបទពិសោធន៍របស់កុមារពាក់ព័ន្ធនឹងការបៀតបៀនតាមប្រព័ន្ធអនឡាញ អ្នកឆ្លើយតបខ្លះដែលមានអាយុចន្លោះពី ២០ឆ្នាំ ទៅ ២៤ឆ្នាំ បានរាយការណ៍ថា ពួកគេធ្លាប់ត្រូវបានបៀតបៀនតាមប្រព័ន្ធអនឡាញដំបូង រហូតដល់១០ឆ្នាំមុន (ពេលដែលពួកគេទើបតែមានអាយុពី ១០ឆ្នាំទៅ១៤ឆ្នាំ) ។ អ្នកឆ្លើយតបខ្លះ ដែលមានអាយុចន្លោះពី ១៨ឆ្នាំ ទៅ ១៩ឆ្នាំ បានរាយការណ៍ពីការបៀតបៀនតាមប្រព័ន្ធអនឡាញ នៅរយៈពេល៤ឆ្នាំចុងក្រោយ (ពេលដែលពួកគេទើបតែមានអាយុពី ១៤ឆ្នាំ ទៅ ១៥ឆ្នាំ) ។

**តារាងទី២៖ ចំនួនអ្នកចូលរួមស្ទង់មតិ ដែលត្រូវបានគំរាមកំហែងតាមប្រព័ន្ធអនឡាញតាមប្រភេទខុសៗគ្នា**

| ប្រភេទនៃការគំរាមកំហែង | ចំនួនអ្នកឆ្លើយតប | | |
|---|---|---|---|
| | ស្រ្តី | បុរស | សរុប |
| ការគំរាមសម្លាប់ | ៤ | ៦ | ១០ |
| ការគំរាមប្រើអំពើហិង្សាលើរូបរាងកាយ | ២ | ៦ | ៨ |
| ការគំរាមប្រើហិង្សាផ្លូវភេទ | ២ | ០ | ២ |
| ការគំរាមកំហែងផ្នែកសេដ្ឋកិច្ច | ៣ | ៦ | ៩ |
| ការគំរាមកំហែងផ្សេងៗទៀត | ៩ | ៣ | ១២ |

*មនុស្សម្នាក់អាចរាយការណ៍ពីការគំរាមកំហែងច្រើនប្រភេទ*



## កម្មវិធីដែលជាកម្មសិទ្ធិរបស់ក្រុមហ៊ុនហ្វេសប៊ុក គឺជាកម្មវិធីចម្បងគេ ដែលកើតមានការបៀតបៀនតាមប្រព័ន្ធអនឡាញ

៩៥%នៃអ្នកឆ្លើយតបក្នុងការស្ទង់មតិ ដែលបានរាយការណ៍ពីការបៀតបៀនតាមប្រព័ន្ធអនឡាញ ត្រូវបានបៀតបៀនតាមរយៈសេវាកម្មក្រុមហ៊ុនហ្វេសប៊ុកយ៉ាងតិចមួយរួមមាន ហ្វេសប៊ុក ឆាត អ៊ីនស្តាក្រាម និងវតសន៍អាប់ ។

មនុស្សជាច្រើនបានរាយការណ៍ថា ធ្លាប់ទទួលរងការបៀតបៀនតាមប្រព័ន្ធអនឡាញតាមរយៈគេហទំព័រ ឬកម្មវិធីលើសពីមួយ ។ កម្មវិធីដែលត្រូវបានរាយការណ៍ច្រើនជាងគេពីការបៀតបៀនតាមប្រព័ន្ធអនឡាញគឺ ហ្វេសប៊ុក និងកម្មវិធីឆាត និងបន្ទាប់មកគឺ កម្មវិធីថេលេក្រាម ។ ភាគរយតិចតួចប៉ុណ្ណោះចំពោះអ្នកឆ្លើយតបដែលបានរាយការណ៍ពីការបៀតបៀនតាមប្រព័ន្ធអនឡាញតាមរយៈកម្មវិធី Mobile Legends: Bang Bang អ៊ីនស្តាក្រាម និងវតសន៍អាប់ ក្នុងចំណោមកម្មវិធីផ្សេងទៀត (សូមមើលតារាងទី៣) ។



**តារាងទី៣៖ ចំនួនអ្នកចូលរួមស្ទង់មតិ ដែលបានទទួលរងការបៀតបៀនតាមប្រព័ន្ធអនឡាញនៅលើកម្មវិធីប្រព័ន្ធផ្សព្វផ្សាយសង្គមខុសៗគ្នា**

| កម្មវិធី | ចំនួនអ្នកឆ្លើយតប | ភាគរយនៃអ្នកឆ្លើយតបដែលត្រូវបានបៀតបៀនតាមប្រព័ន្ធអនឡាញ |
|---|---|---|
| ហ្វេសប៊ុក (Facebook) | ២២១ | ៨១% |
| ឆាត (Messenger) | ១៩៦ | ៧២% |
| ថេលេក្រាម (Telegram) | ៥៨ | ២១% |
| ម៉ូបាល លីជេនបេងៗ (Mobile Legends: Bang Bang) | ២៦ | ១០% |
| អ៊ីនស្តាក្រាម (Instagram) | ២១ | ៨% |
| វតសន៍អាប់ (WhatsApp) | ២១ | ៨% |
| អ៊ីម៉ែល (Email) | ១៩ | ៧% |
| ផាប់ជី (PUBG) | ១៧ | ៦% |
| ធីនឌ័រ (Tinder) | ១៥ | ៥% |
| ហ្សូម (Zoom) ស្កេប (Skype) ជីតស៊ី (Jitsi) ។ល។ | ១២ | ៤% |
| ធីកថុក (TikTok) | ៥ | ២% |
| យូធ្យូប (YouTube) | ៥ | ២% |
| ហ្គ្រីនឌ័រ (Grindr) | ៥ | ២% |
| គេហទំព័រសម្រាប់ពិភាក្សា ឬវេទិកា | ៣ | ១% |
| វីឆាត (WeChat) | ៣ | ១% |
| ធ្វីតទ័រ (Twitter) | ១ | <១% |

*មនុស្សម្នាក់អាចរាយការណ៍ពីការគំរាមកំហែងច្រើនប្រភេទ*

> **“ គាត់ថតវីដេអូ...និយាយទៅខ្ញុំស្មានថាគាត់បើក flash ទូរស័ព្ទ...ប៉ុន្តែបើថាថតវីដេអូខ្ញុំអត់មានថាឱ្យគាត់ថតទេ... ពួកម៉ាកអ្នកស្គាល់គ្នាគេថាឃើញ អាខោនហ្វេសប៊ុកខ្ញុំផ្ញើវីដេអូរូបខ្លួនឯងឱ្យគេមើល ”**

សុផល[១៨] ជាក្មេងស្រី អាយុ ១៦ឆ្នាំ ដែលកំពុងសិក្សាថ្នាក់ទី៩ បានជួបការបៀតបៀនធ្ងន់ធ្ងរតាមកម្មវិធីហ្វេសប៊ុក បន្ទាប់ពីបុរសអាយុ ២៤ឆ្នាំម្នាក់ បានថតវីដេអូខ្លួនគេជាមួយ សុផល ដែលកំពុងរួមភេទ ។ សុផល បានយល់ព្រមក្នុងការរួមភេទ ប៉ុន្តែនាងត្រូវបានថតជាវីដេអូ ដោយពុំដឹងខ្លួន ឬការយល់ព្រមពីនាងឡើយ ។[១៩]

នៅពេល សុផល បដិសេធសំណើបុរសនោះក្នុងការជួបគ្នាម្តងទៀត បុរសនោះក៏បានបង្ហោះវីដេអូពួកគេទាំងពីរនាក់លើគណនីហ្វេសប៊ុករបស់គេ និងលើគណនីរបស់សុផល ។ នាងមិនបានដឹងនោះទេថាបុរសនោះចូលប្រើប្រាស់គណនីរបស់នាងដោយរបៀបណា ប៉ុន្តែវីដេអូនោះត្រូវបានផ្ញើទៅកាន់មិត្តភក្តិរបស់នាង បង្ហោះនៅក្នុងក្រុមផ្ញើសារជាសាធារណៈឈ្មោះដូចជា “18+” និងបានចែកចាយលើហ្វេសប៊ុក ។ នាងបានដឹងនៅពេលមិត្តភក្តិរបស់នាងចាប់ផ្តើមហៅទូរស័ព្ទមកនាង ។ នាងបាននិយាយថា “គេថាខ្ញុំហ្នឹងអាក្រក់ម៉េះ បានផ្ញើរូបអាសអាភាសឱ្យគេមើល” ។ នាងបានបន្ថែមថា “ខ្ញុំមានអារម្មណ៍ថាភ័យ ព្រោះខ្លាចពួដល់ម៉ាក់” ។

វីដេអូ ត្រូវបានចែកចាយយ៉ាងទូលំទូលាយ ហើយម្តាយសុផលត្រូវបានអ្នកជិតខាងប្រាប់ពីរឿងកូនស្រី ។ គ្រួសារនាងបានទៅជួបនគរបាល ។ ដោយមានវត្តមានរបស់នគរបាល គ្រួសាររបស់ជនល្មើសបានស្នើសុំម្តងហើយម្តងទៀតឱ្យ សុផល និងបុរសអាយុ ២៤ឆ្នាំនោះ រៀបការនឹងគ្នា ។ សុផល និងគ្រួសារ បានបដិសេធសំណើនោះ ។ នគរបាលបានដឹងថា បុរសនោះធ្លាប់បានប្រព្រឹត្តបទល្មើសដូចគ្នាកាលពីមុន ដោយកាលនោះគឺជាលើកទីមួយដែលបុរសនោះបានរៀបការជាមួយស្ត្រីម្នាក់ មុនពេលពួកគេលែងលះគ្នាវិញ ។

ជនល្មើសត្រូវបានកាត់ទោសដោយកំបាំងមុខ និងត្រូវបានរកឃើញថាមានពិរុទ្ធនៃការរំលោភឯកជនភាព (ការថតរូបភាពនៃបុគ្គល) ។[២០] ជនល្មើសត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគារកំណត់រយៈពេល ១ឆ្នាំ និងបង្គាប់ឱ្យសងសំណងជំងឺចិត្តចំនួន ២០លានរៀល ។ ជនល្មើសមិនត្រូវបានឃុំខ្លួននៅដំណាក់កាលណាមួយ ឬបានបង់សំណងជំងឺចិត្តដែលត្រូវបានបង្គាប់ទេ ។ ការដាក់ទោសគឺស្រាល បើប្រៀបធៀបទៅនឹងបទចោទផ្សេងទៀត ដែលគួរត្រូវបានចោទប្រកាន់ដូចជា ការផលិត និងចែកចាយរូបភាពអាសអាភាសនៃកុមារ ដែលមានការដាក់ទោសជាប់ពន្ធនាគារពី ១០ ទៅ២០ឆ្នាំ ។[២១] សុផលបាននិយាយថា “ខ្ញុំមានអារម្មណ៍ថាភ័យខ្លាច ព្រោះពេលយើងទៅណាទៅណីអី ខ្លាចតែជួបគាត់ម្តងទៀត...ព្រោះសូម្បីតែមុខគាត់ក៏ខ្ញុំអត់ហ៊ានមើលដែរ” ។

ការបៀតបៀនតាមប្រព័ន្ធអនឡាញនេះ បាននាំឱ្យមានការសម្រេចចិត្តថ្មីៗរបស់សុផល ដើម្បីប្តូរសាលារៀន ជាកន្លែងមិត្តភក្តិថ្មីរបស់នាង មិនដឹងពីវីដេអូនោះ ។ សុផល ក៏ទទួលរងប្រតិកម្មយ៉ាងខ្លាំងពីសហគមន៍របស់នាង ។ នាងបានរៀបរាប់ថា “អ្នកខ្លះគេថាខ្លួនស្រីហ្មេ ដើរលេងអ៊ីចឹងអីអ៊ីចឹង បានតែខ្មាសគេអត់ប្រយោជន៍ ។ ពេលដើរកាត់ផ្ទះគេអ៊ីចឹង ខ្ញុំដើរធ្វើធម្មតាទោះបីគេនិយាយអីក៏ដោយ” ។

សុផល យល់ថា ដំណើរការក្នុងការរាយការណ៍អំពីវីដេអូនាងទៅកាន់ក្រុមហ៊ុនហ្វេសប៊ុក គឺគួរឱ្យកាន់ច្រឡំ ហើយនាងមិនដឹងថាវីដេអូនោះនៅតែត្រូវបានចែករំលែកលើប្រព័ន្ធអនឡាញឬយ៉ាងណាទេ ទោះបីជានាងមិនបានឃើញវាថ្មីៗនេះក៏ដោយ ។ ពេលនេះ សុផល ប្រើប្រាស់គណនីហ្វេសប៊ុកមួយទៀតដោយប្រុងប្រយ័ត្ន ។

នៅពេលត្រូវបានសួរថា តើលទ្ធផលរឿងក្តីរបស់នាងយុត្តិធម៌ឬទេ? សុផលបានឆ្លើយថា “នៅទេ ព្រោះរឿងហ្នឹងអត់ទាន់ចាប់គេបាន ហើយរឿងសងសំណងក៏អត់ទាន់មានដែរ” ។ សុផលនៅតែមានសង្ឃឹមនៅថ្ងៃអនាគត ។ នាងកំពុងរង់ចាំបើកហាងកែសម្ផស្សផ្ទាល់ខ្លួនមួយ បន្ទាប់ពីរៀនចប់ពីសាលា ។

---

[១៨] ឈ្មោះត្រូវបានប្តូរ ដើម្បីធានាឯកជនភាព និងការការពារអ្នកចូលរួម ពីការធ្វើទុក្ខបុកម្នេញដែលអាចកើតមានឡើង ។

[១៩] នីតិភាពនៃការរួមភេទនៅកម្ពុជាត្រូវបានកំណត់ អាយុចាប់ពី ១៥ឆ្នាំ ឡើងទៅ ។ មាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ ។

[២០] មាត្រា៣០២ នៃក្រមព្រហ្មទណ្ឌ ។

[២១] មាត្រា៤០ និងមាត្រា៤១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

**តួលេខទី១៣៖ ភាគរយនៃអ្នកចូលរួមស្ទង់មតិ ដែលធ្លាប់ទទួលរងការបៀតបៀនតាមប្រព័ន្ធអនឡាញដែលជឿជាក់ថា ការបៀតបៀនទាក់ទងនឹងជំនឿ រូបរាងខាងក្រៅ និង/អត្តសញ្ញាណរបស់ពួកគេ**




*អនុញ្ញាតឱ្យមានចម្លើយច្រើន ការឆ្លើយសំណួរមិនមែនជាកាតព្វកិច្ចទេ*

ក្រុមទាំងអស់បានរាយការណ៍ពីអត្រាខ្ពស់នៃការបៀតបៀនតាមប្រព័ន្ធអនឡាញ ពាក់ព័ន្ធនឹងការយល់ឃើញ ឬគំនិតយោបល់របស់ពួកគេ ។ កត្តាចម្បងដែលនាំឱ្យអ្នកឆ្លើយតបជាបុរស និងជាសកម្មជន ទទួលរងការបៀតបៀនតាមប្រព័ន្ធអនឡាញ គឺការយល់ឃើញ ឬគំនិតយោបល់ និងទំនាក់ទំនងផ្នែកនយោបាយរបស់ពួកគេ ។ កត្តាចម្បងដែលនាំឱ្យស្ត្រីទទួលរងការបៀតបៀនតាមប្រព័ន្ធអនឡាញគឺ ពណ៌សម្បុរ ឬរូបរាងខាងក្រៅរបស់ពួកគេ ។[២២] ក្រុមអ្នកស្រឡាញ់ភេទដូចគ្នាភាគច្រើន រាយការណ៍ពីការបៀតបៀនតាមប្រព័ន្ធអនឡាញ ដោយសារតែយេនឌ័រ ឬការបង្ហាញយេនឌ័ររបស់ពួកគេ និងមួយភាគបួនមានអារម្មណ៍ថា ការបៀតបៀនតាមប្រព័ន្ធអនឡាញ គឺពាក់ព័ន្ធនឹងនិន្នាការភេទរបស់ពួកគេ ។ យុវជនជារឿយៗ បានរាយការណ៍ពីការបៀតបៀនតាមប្រព័ន្ធអនឡាញ ពាក់ព័ន្ធនឹងពណ៌សម្បុរ ឬរូបរាងខាងក្រៅ យេនឌ័រ ឬការបង្ហាញយេនឌ័ររបស់ពួកគេ (សូមមើលតួលេខទី១៤) ។



[២២] ស្តង់ដារសម្រស់ទូទៅនៅក្នុងប្រទេសកម្ពុជា ផ្តល់តម្លៃទាក់ទាញទៅលើមនុស្សដែលមានស្បែកស និងស្អាត ដែលនាំឱ្យកើតមានការរើសអើងពណ៌សម្បុរ ។ ការរើសអើងនេះ ប៉ះពាល់មនុស្សនៅក្នុងក្រុមជាតិសាសន៍ និងជាតិពន្ធដូចគ្នា ក៏ដូចជាក្រុមជាតិសាសន៍ និងជាតិពន្ធផ្សេងទៀត ។

**តួលេខទី១៩៖ ភាគរយនៃក្រុមនីមួយៗដោយផ្អែកលើកត្តាដែលកើតមានញឹកញាប់ជាងគេ ដែលពួកគេជឿជាក់ថា មានជាប់ពាក់ព័ន្ធនឹងការបៀតបៀនតាមប្រព័ន្ធអនឡាញ**




*អនុញ្ញាតឱ្យមានចម្លើយច្រើន ការឆ្លើយសំណួរមិនមែនជាកាតព្វកិច្ចទេ*

## "អ្នកខ្លះប្រមាថមើលងាយ និងរើសអើងយើង"

ចន្ទី[២៣] ជាស្ត្រីអាយុ ២០ឆ្នាំម្នាក់ ដែលប្តេជ្ញាចិត្តដើម្បីចែករំលែកវប្បធម៌ជនជាតិដើមភាគតិចនៅលើប្រព័ន្ធអនឡាញ ប៉ុន្តែនាងត្រូវបានបៀតបៀនជារឿយៗ ។ នាងបាននិយាយថា "អ្នកខ្លះគេនិយាយអសុរោះថា មិនដឹងសៀវភៅរកផាប់អីទេ គ្មាននរណាចង់ដឹងទេ ។ វាធ្វើឱ្យប៉ះពាល់អារម្មណ៍ខ្លួនឯង និងអ្នកដទៃ" ។

ចន្ទីបានចែករំលែករូបភាពមួយលើហ្វេសប៊ុករបស់នាងអំពីពិធីបុណ្យមួយក្នុងភូមិ ។ ជនប្លែកមុខម្នាក់បានកែប្រែរូបរបស់នាង ដើម្បីធ្វើឱ្យនាងមើលទៅដូចមេធ្មប់ និងបានបង្ហោះឡើងវិញដោយគណនីរបស់គេ ដោយចោទប្រកាន់ថានាងត្រូវបានវិញ្ញាណអាប់ធ្មប់គ្រប់គ្រង ។ ក្រោយមកបុរសនោះបានផ្ញើសារមក ចន្ទី ដើម្បីទារប្រាក់ពីចន្ទី ជាថ្នូរនឹងការលុបសារបង្ហោះនោះចោលវិញ ។ នាងបាននិយាយថា "គាត់បានធ្វើឱ្យប៉ះពាល់កិត្តិយសខ្ញុំ" ។ ជារឿយៗ ការចោទប្រកាន់នេះមានគ្រោះថ្នាក់ណាស់ ដោយនៅប៉ុន្មានឆ្នាំចុងក្រោយនេះ មនុស្សនៅក្នុងប្រទេសកម្ពុជាត្រូវបានធ្វើឃាត ដោយសារតែការសង្ស័យនៃអំពើអាបធ្មប់ ។[២៤]

ចន្ទីបានទៅជួបឪពុកនាង និងមន្ត្រីសាលាឃុំឱ្យជួយនាង ។ ពួកគេបានស្គាល់អត្តសញ្ញាណជនល្មើស ដែលបានធ្វើការសុំទោសតាមប្រព័ន្ធអនឡាញ និងចូលរួមក្នុងពិធីមួយ ដើម្បីកុំឱ្យគេមានអាកប្បកិរិយាបែបនេះទៀត ។ ចន្ទីមានអារម្មណ៍ថាទទួលបានដំណោះស្រាយយុត្តិធម៌ ប៉ុន្តែនាងបានបង្កើតគណនីហ្វេសប៊ុកថ្មីមួយទៀត និងកាត់បន្ថយការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម ។ នាងបាននិយាយថា "ខ្ញុំអត់សូវហ៊ានសរសេរ ឬក៏បង្ហោះអីមួយដែរ" ។ សាររបស់នាងទៅកាន់អ្នកដទៃគឺច្បាស់លាស់ "សូមកុំរើសអើងមិនថាជនជាតិណាក៏ដោយ នៅក្នុងការប្រើប្រាស់បណ្តាញអនឡាញ" ។

---

[២៣] ឈ្មោះត្រូវបានប្តូរ ដើម្បីធានាឯកជនភាព និងការការពារអ្នកចូលរួម ពីការធ្វើទុក្ខបុកម្នេញដែលអាចកើតមានឡើង ។

[២៤] នៅចន្លោះឆ្នាំ២០១២ និងឆ្នាំ២០១៨ របាយការណ៍មួយរបស់អង្គការសហប្រជាជាតិបានចងក្រងជាឯកសារនូវករណីពាក់ព័ន្ធនឹងអំពើអាបធ្មប់ចំនួន ៤៩ករណី ដែលក្នុងនោះមាន ៣៥ករណីទាក់ទងនឹងឃាតកម្ម និង១៤ករណីជាការប៉ុនប៉ងមនុស្សឃាត ឬការធ្វើទុក្ខបុកម្នេញ ។ "តុលាការប្រជាជន៖ ការទប់ស្កាត់ និងការឆ្លើយតបទៅនឹង ការកាត់ក្តីដោយប្រជាជននៅកម្ពុជា" ដោយអង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្សនៅកម្ពុជា ទំព័រទី១០ ចេញផ្សាយឆ្នាំ២០១៩ ។ ដកស្រង់ពី៖https://cambodia.ohchr.org/en/content/peoples-court-preventing-and-responding-%E2%80%9Cpopular-justice%E2%80%9D-cambodia

## ជារឿយៗ ជនល្មើសតែងជាជនប្លែកមុខ ឬមិនស្គាល់អត្តសញ្ញាណ ហើយភាគច្រើនជឿជាក់ថាជា បុរស

អ្នកឆ្លើយតបក្នុងការស្ទង់មតិជាច្រើនបានរាយការណ៍ពីការបៀតបៀនតាមប្រព័ន្ធអនឡាញដោយមនុស្សជាច្រើន ជាពិសេសជនប្លែកមុខ និង/ឬអ្នកប្រើប្រាស់ដែលមិនស្គាល់អត្តសញ្ញាណ ។ ភាគច្រើន ស្ត្រីត្រូវបានដាក់គោលដៅច្រើនជាងបុរសពីសំណាក់ជនប្លែកមុខ ឬអ្នកមិនស្គាល់អត្តសញ្ញាណ ដោយ៥១%នៃអ្នកឆ្លើយតបជាស្ត្រីដែលធ្លាប់ជួបការបៀតបៀនតាមប្រព័ន្ធអនឡាញ បានរាយការណ៍ពីការបៀតបៀនតាមប្រព័ន្ធអនឡាញដោយជនប្លែកមុខ បើប្រៀបធៀបជាមួយអ្នកឆ្លើយតបជាបុរសគឺមាន ២៦% ខណៈដែល៤១%នៃស្ត្រីដែលធ្លាប់ជួបការបៀតបៀនតាមប្រព័ន្ធអនឡាញ បានរាយការណ៍ពីការបៀតបៀនតាមប្រព័ន្ធអនឡាញដោយជនមិនស្គាល់អត្តសញ្ញាណ បើប្រៀបធៀបជាមួយបុរសគឺមាន ២៨% ។ ផ្ទុយទៅវិញ ក្រុមអ្នកស្រឡាញ់ភេទដូចគ្នា ភាគច្រើនត្រូវបានដាក់គោលដៅដោយនរណាម្នាក់ដែលពួកគេស្គាល់ (សូមមើលតួលេខទី១៥) ។ នេះអាចឆ្លុះបញ្ចាំងពីឥរិយាបថប្រកបដោយគ្រោះថ្នាក់យ៉ាងខ្លាំង ដែលការបៀតបៀន និងធ្វើទុក្ខបុកម្នេញទៅលើក្រុមអ្នកស្រឡាញ់ភេទដូចគ្នា គឺនៅអាចទទួលយកបាន ។ ឧទាហរណ៍៖ ការសិក្សាមួយបានរកឃើញថា កុមារភេទទី៣ជាង៦០% ដែលបានចូលរួមស្ទង់មតិនៅក្នុងប្រទេសកម្ពុជា ត្រូវបានបៀតបៀននៅសាលារៀន ។[២៥]

**តួលេខទី១៥៖ ភាគរយនៃអ្នកចូលរួមស្ទង់មតិ ដែលត្រូវបានបៀតបៀនតាមប្រព័ន្ធអនឡាញ ផ្អែកតាមទំនាក់ទំនងជនល្មើសជាមួយពួកគេ**




*អនុញ្ញាតឱ្យមានចម្លើយច្រើន ការឆ្លើយសំណួរមិនមែនជាកាតព្វកិច្ចទេ*

[២៥] "ការសម្លុតអ្នកស្រឡាញ់ភេទដូចគ្នានៅតាមសាលារៀនក្នុងប្រទេសកម្ពុជា" ដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ទំព័រ១៦ ចេញផ្សាយឆ្នាំ២០១៥ ។ ដកស្រង់ពី៖ https://cchrcambodia.org/admin/media/report/report/khmer/2015_12_17_CCHR_REPORT_LGBT_Bullying_in_Cam_School_(KHM).pdf

## “ភាគច្រើនគេថា បើនៅតែបន្ត [បង្ហោះសារ] ទៀតនឹងមានបញ្ហាសុវត្ថិភាពផ្ទាល់ខ្លួន ”

តារា[២៦] គឺជាសកម្មជនសហជីពម្នាក់ ដែលឧស្សាហ៍បង្ហោះព័ត៌មានអំពីបញ្ហាសង្គម និងសិទ្ធិមនុស្សលើប្រព័ន្ធអនឡាញ ។ នៅប៉ុន្មានឆ្នាំចុងក្រោយនេះ លោកតែងតែប្រឈមនឹងការបៀតបៀនតាមប្រព័ន្ធអនឡាញជាបន្តបន្ទាប់ពីសំណាក់អ្នកប្រើប្រាស់ហ្វេសប៊ុកដែលមិនស្គាល់អត្តសញ្ញាណម្នាក់ ។ លោកបាននិយាយថា “ភាគច្រើនឱ្យតែខ្ញុំ បង្ហោះឬសរសេរព័ត៌មានពាក់ព័ន្ធទៅនឹងការរំលោភសិទ្ធិមនុស្ស ឬក៏ពាក់ព័ន្ធនឹងការធ្វើបាបអីណាមួយដល់ប្រជាពលរដ្ឋ មានប្រូហ្វាល់ហ្នឹងគាត់ចូលមកcommentរហូត។ អត្ថន័យគាត់ សរសេរភាគច្រើនគឺរាំងយើង ក្នុងន័យគំរាមកំហែងយើង” ។

គណនីដែលមិនស្គាល់អត្តសញ្ញាណ ដំបូងបង្ហោះរូបភាពពីរជាមួយគ្នា ។ រូបទីមួយគឺជារូបលោកតារា ដែលត្រូវបានយកចេញពីហ្វេសប៊ុករបស់លោក និងរូបទីពីរគឺជារូបកាំភ្លើង ។ តារាបានបញ្ជាក់ថា ការបង្ហោះសារនោះបានបាត់ទៅវិញនៅថ្ងៃបន្ទាប់ ។ ក្រោយមក អ្នកប្រើប្រាស់ដែលមិនស្គាល់អត្តសញ្ញាណនោះ បានចាប់ផ្ដើមសរសេរអធិប្បាយលើការបង្ហោះសាររបស់លោកតារា ឥតឈប់ឈរ ដោយទាមទារឱ្យតារាបញ្ឈប់ការចែករំលែកព័ត៌មាន ។ តារា បានប៉ាន់ស្មានថា លោកទទួលបានការសរសេរអធិប្បាយចន្លោះពី ៥០ ទៅ១០០ នៃការបង្ហោះសាររបស់លោក ។

លោក តារា ក៏បានទទួលការហៅទូរស័ព្ទពីជនមិនស្គាល់អត្តសញ្ញាណ ដែលបានប្រាប់លោកឱ្យបញ្ឈប់ការបង្ហោះព័ត៌មាន ។ លោកគិតថា អ្នកហៅទូរស័ព្ទ និងអ្នកប្រើប្រាស់ហ្វេសប៊ុកដោយមិនស្គាល់អត្តសញ្ញាណនោះគឺជាមនុស្សតែមួយ ដោយសារគេប្រើប្រាស់ពាក្យពេចន៍ស្រដៀងគ្នា ។ តារាក៏បានរាយការណ៍ពីការដែលលោកត្រូវបានតាមដានដោយផ្ទាល់ផងដែរ ។ លោកបានរៀបរាប់ថា “គាត់ដឹងថាយើងប្រកបអាជីវកម្មអីទៀត ហើយដឹងថាយើងនឹងនៅតំបន់ណា គោលដៅណា ចឹងគឺថាគាត់ដឹងតាម៉ង ខ្ញុំគិតថាមិនមែនអ្នកឆ្ងាយទេ ហើយជាអ្នកដែលជំនាញបច្ចេកវិទ្យាទៀត គាត់ដឹងថាយើងឈរនៅគោលដៅណា” ។

តារាបានព្យាយាមប្លុកបុគ្គលនោះ ប៉ុន្តែមិនបានជោគជ័យទេ ។ លោកបាននិយាយថា “យើងរកអ្នកជំនាញដែលគាត់ចេះប្លុកម៉ង គាត់នៅតែថាចូលទៅប្លុកអត់បាន ដូចថាយើងមិនមែនជាFriend គាត់ តែគាត់អាចចូលមក Comments យើងបាន ។ ហើយយើងឆែកមើលFriend របស់គាត់នៅក្នុង Profileហ្នឹង ក៏ឃើញសុទ្ធតែមន្ត្រីធំៗ” ។

តារាក៏ដឹងថា ការតាមដានលើការបង្ហោះសាររបស់លោកនៅលើហ្វេសប៊ុកនឹងនៅបន្តទៀត ។ មន្ត្រីមូលដ្ឋានធ្លាប់បានព្រមានលោកតារា កុំឱ្យបង្ហោះព័ត៌មានពាក់ព័ន្ធនឹងនយោបាយ និងឱ្យប្រុងប្រយ័ត្ន ។ លោកមិនបានភ័យខ្លាចទេ និងបន្តបញ្ចេញមតិអំពីបញ្ហាសំខាន់ៗ ប៉ុន្តែលោកព្រួយបារម្ភថា អ្នកផ្សេងទៀតអាចឃើញការបៀតបៀននេះ និងឈប់បង្ហោះព័ត៌មានរបស់ពួកគេ ។

## “សុខៗថតរូបយើងដោយមិនមានការអនុញ្ញាត”

ល័ក្ខ[២៧] ជាស្ត្រីម្នាក់អាយុ ២៦ឆ្នាំ បានទៅម៉ាតតូចមួយ ដើម្បីទិញភេសជ្ជៈ ខណៈនោះស្រាប់តែមានបុរសប្លែកមុខមួយក្រុមប្រមាណ៤នាក់បានថតរូបនាង។ក្រោយមកជនប្លែកមុខម្នាក់បានផ្ញើសារមកនាងតាមថេលេក្រាមដោយបានប្រាប់នាងថារូបរបស់នាងត្រូវបានចែកចាយក្នុងក្រុមថេលេក្រាមមួយហើយថាមនុស្សកំពុងតែនិយាយពីនាង។បុរសនៅម៉ាតនោះចាប់ផ្តើមស្នើនាងធ្វើជាមិត្តលើហ្វេសប៊ុក ប៉ុន្តែត្រូវបាននាងបដិសេធ។ដោយសារល័ក្ខមិនអាចចូលមើលក្រុមថេលេក្រាម នាងមិនច្បាស់ថារូបភាពរបស់នាងនៅតែត្រូវបានចែករំលែកឬយ៉ាងណាទេទោះបីជាពួកគេបានប្រាប់នាងថាពួកគេបានលុបរូបទាំងនោះចោលហើយក៏ដោយ។ ល័ក្ខ ក៏មិនបានដឹងថាហេតុដូចម្តេចបានជាពួកគេអាចរកឃើញនាងនៅលើថេលេក្រាម និងហ្វេសប៊ុកដែរ។ នាងបាននិយាយថា “ខ្ញុំអត់ដឹង។ខ្ញុំដូចជាមានអារម្មណ៍ខ្លាចៗរាងអត់យល់អត់ដឹងថាលើរូបថតមួយហ្នឹងគាត់ប្រើពាក្យពេចន៍អីខ្លះ ហើយនៅសុខៗហេតុអី មនុស្សដែលអត់ស្គាល់គ្នាក៏យករូបទៅធ្វើចឹង” ។

---

[២៦] ឈ្មោះត្រូវបានប្តូរ ដើម្បីធានាឯកជនភាព និងការការពារអ្នកចូលរួម ពីការធ្វើទុក្ខបុកម្នេញដែលអាចកើតមានឡើង ។

[២៧] ឈ្មោះត្រូវបានប្តូរ ដើម្បីធានាឯកជនភាព និងការការពារអ្នកចូលរួម ពីការធ្វើទុក្ខបុកម្នេញដែលអាចកើតមានឡើង ។



ពេលខ្លះ ជនល្មើសស្គាល់អត្តសញ្ញាណមនុស្ស ដែលគេដាក់គោលដៅ ។ ស្ត្រីម្នាក់ដែលមានអាយុ ២០ស្ទើង បានចែករំលែកថា អតីតមិត្តប្រុសរបស់នាងបានលួចចូលប្រើប្រាស់គណនីរបស់នាង ។ នាងបាននិយាយថា "អតីតមិត្តប្រុសរបស់ខ្ញុំ បានប្រើប្រាស់គណនីរបស់ខ្ញុំ ហើយបានថតស្រ្តីនសាររបស់ខ្ញុំជាមួយមនុស្សផ្សេងនិង បានបង្ហោះវានៅលើគណនីរបស់ខ្ញុំ ធ្វើឱ្យខ្ញុំភ័យខ្លាចនឹងអាម៉ាស" ។ ស្ត្រីម្នាក់ទៀត អាយុជាង ៣០ឆ្នាំ បានចែករំលែកថា អតីតមិត្តប្រុសរបស់នាង បានបង្កើតគណនីក្លែងក្លាយដោយប្រើប្រាស់រូបភាពពីគណនីរបស់នាង ដើម្បីព្យាយាមគ្រប់គ្រងនាង ។ នាងបានរៀបរាប់ថា "ពេលហ្នឹង គាត់អត់ចង់បែកគ្នាជាមួយខ្ញុំ ប្រហែលជាគាត់ចង់គំរាមយើង ដើម្បីកុំឱ្យយើងបែកពីគាត់" ។

អ្នកឆ្លើយតបបានរាយការណ៍ថា បុរសបានប្រព្រឹត្តការបៀតបៀនតាមប្រព័ន្ធអនឡាញញឹកញាប់ជាងស្ត្រី ។ ជាឧទាហរណ៍ នៅពេលដែលជនល្មើសជាជនប្លែកមុខ ឬជនមិនស្គាល់អត្តសញ្ញាណ អ្នកឆ្លើយតបអាចសន្និតពីយេនឌ័ររបស់ជនល្មើសដោយផ្អែកលើវត្តមានរបស់គេលើប្រព័ន្ធអនឡាញ ។ ក្នុងចំណោមមនុស្សដែលបានរាយការណ៍ពីការបៀតបៀនតាមប្រព័ន្ធអនឡាញ ៦៥%នៃអ្នកឆ្លើយតបជឿជាក់ថា ពួកគេត្រូវបានដាក់គោលដៅដោយបុរស និង២៣%ជឿជាក់ថា ពួកគេត្រូវបានដាក់គោលដៅដោយស្ត្រី ហើយអ្នកខ្លះទៀតបានរាយការណ៍ពីការបៀតបៀនតាមប្រព័ន្ធអនឡាញដោយមនុស្សដែលមានយេនឌ័រខុសៗគ្នា ខណៈដែលអ្នកផ្សេងទៀតមិនស្គាល់ច្បាស់ពីយេនឌ័ររបស់ជនល្មើស(សូមមើលតារាងទី៤)។

**តារាងទី៤៖ យេនឌ័ររបស់ជនល្មើស រាយការណ៍ដោយអ្នកចូលរួមស្ទង់មតិ ដែលត្រូវបានបៀតបៀនតាម**

| យេនឌ័ររបស់ជនល្មើស | ចំនួនអ្នកឆ្លើយតប |
|---|---|
| បុរស | ១៧៧ |
| ស្ត្រី | ៦៤ |
| ផ្សេងទៀត | ៨ |
| មិនស្គាល់ | ៥៥ |

*មនុស្សម្នាក់អាចរាយការណ៍ពីការគំរាមកំហែងច្រើនប្រភេទ*

## “ ពួកគាត់នៅតែដើរផ្ញើសារទៅអ្នកដទៃ ជាពិសេសស្ត្រី ”

*វណ្ណា[២៨] អាយុ ២៣ឆ្នាំ ជាសិស្សម្នាក់ ដែលប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម ដើម្បីទំនាក់ទំនងជាមួយមិត្តភក្តិ និងអានព័ត៌មាន ។ នាងបានជួបការបែកធ្លាយព័ត៌មាន នៅពេលដែលលេខទូរស័ព្ទរបស់នាង ត្រូវបានមិត្តរបស់មិត្តភក្តិនាងចែកចាយដោយមិនត្រឹមត្រូវនៅក្នុងក្រុមផ្ញើសារជំមួយ ។ នាងបាននិយាយថា "គេចង់លក្ខណៈដូចធ្វើបាប គេចែកចាយទៅអ្នកដែលអត់ល្អ" ។*

*វណ្ណាបានប្លុកមិត្តរបស់នាង និងបុរសដែលបានចែកចាយលេខទូរស័ព្ទរបស់នាង ប៉ុន្តែនាងបានចាប់ផ្តើមទទួលការហៅចូលពីលេខទូរស័ព្ទមិនស្គាល់ជាច្រើន ។ នាងមិនបានឆ្លើយតបទេ ប៉ុន្តែបុរសដែលនាងមិនស្គាល់ជាច្រើន បានចាប់ផ្តើមទាក់ទងនាងតាមកម្មវិធីឆាត ។ នាងបាននិយាយថា "គេប្រើពាក្យអត់គួរសម ខ្ញុំអត់និយាយអីទាំងអស់ ខ្ញុំប្លុកចោល ។ ខ្ញុំមានអារម្មណ៍ថាអត់មានសុវត្ថិភាព" ។*

[២៨] ឈ្មោះត្រូវបានប្តូរ ដើម្បីធានាឯកជនភាព និងការការពារអ្នកចូលរួម ពីការធ្វើទុក្ខបុកម្នេញដែលអាចកើតមានឡើង ។

## អាជ្ញាធរកម្ពុជាតាមដាន និងធ្វើទុក្ខបុកម្នេញសកម្មជន និងអ្នកផ្សេងទៀត ដើម្បីគាបសង្កត់សេរីភាពនៃការបញ្ចេញមតិតាមប្រព័ន្ធអនឡាញ

អាជ្ញាធរកម្ពុជាជារឿយៗតែង ធ្វើទុក្ខបុកម្នេញ និងចាប់ខ្លួនអ្នកការពារបរិស្ថាន និងអ្នកការពារសិទ្ធិមនុស្ស គូប្រជែងនយោបាយ អ្នកសារព័ត៌មាន និងអ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម ដាក់ពន្ធនាគារ ដោយសារការសម្តែងមតិរបស់ពួកគេនៅលើប្រព័ន្ធអនឡាញ ។ ការធ្វើទុក្ខបុកម្នេញនេះ ត្រូវបានអនុញ្ញាតដោយអំណាចតាមដានដ៏លើសលប់ និងគ្មានតម្លាភាព ។ ការបៀតបៀនតាមប្រព័ន្ធអនឡាញដោយអាជ្ញាធរ ត្រូវបានរាយការណ៍ដោយ ៤%នៃអ្នកឆ្លើយតបទាំងអស់ និង១១%នៃសកម្មជន ។ អ្នកចូលរួមស្ទង់មតិចំនួន ១៤នាក់ ដែលក្នុងនោះមាន១១នាក់ជាបុរស ខណៈដែល៨នាក់កំណត់អត្តសញ្ញាណជាសកម្មជន បានរាយការណ៍ដោយជាក់លាក់ថា អាជ្ញាធរបានប្រតិកម្មទៅលើអ្វីមួយដែលពួកគេបានបង្ហោះនៅលើប្រព័ន្ធអនឡាញ ដោយធ្វើការកោះហៅពួកគេទៅសាកសួរ ព្រមទាំងបង្គាប់ឱ្យលុបសារបង្ហោះ ឬធ្វើការសុំទោស ជាដើម ។

ទោះបីជាមិនបានលើកឡើងនៅផ្នែកណាមួយនៃការស្រាវជ្រាវនេះ មានករណីជាច្រើនត្រូវបានដឹងឮជាសាធារណៈថា តួអង្គរដ្ឋបានចាប់ខ្លួនផ្តន្ទាទោស និងចាប់ប្រជាពលរដ្ឋដាក់ពន្ធនាគារ ដោយសារតែការសម្តែងមតិរបស់ពួកគេលើប្រព័ន្ធអនឡាញ។[២៩] បទប្បញ្ញត្តិមិនច្បាស់លាស់នៃក្រមព្រហ្មទណ្ឌ ជាពិសេសបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ជាអាទិ៍ (មាត្រា៤៩៤ និងមាត្រា៤៩៥) បទជេរប្រមាថជាសាធារណៈ (មាត្រា៣០៧) និងបទប្រមាថចំពោះអង្គព្រះមហាក្សត្រ (មាត្រា៤៣៧ស្ទួន) តែងត្រូវបានប្រើប្រាស់ដោយប្រព័ន្ធយុត្តិធម៌នៅកម្ពុជា ដើម្បីចាប់ប្រជាពលរដ្ឋដាក់ពន្ធនាគារ ដោយសារការសម្តែងមតិរបស់ពួកគេនៅលើប្រព័ន្ធអនឡាញ។[២៩] អាជ្ញាធរក៏បានដកហូតអាជ្ញាប័ណ្ណពីស្ថាប័នប្រព័ន្ធផ្សព្វផ្សាយ ដោយសារតែការរាយការណ៍ព័ត៌មានរបស់អ្នកទាំងនោះលើប្រព័ន្ធអនឡាញ ។ នៅឆ្នាំ២០២០ អង្គការលីកាដូបានចងក្រងជាឯកសារនូវការចាប់ខ្លួនប្រជាពលរដ្ឋចំនួន ១៥៨នាក់ (ស្ត្រី ៣៤នាក់ និងបុរស១២៤នាក់) ដោយសារការបញ្ចេញមតិរបស់ពួកគេលើប្រព័ន្ធអនឡាញ ។ គិតត្រឹមចុងឆ្នាំនោះ ពួកគេចំនួន ៧៣នាក់ កំពុងស្ថិតនៅក្នុងពន្ធនាគារនៅឡើយ ។ មាតិកាប្រព័ន្ធផ្សព្វផ្សាយសង្គម ដែលក្នុងនោះមានការសន្ទនាជាលក្ខណៈឯកជន ជារឿយៗតែងជាភស្តុតាងតែមួយប្រភេទគត់ ក្នុងការបង្ហាញនៅក្នុងសវនាការ ផងដែរ ។

ជាឧទាហរណ៍ កាលពីខែឧសភា ឆ្នាំ២០២១ សកម្មជនបរិស្ថាន កញ្ញា ឡុង គន្ធា កញ្ញា ភួន កែវរស្មី និងលោក ថុន រដ្ឋា ត្រូវបានផ្តន្ទាទោសក្រោមការចោទប្រកាន់ពីបទញុះញង់ ។ "ភស្តុតាង" តែមួយប្រភេទគត់ដែលត្រូវបានបង្ហាញនៅក្នុងសវនាការគឺ ការបង្ហោះសារនៅលើហ្វេសប៊ុក និងការសន្ទនាជាវីដេអូរបស់ពួកគេក្នុងកិច្ចការពារបរិស្ថាន ។ ពួកគេត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគារចន្លោះពី ១៨ខែ ទៅ ២០ខែ ដោយសកម្មជនពីរនាក់ផ្សេងទៀត ត្រូវបានកាត់ទោសដោយកំបាំងមុខ ។ សាលាឧទ្ធរណ៍នៅរាជធានីភ្នំពេញ បានព្យួរទោសខ្លះរបស់ពួកគេក្នុងខែវិច្ឆិកា ឆ្នាំ២០២១ បន្ទាប់ពីពួកគេជាប់ឃុំក្នុងពន្ធនាគារអស់រយៈពេលជាង ១ឆ្នាំ ។ អ្នកទាំង៣ ប្រឈមនឹងការចោទប្រកាន់ពីបទរួមគំនិតក្បត់ក្នុងសំណុំរឿងមួយទៀតរួមជាមួយសកម្មជន៣នាក់ទៀតដូចជា កញ្ញា ស៊ុន រដ្ឋា លោក យ៉ឹម លាងហ៊ី និងលោក លី ចាន់ដារ៉ាវុត ដែលត្រូវបានចាប់ខ្លួន និងចោទប្រកាន់ ក្នុងខែមិថុនា ឆ្នាំ២០២១ ។ កញ្ញា រដ្ឋា និងលោក លាងហ៊ី ក៏ប្រឈមនឹងបទប្រមាថចំពោះអង្គព្រះមហាក្សត្រផងដែរ ។ ប្រព័ន្ធផ្សព្វផ្សាយ Fresh News ដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយរដ្ឋាភិបាល បានបញ្ចេញវីដេអូដែលបានថតទុកស្តីពីការចូលរួមរបស់ពួកគេក្នុងកិច្ចប្រជុំតាមកម្មវិធី Zoom ជាលក្ខណៈឯកជន ដែលទំនងជាត្រូវបានលួចថតដោយមិនត្រឹមត្រូវ ដែលប្រព័ន្ធផ្សព្វផ្សាយនោះមិនបានប្រាប់ពីប្រភពនៃវីដេអូទេ ប៉ុន្តែបានបញ្ជាក់ថាជា "ភស្តុតាង" ។ អ្នកទាំង៦នាក់ ត្រូវបានដោះលែង



[២៩] សម្រាប់ឧទាហរណ៍ សូមមើល "ការតស៊ូដើម្បីសេរីភាព ៖ ការរំលោភបំពានអ្នកការពារសិទ្ធិមនុស្ស ២០១៨-២០២០" ចេញផ្សាយដោយអង្គការលីកាដូ ឆ្នាំ២០២០ ។ ដកស្រង់ពី៖ https://www.licadho-cambodia.org/reports.php?perm=233&khmer

ឱ្យនៅក្រៅឃុំក្នុងខែវិច្ឆិកា ឆ្នាំ២០២១ ប៉ុន្តែត្រូវបន្តប្រឈមនឹងការជាប់ពន្ធនាគាររហូតដល់ ១០ឆ្នាំ ប្រសិនបើរកឃើញថាមានពិរុទ្ធភាព ។[៣០]

ស្រដៀងគ្នានេះដែរ កាលពីខែមិថុនា ឆ្នាំ២០២១ ក្មេងប្រុសអាយុ ១៦ឆ្នាំម្នាក់ ដែលមានជំងឺអូទីស្ស៊ីម (ASD) ត្រូវបានឃុំខ្លួន ជុំវិញការបង្ហោះសារតាមរយៈកម្មវិធីថេលេក្រាម និងលើហ្វេសប៊ុក ខណៈដែលឪពុករបស់ក្មេងប្រុស ដែលជាអតីតសកម្មជន និងជាសមាជិកគណបក្សជំទាស់ ក៏កំពុងត្រូវបានឃុំខ្លួនផងដែរ ។ នៅមុនពេលចាប់ខ្លួនក្មេងប្រុសនេះ ម្ដាយរបស់គេជារឿយៗ បានតវ៉ាឱ្យមានការដោះលែងឪពុករបស់កុមារនោះវិញ ។ នៅខែវិច្ឆិកា ឆ្នាំ២០២១ ក្រោយពីត្រូវបានឃុំខ្លួនក្នុងពន្ធនាគារអស់រយៈពេល៤ខែ រូបគេត្រូវបានផ្តន្ទាទោសពីបទញុះញង់ និងបទប្រមាថមន្ត្រីរាជការសាធារណៈ ព្រមទាំងត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារ៨ខែ ។ ក្មេងប្រុសនេះ បានអនុវត្តទោសជាប់ពន្ធនាគារ ៤ខែ និង១៥ថ្ងៃ ដោយទោសនៅសល់ផ្សេងទៀតត្រូវបានព្យួរ ប៉ុន្តែរូបគេត្រូវស្ថិតក្រោមការព្យួរទោសសាកល្បងរយៈពេល២ឆ្នាំ ដោយភ្ជាប់ជាមួយលក្ខខណ្ឌជាច្រើនទៀត ។[៣១]

ក្រៅពីចាប់អ្នករិះគន់ឥតសំចៃលើប្រព័ន្ធអនឡាញដាក់ពន្ធនាគារ អាជ្ញាធរក៏បានចូលរួមយុទ្ធនាការតាមប្រព័ន្ធអនឡាញ ដើម្បីធ្វើទុក្ខបុកម្នេញសំឡេងអ្នករិះគន់ផងដែរ ។ កាលពីខែមិថុនា ឆ្នាំ២០២០ ព្រះតេជព្រះគុណ លួន សុវ៉ាត ដែលត្រូវបានទទួលស្គាល់ដោយអន្តរជាតិថាជាព្រះសង្ឃការពារសិទ្ធិមនុស្ស ត្រូវបានដាក់គោលដៅនៅក្នុងយុទ្ធនាការមួយ ដោយប្រើប្រាស់វីដេអូ សារជាសំឡេង និងគណនីហ្វេសប៊ុកក្លែងក្លាយ ។ ការស៊ើបអង្កេតរបស់កាសែត The New York Times បានរកឃើញថា មន្ត្រីនៃក្រុមឃោសនារបស់រាជរដ្ឋាភិបាលគឺអង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស មានជាប់ពាក់ព័ន្ធក្នុងការបង្កើត និងបង្ហោះវីដេអូដែលមានលក្ខណៈមិនពិតលើហ្វេសប៊ុក ។ ទោះបីជាហ្វេសប៊ុកបានលុបចោលទំព័រក្លែងក្លាយនោះហើយក្តី ប៉ុន្តែការលុបទំព័រនោះត្រូវប្រើរយៈពេលជាងមួយខែ ។[៣២] ព្រះអង្គបានចាកចេញពីប្រទេសកម្ពុជា និងត្រូវបានកាត់ទោសដោយកំបាំងមុខ និងត្រូវបានថេរសភាសង្ឃដែលគ្រប់គ្រងដោយរាជរដ្ឋាភិបាលផ្សឹកដោយអវត្តមានព្រះអង្គ ផងដែរ ។

បរិបទនេះបាននាំឱ្យមានការត្រួតពិនិត្យចាប់ពិរុទ្ធកាន់តែធំឡើង ។ ស្ត្រីជាអ្នកសារព័ត៌មានម្នាក់ដែលបានផ្តល់បទសម្ភាសន៍ក្នុងការស្រាវជ្រាវនេះ បានឆ្លុះបញ្ចាំងថា អាជ្ញាធរបានកោះហៅអ្នកការពារសិទ្ធិមនុស្សទៅសាកសួរដោយសារការបញ្ចេញមតិរបស់ពួកគេលើហ្វេសប៊ុក ។ នាងបាននិយាយថា "ខ្ញុំអត់មានសរសេរពាក់ព័ន្ធជាមួយនឹងរឿង Sensitive ពេកទេ" ។ បុរសម្នាក់ អាយុជាង ២០ឆ្នាំ បានសរសេរអធិប្បាយថា "ពេលនេះ ខ្ញុំអាចនិយាយបានតែរឿងបញ្ហាតិចតួចទេ ដោយសារអាជ្ញាធររឹតបន្តឹងលើសេរីភាពបញ្ចេញមតិ" ។ និស្សិតម្នាក់ អាយុជាង ២០ឆ្នាំ បានចែករំលែកថា "ការផុសសកម្មភាពក្នុងសហគមន៍ត្រូវបានអាជ្ញាធរតាមដាននិងហាមឃាត់"។

ច្បាប់ដែលត្រូវបានអនុម័តថ្មីៗនេះ ទំនងជានឹងកាន់តែរឹតត្បិតសេរីភាពនៃការសម្តែងមតិតាមប្រព័ន្ធអនឡាញ បន្ថែមទៀត ។[៣៣] ច្បាប់ស្តីពីទូរគមនាគមន៍ ដែលត្រូវបានអនុម័តឆ្នាំ២០១៥ បានអនុញ្ញាតឱ្យមានអំណាចតាមដាន និងការផ្តន្ទាទោសដោយគ្មានតម្លាភាពលើការបញ្ចេញមតិ ។ ប្រកាសអន្តរក្រសួងលេខ១៧០ ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងការផ្សព្វផ្សាយតាមគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គមដែលដំណើរការតាមប្រព័ន្ធអ៊ីនធឺណិតនៅព្រះរាជាណាចក្រកម្ពុជា បានផ្តល់មូលដ្ឋានទូលំទូលាយ និងស្រពេចស្រពិល ថាតើមាតិកាអនឡាញណាខ្លះដែលអាចត្រូវបានរាំងខ្ទប់ ព្រមទាំងបានចាត់តាំងក្រសួងចំនួនបី ដើម្បីតាមដានគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គម ។ កាលពីខែមករា ឆ្នាំ២០២១ មន្ត្រីក្រសួងព័ត៌មានម្នាក់ បានប្រាប់សារព័ត៌មានក្នុងស្រុកមួយថា ក្រសួងនឹងបន្ថែមសមត្ថភាពឃ្លាំមើលទៅលើកម្មវិធីជីកចុក និងកម្មវិធីផ្ញើសារជាលក្ខណៈឯកជនដូចជា វតសអ៊ាប់ ឆាត និងថេលេក្រាម ជាដើម ។[៣៤] អនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ ត្រូវបានអនុម័តកាលពីខែកុម្ភៈ ដែលនឹងត្រូវចាប់ផ្តើមអនុវត្តនៅដើមឆ្នាំ២០២២នេះ ។ ដោយតម្រូវឱ្យគ្រប់បណ្តាញអ៊ីនធឺណិតទាំងអស់ត្រូវឆ្លងកាត់ ច្រកទ្វារនេះនឹងផ្តល់មធ្យោបាយសម្រាប់អាជ្ញាធរដើម្បីគ្រប់គ្រង និងរឹតត្បិតទាំងអស់នៃចរាចរណ៍លើអ៊ីនធឺណិត រាំងខ្ទប់មាតិកាលើអ៊ីនធឺណិត និងបង្កើនការតាមដាន ។ សេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យា ក៏បង្កើតឱ្យមានហានិភ័យបន្ថែមទៀត ទៅលើសេរីភាពនៃការបញ្ចេញមតិ និងសិទ្ធិឯកជនភាព ប្រសិនបើច្បាប់នេះត្រូវបានអនុម័ត ។

---

[៣០] សូមមើលសេចក្តីថ្លែងការណ៍រួម "សូមទម្លាក់ចោលបទចោទទាំងអស់ចំពោះសកម្មជនមាតាធម្មជាតិ និងដោះលែងអ្នកការពារសិទ្ធិមនុស្សដែលកំពុងជាប់ឃុំក្នុងពន្ធនាគារ" ចេញផ្សាយថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២១ ។ ដកស្រង់ពី៖

https://www.licadho-cambodia.org/pressrelease.php?perm=479&khmer

[៣១] សូមមើលអត្ថបទខ្លីៗស្តីពី "កុមារអាយុ ១៦ឆ្នាំ ដែលកើតជំងឺអូទីស្ស៊ីម ត្រូវបានផ្តន្ទាទោស ជុំវិញការបង្ហោះសារលើហ្វេសប៊ុក និងថេលេក្រាម" ចេញផ្សាយដោយអង្គការលីកាដូ ឆ្នាំ២០២១ ។ ដកស្រង់ពី៖ https://www.licadho-cambodia.org/flashnews.php?perm=296&khmer

[៣២] សូមមើលអត្ថបទស្តីពី "ព្រះសង្ឃម្នាក់ជម្លៀសព្រះកាយចេញពីប្រទេសកម្ពុជា ក្រោយពីរងការគំរាមកំហែងដោយព័ត៌មានមិនពិតលើហ្វេសប៊ុក" ដោយ Hannah Beech and Sun Narin មកពី The New York Times ចេញផ្សាយថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២០ ។ ដកស្រង់ពី

[៣៣] សម្រាប់ការពិភាក្សាស៊ីជម្រៅនៃច្បាប់ពាក់ព័ន្ធ សូមមើល "សេរីភាពអ៊ីនធឺណិតនៅកម្ពុជា៖ ច្រកទ្វារដើម្បីគ្រប់គ្រង" ដោយ Asia Centre ចេញផ្សាយឆ្នាំ២០២១ ។ ដកស្រង់ពី៖ https://asiacentre.org/wp-content/uploads/Internet-Freedoms-in-Cambodia-A-Gateway-to-Control.pdf និង "មនុស្សកំពុងឃ្លាំមើល៖ ការត្រួតពិនិត្យចាប់ពិរុទ្ធ ការតាមដាន និងច្រកទ្វារអ៊ីនធឺណិតជាតិនៅកម្ពុជា" ដោយ Digital Reach ចេញផ្សាយឆ្នាំ២០២១ ។ ដកស្រង់ពី៖ https://digitalreach.asia/news/online-people-watching-censorship-surveillance-and-the-national-internet-gateway-in-cambodia/

[៣៤] សូមមើលអត្ថបទ "ក្រសួងព័ត៌មានបង្កើនការឃ្លាំមើលលើប្រព័ន្ធផ្សព្វផ្សាយសង្គម" ដោយ ស សុជាតិ មកពី Khmer Times ចេញផ្សាយថ្ងៃទី២៨ ខែមករា ឆ្នាំ២០២១ ។ ដកស្រង់ពី៖ https://www.khmertimeskh.com/50807854/information-ministry-to-expand-monitoring-on-social-media/

### “រឿងនិយាយផ្តោតខ្លាំងទាក់ទងលើការបំពារបំពានសិទ្ធិហ្នឹង ក៏យើងអត់ប្រើ [Facebook]ច្រើនដែរ ព្រោះខ្លាចគេរឹតត្បិតជាប់”

ពិសិដ្ឋ[៣៥] ជាសកម្មជនសហជីពម្នាក់ ដែលត្រូវបានធ្វើទុក្ខបុកម្នេញឥតឈប់ឈរ ដោយសារការងារ និងការសម្តែងមតិតាមប្រព័ន្ធអនឡាញរបស់លោក ។ លោកធ្លាប់បង្ហោះព័ត៌មានអំពីសិទ្ធិការងារ នយោបាយ ការរំលោភយកដីធ្លី និងការរំលោភសិទ្ធិមនុស្ស ប៉ុន្តែពេលនេះ លោកគ្រាន់តែចែករំលែកពីមាតិកាផ្ទាល់ខ្លួនប៉ុណ្ណោះ ។

នៅពេលពិសិដ្ឋអំពាវនាវឱ្យដោះលែងសកម្មជនដែលកំពុងជាប់ឃុំក្នុងពន្ធនាគារ មន្ត្រីយោធាជាន់ខ្ពស់ម្នាក់ បានហៅលោកទៅជួប ។ អំឡុងពេលជួបគ្នាដែលបានចំណាយពេលជាច្រើនម៉ោង ពិសិដ្ឋ តក់ស្លុតនឹងព័ត៌មានលម្អិតដែលពួកគេដឹងអំពីលោក ដែលលោកជឿជាក់ថា ពួកគេយកចេញពីការសន្ទនាជាលក្ខណៈឯកជន និងការបង្ហោះសាររបស់លោកលើហ្វេសប៊ុក ។ លោកបានរៀបរាប់ថា “ខ្ញុំគិតថា គេស្វែងរកតាមប្រព័ន្ធបច្ចេកវិទ្យាហ្នឹង តាមហ្វេសប៊ុកតាមអីហ្នឹងហើយ... គេដឹងទាំងអស់ ដឹងពីប្រវត្តិធ្វើការ” ។ អំឡុងពេលជួបគ្នា លោកត្រូវបានព្រមានកុំឱ្យហួសបន្ទាត់ព្រំដែនពាក់ព័ន្ធនឹងការងារ និងការបង្ហោះសាររបស់លោកលើប្រព័ន្ធអនឡាញ ។ “គេថាកុំថាយើងទៅដល់កន្លែងណា ចូលក្នុងលូទឹកស្អុយ ក៏គេដឹងថានៅក្នុងលូទឹកស្អុយដែរ” ។

ប៉ុន្តែលោកពិសិដ្ឋ បានជួបការបៀតបៀនតាមប្រព័ន្ធអនឡាញ មុនពេលជួបគ្នានោះ ។ អ្នកប្រើប្រាស់ដែលមិនស្គាល់អត្តសញ្ញាណបានទាក់ទងលោកពិសិដ្ឋយ៉ាងតិចណាស់បីដង តាមរយៈកម្មវិធីឆាត និងការហៅទូរស័ព្ទដោយផ្ទាល់ ដោយព្រមានលោកឱ្យប្រុងប្រយ័ត្ន ។ សារទាំងនោះត្រូវបានលុបបាត់ទៅវិញនៅប៉ុន្មានម៉ោងក្រោយមក ។ លោកបានទទួលការជូនដំណឹងជាច្រើនថា មានអ្នកប៉ុនប៉ងចូលប្រើប្រាស់គណនីហ្វេសប៊ុករបស់លោក ។ ពិសិដ្ឋក៏ត្រូវបានតាមដានដោយផ្ទាល់ពីសំណាក់មនុស្សជិះម៉ូតូ ដែលបានរង់ចាំលោកនៅក្រៅផ្ទះ ឬកន្លែងធ្វើការរបស់លោក ។អ្នកគ្រប់គ្រងរបស់លោកក៏ដូចជាអាជ្ញាធរថ្នាក់ស្រុកនិងខេត្តបានប្រាប់លោកឱ្យឈប់បញ្ចេញមតិនៅកន្លែងធ្វើការ។

ការធ្វើទុក្ខបុកម្នេញជាបន្តបន្ទាប់នេះ បានធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់លោកពិសិដ្ឋ ។ លោកបានរៀបរាប់ថា “ពេលត្រលប់មកពីជួបគេវិញ និយាយទៅក្នុង១យប់ហ្នឹង អ្វីដែលយើងនិយាយហើយអីហើយគិតថាវាជាទម្ងន់មួយដល់យើង ... ខ្ញុំអង្គុយរើសមើល លុបចោលឯកសារផ្សេងៗ” ។ លោកបន្តថា “ពីមុនយើងឃើញព័ត៌មានណាផុសផុល គេស៊ែរច្រើន យើងក៏ចូលរួមដែរដើម្បីលើកទឹកចិត្តដល់យុវជនដែលបានប្រឹងធ្វើការងារទាំងអស់ហ្នឹង...ដល់ពេលអ៊ីចឹងយើងមានសម្ពាធ ... យើងស្រមៃទៅអនាគតទៀតតើប្រទេសរបស់ខ្លួនឯង ឬកូនចៅរបស់យើង នឹងទៅជាយ៉ាងណា” ។

### “គេថាបើមិនលុបចោលទេ សាកតែឃើញផុសចេញ អញនឹងប្តឹងទៅប៉ូលីស”

នៅរយៈពេលប្រមាណមួយទសវត្សរ៍មកនេះ រដ្ឋា[៣៦] អាយុ ២៧ឆ្នាំ ជាកសិករម្នាក់ បានជួបប្រឈមនឹងបញ្ហាជម្លោះដីធ្លីមួយដែលអូសបន្លាយពេលជាច្រើនឆ្នាំ ដែលលោកបានបាត់បង់ដីធ្លីទាំងស្រុង ក្នុងនោះដីធ្លីរបស់លោកទំហំបីហិកតាត្រូវបានបាត់បង់ទៅក្រុមហ៊ុនដ៏មានឥទ្ធិពលមួយ ។ លោកគឺជាអ្នកតស៊ូមតិដ៏រឹងមាំម្នាក់ ក្នុងកិច្ចខិតខំប្រឹងប្រែងការពារដីសហគមន៍ ហើយលោកពឹងផ្អែកលើហ្វេសប៊ុក ដើម្បីផ្សព្វផ្សាយពីការរំលោភបំពានសិទ្ធិដីធ្លីដែលពួកគេជួបប្រទះ ។

នៅពេលរដ្ឋាបានព្យាយាមចងក្រងឯកសារស្តីពីការទន្ទ្រានយកដីសហគមន៍ អាជ្ញាធរបានគំរាមកំហែងលោក ។ លោកបាននិយាយថា “គេថាឱ្យតែហ៊ានថតអញផុស អញនឹងចាប់ដាក់គុក” ។

រដ្ឋា ក៏មានអារម្មណ៍ថា ការបង្ហោះព័ត៌មានរបស់លោក ត្រូវបានមេភូមិឃ្លាំមើលយ៉ាងជាប់លាប់ ដែលអាចនឹងរាយការណ៍ទៅមន្ត្រីថ្នាក់ខ្ពស់ ។ លោកថា “គេតាមសង្កេតមើលចង់ថា១០០% ដើម្បីឃើញខុសត្រង់ណាត្រង់ណី គេនឹងធ្វើស៊ីខ្ញុំ” ។ ប៉ុន្តែការគំរាមកំហែងនេះ មិនបានបង្អាក់ដំណើរលោកទេ “ពេលគេគំរាមចឹង នៅតែខ្ញុំតាមថតគេ នៅតែខ្ញុំតាមផុសគេ” ។

---

[៣៥] ឈ្មោះត្រូវបានប្តូរ ដើម្បីធានាឯកជនភាព និងការការពារអ្នកចូលរួម ពីការធ្វើទុក្ខបុកម្នេញដែលអាចកើតមានឡើង ។

[៣៦] ឈ្មោះត្រូវបានប្តូរ ដើម្បីធានាឯកជនភាព និងការការពារអ្នកចូលរួម ពីការធ្វើទុក្ខបុកម្នេញដែលអាចកើតមានឡើង ។

## ការបៀតបៀនផ្លូវភេទគឺជាប្រភេទនៃការបៀតបៀនតាមប្រព័ន្ធអនឡាញ ដែលត្រូវបានរាយការណ៍ច្រើនជាងគេ

"មនុស្សប្រុសម្នាក់ដែលជាមិត្តក្នុងហ្វេសប៊ុក មិនដែលស្គាល់ពីមុន ផ្ញើរូបអាក្រាតខាងក្រោមគាត់មកខ្ញុំជាច្រើនរូបនាពេលយប់ ដោយមិនដឹងថាគាត់ចង់បានអីពីវាឡើយ មិនយល់ថាហេតុអ្វី ព្រោះមិនដែលស្គាល់គ្នាសោះ" ។

ស្ត្រីម្នាក់ដែលស្រឡាញ់ភេទផ្ទុយគ្នា អាយុជាង ២០ឆ្នាំ

"នាងខ្ញុំធ្លាប់បានជនមិនស្គាល់មុខផ្ញើរូបអាសអាភាសតាមMessenger ហើយនាងខ្ញុំក៏បានជេរទៅកាន់ពួកវា ហើយនាងខ្ញុំក៏ប្លុកវាទៅ"

ស្ត្រីម្នាក់ដែលស្រឡាញ់ទាំងពីរភេទ អាយុជាង ៣០ឆ្នាំ

"ពេលនឹងខ្ញុំដាក់រូបក្នុងប្រូហ្វាល់ខ្ញុំគឺរូបផ្កា ដល់ពេលគេឆាតមកយើងអត់តប ព្រោះធម្មតាជនប្លែកមុខ ខ្ញុំអត់ហ៊ានឆ្លើយតបក្នុងMessengerទេ របៀបថាគេផ្ញើរូបមកខ្ញុំអាក្រក់ៗ ប៉ុន្តែខ្ញុំអត់មានឆ្លើយតបហើយក៏អត់មានដោះស្រាយអីដែរ ព្រោះឱ្យតែខ្ញុំឃើញអ្នកផ្ញើចឹង គឺខ្ញុំប្លុកចោលម៉ង ខ្ញុំគិតថាគេបំពានខ្ញុំ" ។

ស្ត្រីម្នាក់ដែលស្រឡាញ់ភេទផ្ទុយគ្នា អាយុជាង ២០ឆ្នាំ

"មិនដែលស្គាល់គ្នាសោះបែរជាឆាតមកហៅទៅរួមភេទ ខ្ញុំមិនចូលចិត្តត្រង់ចំណុចនេះទាល់តែសោះ" ។

បុរសម្នាក់ដែលស្រឡាញ់បុរសដូចគ្នា អាយុជាង ២០ឆ្នាំ

"ធ្លាប់មានគេSay Hi ជាមួយយើង ហើយយើង Say Hi ទៅវិញ គេផ្ញើរូបអីចឹងមក ហើយខ្ញុំក៏ប្លុកចោលម៉ងទៅ ។ មានអារម្មណ៍ថាយើងអត់ចូលចិត្តគេផ្ញើសារបែបហ្នឹងមកហើយលក្ខណៈគេគិតមិនល្អយើងក៏អត់ចង់ទំនាក់ទំនងជាមួយ"។

ស្ត្រីម្នាក់ដែលស្រឡាញ់ស្ត្រីដូចគ្នា អាយុជាង ៣០ឆ្នាំ

"ជនអនាមិកជាច្រើនផ្ញើរូបអាសអាភាស ផ្ញើអីមកយើង ។ អ្នកខ្លះផ្ញើMessage ពេលដែលខ្ញុំផុសរូបអីចឹងទៅ ផ្ញើMessage ដូចចង់ Harass យើង ចង់ញ៉ែយើង ឬក៏ចង់បៀតបៀនយើង" ។

ស្ត្រីម្នាក់ដែលស្រឡាញ់ភេទផ្ទុយគ្នា អាយុជាង ៣០ឆ្នាំ

"ជួនកាលពួកគាត់ផ្ញើសារដោយផ្ទាល់មក ហើយគាត់ផ្ញើរូបមិនល្អអីមក និងនិយាយសម្ដីប៉ះពាល់ ជាលក្ខណៈបៀតបៀនផ្លូវភេទ ។ ជួនកាលអត់ដាក់រូប Profile ខ្លួនឯងក្នុងហ្នឹងទេ កុំឱ្យមានអ្នកមកផ្ញើសារបែបៗហ្នឹងទៀត" ។

ស្ត្រីម្នាក់ដែលស្រឡាញ់ភេទផ្ទុយគ្នា អាយុជាង ២០ឆ្នាំ

"ជនមិនស្គាល់មុខបានផ្ញើវីដេអូអាសអាភាសមកកាន់ខ្ញុំ ហើយវាជារឿងអសីលធម៌ណាស់ដែលបុគ្គលម្នាក់នោះធ្វើរឿងអ៊ីចឹងមកខ្ញុំ" ។

ស្ត្រីម្នាក់ដែលស្រឡាញ់ភេទផ្ទុយគ្នា អាយុជាង ២០ឆ្នាំ

"ឆាតមកសួរថាយើងធ្វើការនៅទីណា ហើយចង់ចេញក្រៅទៅជាមួយភ្ញៀវអត់ គេជាមេខ្យល់នាំទៅដាក់ភ្ញៀវ សួរពីតំលៃខ្លួនយើង$២០០ $៣០០ ទៅដេកជាមួយភ្ញៀវគេអត់" ។

ស្ត្រីម្នាក់ដែលស្រឡាញ់ភេទផ្ទុយគ្នា អាយុជាង ២០ឆ្នាំ

"មិត្តភក្តិក្នុង Facebook បានផ្ញើសារធម្មតា បន្ទាប់មកvideo call ដំបូងឃើញអត់អាវគិតថាខែក្តៅ ពេលទ្បើងឈរគឺស្រាតសោះ" ។

ស្ត្រីម្នាក់ដែលស្រឡាញ់ភេទផ្ទុយគ្នា អាយុជាង ៣០ឆ្នាំ

"ធ្លាប់មានមនុស្សមិនស្គាល់ប្រើប្រាស់account Facebook មិនស្គាល់ ផ្ញើរូបភាពអាក្រាតតាមរយៈ Messenger" ។

ស្ត្រីម្នាក់ដែលស្រឡាញ់ភេទផ្ទុយគ្នា អាយុជាង ៤០ឆ្នាំ

ស្ត្រីអ្នកឆ្លើយតបម្នាក់ក្នុងចំណោមប្រាំនាក់ បាននិយាយការណ៍ពីការទទួលបានសារជាអក្សរ រូបភាព វីដេអូ ឬសំណើបែបផ្លូវភេទ ដែលពួកគេពុំបានស្នើសុំ ។ ករណីនេះកើនដល់ ២៥% សម្រាប់ស្ត្រីដែលមានអាយុចន្លោះពី ១៨ឆ្នាំ ទៅ ២៤ឆ្នាំ ហើយក្រុមអ្នកស្រឡាញ់ភេទដូចគ្នាបានរាយការណ៍ ពីការបៀតបៀនតាមប្រព័ន្ធអនឡាញក្នុងអត្រាខ្ពស់ជាងនេះ (សូមមើលតួលេខទី១៦) ។

ស្ត្រីម្នាក់ អាយុជាង ៣០ឆ្នាំ បានប្រាប់អង្គការលីកាដូថា នាងត្រូវបានដាក់គោលដៅជាញឹកញាប់ជាមួយនឹងការបៀតបៀនផ្លូវភេទតាមប្រព័ន្ធអនឡាញ ។ នាងបានរៀបរាប់ថា "វាធ្វើឱ្យខ្ញុំប៉ះទង្គិចផ្លូវចិត្ត ខ្ញុំអត់ចង់លេងវាទៀតទេ" ។

៦៥%នៃអ្នកឆ្លើយតបដែលបានរាយការណ៍ថា ត្រូវបានបៀតបៀនផ្លូវភេទតាមប្រព័ន្ធអនឡាញ ធ្លាប់ជួបការបៀតបៀននេះលើសពីម្តង ។ អ្នកផ្តល់បទសម្ភាសជាច្រើន បានចែករំលែកថា ពួកគេត្រូវបានដាក់គោលដៅដោយជនបរទេស និងជនជាតិខ្មែរ ប៉ុន្តែភាគច្រើនពួកគេត្រូវបានដាក់គោលដៅដោយជនបរទេស ។ ភាគច្រើន វាកើតឡើងតាមរយៈកម្មវិធីផ្ញើសារជាលក្ខណៈឯកជន ភាគច្រើនកម្មវិធីឆាត និងបន្ទាប់មកគឺថេលេក្រាម ប៉ុន្តែអ្នកខ្លះបានលើកឡើងថា វាក៏កើតឡើងនៅក្នុងការសរសេរអធិប្បាយជាសាធារណៈផងដែរ ។ ដូចមានរៀបរាប់ខាងក្រោមនេះ ការប្លុកជនល្មើសគឺជាយន្តការដោះស្រាយទូទៅមួយ ប៉ុន្តែជារឿយៗ មិនសូវមានប្រសិទ្ធភាពទេ ។ ការបៀតបៀនផ្លូវភេទតាមប្រព័ន្ធអនឡាញ ក៏អាចនាំឱ្យមានអំពើហិង្សាក្នុងជីវិតរស់នៅផ្ទាល់ផងដែរ ។ ទោះបីជាមិនបានលើកឡើងនៅក្នុងរបាយការណ៍នេះក្តី ប៉ុន្តែនៅឆ្នាំមុន អង្គការលីកាដូបានអន្តរាគមន៍ករណីរំលោភសេពសន្ថវៈជាច្រើន ដែលជនល្មើសបានជួបស្ត្រី ឬកុមារដំបូង នៅលើកម្មវិធីហ្វេសប៊ុក ។

**តួលេខទី១៦៖ ភាគរយនៃក្រុមស្ទង់មតិនីមួយៗ ដែលបានរាយការណ៍ថា ធ្លាប់បានទទួលមាតិកាផ្លូវភេទ ដែលពួកគេពុំបានស្នើសុំ**




ជំនួសឱ្យការដោះស្រាយបញ្ហាបៀតបៀនផ្លូវភេទតាមប្រព័ន្ធអនឡាញ អាជ្ញាធរកម្ពុជាក្នុងករណីជាច្រើន បានបង្កើនការធ្វើទុក្ខបុកម្នេញ និងចាប់ខ្លួនស្ត្រីដាក់ពន្ធនាគារ ដោយសារជម្រើសស្លៀកពាក់ ឬការនិយាយស្តីរបស់ពួកគេលើហ្វេសប៊ុក ដោយរំលោភបំពានសិទ្ធិស្វ័យសម្រេចនៃរាងកាយ និងសេរីភាពសម្តែងមតិរបស់ពួកគេ ព្រមទាំងចូលរួមនៅក្នុងវប្បធម៌ស្តីបន្ទោសជនរងគ្រោះ ។ កាលពីខែកុម្ភៈ ឆ្នាំ២០២០ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានបញ្ជាឱ្យបង្ក្រាបអ្នកលក់ផលិតផលលើប្រព័ន្ធផ្សព្វផ្សាយសង្គម ដែលស្លៀកពាក់ "ស៊ិចស៊ីពេក" ឬប្រើប្រាស់សំលៀកបំពាក់ណា ដែលលេចលើលេចក្រោមខ្លាំងពេក ដោយអះអាងមិនត្រឹមត្រូវថា ទង្វើនេះអាចនាំឱ្យមានអំពើហិង្សាផ្លូវភេទ និងការជួញដូរមនុស្ស ព្រមទាំងបាន

● ● ●

- កាលពីខែកុម្ភៈ ឆ្នាំ២០២០ អ្នកលក់អនឡាញម្នាក់ត្រូវបានចាប់ដាក់ពន្ធនាគារ ដោយសាររូបភាព និងវីដេអូរបស់នាងស្លៀកពាក់ "ខោអាវស៊ិចស៊ីពេក" ដែលនាងបានបង្ហោះលើហ្វេសប៊ុក ។ នាងត្រូវបានផ្តន្ទាទោសពីបទចោទទាក់ទងនឹងការបង្ហាញកេរភេទ និងរូបភាពអាសអាភាស[៣៧] មុនពេលនាងត្រូវបានដោះលែងវិញក្នុងខែឧសភា ឆ្នាំ២០២០ ។
- នៅខែដដែលនេះ ស្ត្រីប្តូរភេទម្នាក់ ត្រូវបានចាប់ដាក់ពន្ធនាគារ ដោយសារវីដេអូមួយដែលនាងបានផ្ញើតាមរយៈការសន្ទនាជាលក្ខណៈឯកជន ដែលនាងស្នើផ្តល់សេវាកម្មផ្លូវភេទ ។ នាងត្រូវបានផ្តន្ទាទោសពីបទចោទពាក់ព័ន្ធនឹងរូបភាពអាសអាភាស[៣៨] មុនពេលត្រូវបានដោះលែងវិញក្នុងខែមិថុនា ឆ្នាំ២០២០ ។ នាងមិនបានទទួលការថែទាំសុខភាព ឬការព្យាបាលអរម៉ូននៅក្នុងពន្ធនាគារទេ ទោះបីជាទើបត្រូវបានវះកាត់ប្តូរភេទក៏ដោយ ។
- កាលពីខែកុម្ភៈ ឆ្នាំ២០២១ អ្នកលក់អនឡាញម្នាក់ ត្រូវបានកោះហៅទៅសាកសួរដោយស្នងការនគរបាលរាជធានីភ្នំពេញ ដោយសារតែការស្លៀកពាក់ "ស៊ិចស៊ី" និងប្រើប្រាស់ពាក្យពេចន៍ "អសីលធម៌" លើហ្វេសប៊ុក ដែល"ប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ស្ត្រីខ្មែរ" ។ នាងត្រូវបានបង្គាប់ឱ្យធ្វើការសុំទោសជាសាធារណៈ និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយដែលរឹតត្បិតការសម្តែងមតិរបស់នាងតាមប្រព័ន្ធអនឡាញ ។
- កាលពីខែមីនា ឆ្នាំ២០២១ មន្ត្រីនគរបាលម្នាក់ បានប្រឈមនឹងការដាក់ពិន័យ ដោយសារការបង្ហោះរូបភាពនាងកំពុងបំបៅដោះកូនលើគណនីហ្វេសប៊ុករបស់នាង ខណៈដែលកំពុងស្ថិតក្នុងឯកសណ្ឋាននគរបាល ។ នាងត្រូវបានបង្គាប់ឱ្យធ្វើការសុំទោស ចំពោះការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់ស្ត្រី និងការិយាល័យរបស់នាង និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយ ដើម្បីបញ្ឈប់អាកប្បកិរិយាបែបនេះទៀត ។ អាជ្ញាធរគ្រាន់តែលុបចោលការដាក់ពិន័យនេះ បន្ទាប់ពីមានការរិះគន់យ៉ាងខ្លាំងពីសាធារណជន ។
- កាលពីខែមិថុនា ឆ្នាំ២០២១ សារព័ត៌មានក្នុងស្រុក បានរាយការណ៍ថា អ្នកលក់អនឡាញម្នាក់ត្រូវបានចាប់ខ្លួន ទំនងដោយសារភាសាអាសគ្រាមបែបទាក់ទាញផ្លូវភេទ ដែលនាងបាននិយាយនៅក្នុងវីដេអូមួយលើហ្វេសប៊ុក ។

[៣៧] មាត្រា៣៨ និងមាត្រា៣៩ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក៏ដូចជាមាត្រា២៤៩ នៃក្រមព្រហ្មទណ្ឌ ។

[៣៨] មាត្រា៣៨ និងមាត្រា៣៩ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

អះអាងថា វាធ្វើឱ្យប៉ះពាល់ដល់តម្លៃប្រពៃណី និងវប្បធម៌ខ្មែរ ។[៣៩] ទោះបីជាមិនបានលើកមកបង្ហាញក្នុងការស្រាវជ្រាវនេះ សារព័ត៌មានក្នុងស្រុក និងផ្សេងទៀត បានរាយការណ៍ពី ស្ត្រីយ៉ាងតិច ៥នាក់ ដែលត្រូវបានអាជ្ញាធរកោះហៅទៅសាកសួរ ឬចាប់ដាក់ពន្ធនាគារ ដោយសារការស្លៀកពាក់ ឬការសម្តែងមតិរបស់ពួកគេលើហ្វេសប៊ុក ដែលត្រូវបានចាត់ទុកដោយមិនត្រឹមត្រូវថា មិនសមរម្យ ឬទាក់ទាញផ្លូវភេទខ្លាំងពេក

ការស្តីបន្ទោសនេះគឺជាបញ្ហាចាក់ឫសយ៉ាងជ្រៅនៅក្នុងទំនៀមទម្លាប់យេនឌ័រនៅក្នុងប្រទេសកម្ពុជា ដែលផ្តល់សិទ្ធិផ្លូវភេទ និងសិទ្ធិដទៃទៀតសម្រាប់បុរស ព្រមទាំងបង្កើតការរំពឹងទុកសម្រាប់ស្ត្រីឱ្យមានចរិតសុភាពរាបសា និងស្តាប់បង្គាប់ ។ ខណៈដែលការដាក់ទោសការស្លៀកពាក់របស់ស្ត្រីមិនទាន់មានចែងនៅក្នុងច្បាប់នាពេលបច្ចុប្បន្ន សេចក្តីព្រាងច្បាប់ស្តីពីសណ្តាប់ធ្នាប់សាធារណៈ មានចែងមាត្រាជាច្រើន ដែលពណ៌នាពីអ្វីដែលអាចស្លៀកពាក់បាននៅទីសាធារណៈ ។

ទំនៀមទម្លាប់យេនឌ័រ ការស្តីបន្ទោសជនរងគ្រោះ និងការបៀតបៀនផ្លូវភេទ កំពុងធ្វើឱ្យស្ត្រីត្រួតពិនិត្យចាប់ពិរុទ្ធខ្លួនឯងលើប្រព័ន្ធផ្សព្វផ្សាយសង្គម ។ ស្ត្រីជាច្រើនដែលបានចូលរួមក្នុងការស្រាវជ្រាវនេះ មានអារម្មណ៍ថា ពួកគេមិនអាចដាក់រូបភាពពួកគេជារូបប្រូហ្វាល់ដោយពុំមានការបៀតបៀនផ្លូវភេទទេ ។ ស្ត្រីម្នាក់ អាយុជាង ៣០ឆ្នាំបានរិះគន់ទាំងមិនអស់ចិត្តថា "បើយើងស្លៀកពាក់ស៊ិចស៊ី ហើយបង្ហាញលើរូបប្រូហ្វាល់ កំហុសនឹង ធ្លាក់លើស្ត្រី មិនមែនមកពីបុរសទេ" ។





**"ពេលបញ្ចេញសកម្មភាពចឹងទៅដូចជាអត់ឱ្យតម្លៃមកលើយើងជាមនុស្សស្រីអ៊ីចឹង"**

សុភា[៤០] អាយុ ២៣ឆ្នាំ ជានិស្សិត ដែលប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម ដើម្បីចែករំលែកព័ត៌មាន និងផ្ញើសារជាមួយអ្នកដទៃ ដើម្បីអនុវត្តការប្រើប្រាស់ភាសាអង់គ្លេស ។ ប៉ុន្តែជារឿយៗ នាងតែងទទួលបានសារបែបផ្លូវភេទដែលនាងមិនចង់បាន ។ មានពេលមួយ បុរសខ្មែរម្នាក់បានស្នើនាង (Add) ធ្វើជាមិត្ត និងចាប់ផ្តើមឆ្លើយឆ្លងគ្នា ។ ភ្លាមៗ បុរសនោះបានផ្ញើរូបអាសអាភាសមក និងស្នើសុំនាងជួបដោយផ្ទាល់ ។

សុភា បានរៀបរាប់ថា "ដំបូងនិយាយប្រាប់គាត់ដែរថាកុំឱ្យគាត់ធ្វើអ៊ីចឹងៗ វាអត់ល្អអ៊ីចឹងទៅបានខ្ញុំប្លុកគាត់" ។ សុភាមិនបានជួបបុរសនោះដោយផ្ទាល់ទេ ប៉ុន្តែបានធ្លុះបញ្ចាំងពីគ្រោះថ្នាក់ដែលអាចជួបសម្រាប់អ្នកផ្សេងទៀត "យើងគិតថាគ្រាន់តែចង់ទំនាក់ទំនងបែបធម្មតា ប៉ុន្តែពេលបញ្ចេញសកម្មភាពចឹងទៅដូចជាអត់ឱ្យតម្លៃមកលើយើងជាមនុស្សស្រីអ៊ីចឹង" ។ នាងមានអារម្មណ៍ថា ការប្លុកបុរសនោះបានជួយខ្លះដែរ ប៉ុន្តែនាងមិនមានទំនុកចិត្តថា វានឹងបញ្ឈប់គេមិនឱ្យទាក់ទងមកនាងម្តងទៀតនោះទេ ។

សុភាធ្លាប់មានបទពិសោធន៍ស្រដៀងគ្នានេះជាមួយជនបរទេសទាំងស្ត្រីនិងបុរសដែលបានចែករំលែករូបភាពអាសអាភាសរបស់ពួកគេមុនពេលស្នើសុំរូបភាពពីនាងម្តងហើយម្តងទៀត។ពេលមួយនៅសាលារៀនមិត្តភក្តិរបស់សុភាកំពុងប្រើប្រាស់ទូរស័ព្ទរបស់សុភាចំពេលដែលមានមនុស្សផ្ញើរូបអាសអាភាសឱ្យនាង។សុភាមានអារម្មណ៍ថាមិត្តភក្តិនាងនឹងវាយតម្លៃនាងទោះបីជានាងដឹងថាមិត្តភក្តិនាងក៏ធ្លាប់ជួបបញ្ហាស្រដៀងគ្នានេះ។នាងបាននិយាយថា "នៅពេលដែលគាត់ផ្ញើនឹង ធ្វើឱ្យខ្ញុំខ្មាសគេ" ។

---

[៣៩] សូមមើលលិខិតចំហរួម "សិទ្ធិស្ត្រីជាសិទ្ធិមនុស្ស៖ កម្ពុជាត្រូវគោរពសិទ្ធិស្វ័យសម្រេច សិទ្ធិសម្តែងមតិ អារម្មណ៍ និងជម្រើសរាងកាយរបស់ស្ត្រី" ចេញផ្សាយខែកុម្ភៈ ឆ្នាំ២០២០ ។ ដកស្រង់ពី៖ https://www.cchrcambodia.org/media/files/press_release/748_oltpwa1k_kh.pdf

[៤០] មាត្រា៣៨ និងមាត្រា៣៩ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក៏ដូចជាមាត្រា២៤៩ នៃក្រមព្រហ្មទណ្ឌ ។

## ការរើសអើងកើតឡើងញឹកញាប់ ជាពិសេសសម្រាប់ក្រុមអ្នកស្រឡាញ់ភេទដូចគ្នា

អ្នកឆ្លើយតបចំនួន ៨% បានរាយការណ៍ពីការរើសអើង ឬប្រឈមនឹងភាសារើសអើងលើប្រព័ន្ធអនឡាញ ។ អ្នកឆ្លើយតបជាអ្នកស្រឡាញ់ភេទដូចគ្នា បានរាយការណ៍ពីបទពិសោធន៍នៃការរើសអើងតាមប្រព័ន្ធអនឡាញស្ទើរតែជិតបីដងនៃអត្រាខាងលើនេះ (សូមមើលតួលេខទី១៧) ។ ក្នុងចំណោមក្រុមអ្នកស្រឡាញ់ភេទដូចគ្នា ដែលបានរាយការណ៍ពីការរើសអើងតាមប្រព័ន្ធអនឡាញនោះ ពួកគេទាំងអស់ (លើកលែងតែម្នាក់ប៉ុណ្ណោះ) ធ្លាប់ជួបការរើសអើងនោះលើសពីម្តង ។

បុរសស្រឡាញ់ភេទដូចគ្នាម្នាក់ អាយុជាង ៣០ឆ្នាំ បានរៀបរាប់ថាលោកបានជួបការបៀតបៀនតាមប្រព័ន្ធអនឡាញពីសំណាក់មិត្តភក្តិ និងសហការី ហើយថាមនុស្សបានចូលសរសេរអធិប្បាយលើការបង្ហោះសាររបស់លោកដោយការប្រមាថ ឬប្រើប្រាស់ពាក្យពេចន៍បែបរើសអើងអ្នកស្រឡាញ់ភេទដូចគ្នា ។

ស្ត្រីម្នាក់ដែលស្រឡាញ់ទាំងពីរភេទ អាយុ២០ឆ្នាំជាងបន្តិច បានរាយការណ៍ពីការបៀតបៀនតាមប្រព័ន្ធអនឡាញ ពាក់ព័ន្ធនឹងយេនឌ័រ និន្នាការភេទ និងរូបរាងខាងក្រៅរបស់នាង ដែលបង្ខំឱ្យនាងឈប់ប្រើប្រាស់ប្រព័ន្ធអនឡាញ ។ នាងបាននិយាយថា "ខ្ញុំមិនហ៊ានបង្ហោះរូបរបស់ខ្ញុំនៅក្នុងបណ្តាញសង្គមទេ ។ រាល់រូបដែលខ្ញុំបង្ហោះ អ្នកcomments តែងបង្ហាញភាពមិនពេញចិត្តមកលើករូបរាងកាយខ្ញុំ" ។

អ្នកផ្តល់បទសម្ភាសន៍ពីរនាក់ ក៏បានចែករំលែកបទពិសោធន៍នៃការរើសអើង ដោយផ្អែកលើជាតិពន្ធដាក់ស្តែង ឬដែលអាចមើលដឹង ដូចជាការនិយាយស្តី ឬរូបរាងដូចជនជាតិវៀតណាម ។ ស្ត្រីខ្មែរម្នាក់ អាយុជាង ៣០ឆ្នាំ បានឆ្លុះបញ្ចាំងការសរសេរអធិប្បាយរបស់មនុស្សនៅលើការបង្ហោះសាររបស់នាង ។ នាងបាននិយាយថា "នៅពេលពាក្យថាយួន[៤១] មួយម៉ាត់ប្រើមកលើមនុស្សស្រីដូចខ្ញុំ វាមានអារម្មណ៍ថាពាក្យនឹងគឺ Bully មើលងាយម៉ង" ។ ការស្រាវជ្រាវបន្ថែមទៀត គឺពិតជាមានសារៈសំខាន់ ដើម្បីចងក្រងជាឯកសារនៃការរើសអើងតាមប្រព័ន្ធអនឡាញ ដែលប្រឈមដោយជនជាតិភាគតិចនៅក្នុងប្រទេសកម្ពុជា ។

**តួលេខទី១៧៖ ភាគរយនៃក្រុមស្ទង់មតិនីមួយៗ ដែលបានរាយការណ៍ថាធ្លាប់ត្រូវបានរើសអើងតាមប្រព័ន្ធអនឡាញ**






[៤១] ត្រូវបានប្រើប្រាស់ជាទូទៅថាជា ការចោទប្រកាន់ជាតិសាសន៍ ដោយដាក់គោលដៅលើជនជាតិវៀតណាម ។

## ការបៀតបៀនតាមប្រព័ន្ធអនឡាញ កំពុងរុញច្រានមនុស្សឱ្យឃ្លាតឆ្ងាយពីប្រព័ន្ធផ្សព្វផ្សាយសង្គម

ក្នុងចំណោមអ្នកចូលរួមស្ទង់មតិដែលបានរាយការណ៍ពីការបៀតបៀនតាមប្រព័ន្ធអនឡាញ ៣៧៣៦%នៃពួកគេកាត់បន្ថយការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម ឈប់ប្រើប្រាស់ទាំងស្រុង ឬលុបគណនីរបស់ពួកគេចោលតែម្តង (សូមមើលតួលេខទី១៨) ។ ជាពិសេស ស្ត្រី និងយុវជនទំនងជាកាត់បន្ថយការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម បន្ទាប់ពីត្រូវបានដាក់គោលដៅដោយការបៀតបៀនតាមប្រព័ន្ធអនឡាញ (សូមមើលតួលេខទី១៩) ។

ការត្រួតពិនិត្យចាប់ពិរុទ្ធខ្លួនឯងគឺជា យន្តការដោះស្រាយទូទៅមួយបន្ទាប់ពីរងការបៀតបៀនតាមប្រព័ន្ធអនឡាញ ។ នេះរាប់បញ្ចូលពីស្ត្រីដែលមិនបង្ហោះរូបភាពរបស់ពួកគេធ្វើជារូបភាពប្រូហ្វាល់ ដើម្បីទប់ស្កាត់ការបៀតបៀនតាមប្រព័ន្ធអនឡាញ រហូតដល់មនុស្សដែលជ្រើសរើសមិនបញ្ចេញមតិលើបញ្ហា ឬការលុបសារបង្ហោះណាដែលមាន ឬអាចទទួលបានការឆ្លើយតបបែបគ្រោះថ្នាក់ពីសំណាក់អាជ្ញាធរ ឬភាគីផ្សេងទៀត ។

**តួលេខទី១៨៖ ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមក្នុងចំណោមអ្នកចូលរួមស្ទង់មតិ ក្រោយពីរងការបៀតបៀនតាមប្រព័ន្ធអនឡាញ**




**តួលេខទី១៩៖ ភាគរយនៃក្រុមនីមួយៗ ដែលបានកាត់បន្ថយការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម ឬឈប់ប្រើប្រាស់ទាំងស្រុង បន្ទាប់ពីរងការបៀតបៀនតាមប្រព័ន្ធអនឡាញ**






**“គាត់និយាយថា "ប្រយ័ត្នមានគ្រោះថ្នាក់ បើជាខ្លួនខ្ញុំអត់អីទេ ប៉ុន្តែក្រែងលោគ្រួសារខ្ញុំអ៊ីចឹងទៅណា”**

លក័្ខ[៤២] ជាស្រ្តីម្នាក់អាយុ ២៦ឆ្នាំ ដែលមានអារម្មណ៍ថា នាងមិនអាចបញ្ចេញមតិយោបល់នៅលើប្រព័ន្ធអនឡាញបានទៀតទេ ។ នាងបានត្អូញត្អែរថា "ធម្មតាបើសិនជាយើងបញ្ចេញមតិលើសលួស អាចនឹងមានបញ្ហា ហើយព័ត៌មានខ្លះយើងអត់គួរសូម្បីតែសរសេរ...អាចពាក់ព័ន្ធជាមួយការរកស៊ី ឬមួយក៏ជំនួញរបស់អ្នកធំ" ។

នៅពេលមួយនោះ លក័្ខបានទៅទស្សនាតំបន់មួយនៅទីក្រុង ។ នាងបានបង្ហោះវីដេអូមួយស្តីពីទឹកន្លែងនោះនៅលើហ្វេសប៊ុក ជាទីតាំងដែលផ្នែកនៃទន្លេត្រូវបានចាក់លុបដោយការបូមខ្សាច់ដើម្បីធ្វើការអភិវឌ្ឍន៍ ។ ការលុបផ្ទៃទឹក ដើម្បីធ្វើការអភិវឌ្ឍន៍ជាលក្ខណៈឯកជន គឺជាបញ្ហាបរិស្ថាន និងសិទ្ធិមនុស្ស ជាច្រើនឆ្នាំមកហើយនៅក្នុងប្រទេសកម្ពុជា ។ ភ្លាមៗ មនុស្សម្នាក់បានសរសេរអធិប្បាយ ដោយសួរ លក័្ខ ថានាងមិនភ័យខ្លាចក្នុងការបង្ហោះសារនោះទេ? និងបានចង្អុលបង្ហាញថា វាអាចធ្វើឱ្យគ្រោះថ្នាក់ដល់គ្រួសាររបស់នាង ។ នាងបាននិយាយថា "អាចនិយាយបានថាជាការរំឭកយើងក៏ថាបាន ឬមួយក៏វាអាចចូលពាក្យពេចន៍ខ្លះ គំរាមដែរ ។ ខ្ញុំមើលទៅគាត់ដូចជាអ្នកធ្វើការខាងរដ្ឋដែរ អ្នកដែលចូល Comments គឺមានតែម្នាក់ហ្នឹងទេ បន្ទាប់មកខ្ញុំក៏បានលុបចេញទៅ" ។

លក័្ខ ក៏មានអារម្មណ៍ទទួលរងការត្រួតពិនិត្យចាប់ពិរុទ្ធដោយអ្នកផ្សេងយ៉ាងប៉ិនប្រសប់ ។ នាងបានចូលរួមក្រុមថេលេក្រាមមួយ ដើម្បីពិភាក្សាផ្លូវច្បាប់ជាមួយសមាជិកប្រមាណជា ៤០០០០នាក់ ។ នៅពេលនាងបានសរសេរអធិប្បាយនៅក្នុងក្រុមដូចជាអំពើនគរបាលចរាចរណ៍ នាងត្រូវបានចោទប្រកាន់ថាមានទំនាក់ទំនងនយោបាយ ។

លក័្ខ ព្រួយបារម្ភពីសុវត្ថិភាពផ្ទាល់ខ្លួននាង ប៉ុន្តែក៏បានបញ្ជាក់ដែរថា "ខ្ញុំគិតថាសម្រាប់ម្ចាស់គេម៉ង ក៏គេគិតថាយើងមិនមែនជាបញ្ហាសម្រាប់គេដែរ ណាស់តែអាតូចៗក្រោមគាត់ដែលចេះតែមកគំរាមយើង" ។ ប៉ុន្តែវានៅតែប៉ះពាល់ដល់ការបញ្ចេញមតិរបស់នាងតាមប្រព័ន្ធអនឡាញ ។ នាងបាននិយាយថា "បណ្តាញសង្គមឥឡូវហ្វេសប៊ុកអីខ្ញុំអត់សូវលេងផង អត់សូវចំណាយពេលទៅលើវា យើងអត់សូវដូចកាលពីមុនដែលយើងលេង គ្រាន់តែមើលហើយចោលចឹងទៅ" ។

[៤២] ឈ្មោះត្រូវបានប្តូរ ដើម្បីធានាឯកជនភាព និងការការពារអ្នកចូលរួម ពីការធ្វើទុក្ខបុកម្នេញដែលអាចកើតមានឡើង ។ អ្នកចូលរួមម្នាក់នេះ ក៏ត្រូវបានរំលោភ ឯកជនភាពរបស់នាងលើប្រព័ន្ធអនឡាញផងដែរ ដូចដែលបានបង្ហាញនៅក្នុងករណីសិក្សានៅទំព័រ ២២ នៃរបាយការណ៍នេះ ។

## ការបៀតបៀនតាមប្រព័ន្ធអនឡាញអាចប៉ះពាល់ធ្ងន់ធ្ងរដល់ជីវិតរស់នៅផ្ទាល់

**តួលេខទី២០៖ កម្រិតនៃការប៉ះពាល់ផ្លូវចិត្តបង្កឡើងដោយការបៀតបៀនតាមប្រព័ន្ធអនឡាញក្នុងចំណោមមនុស្សដែលជួបបញ្ហានេះ**




ក្នុងចំណោមមនុស្សដែលបានរាយការណ៍ពីការបៀតបៀនតាមប្រព័ន្ធអនឡាញ ៨០%នៃពួកគេយល់ថា មានការរំខានចិត្តតិចតួច ឬខ្លាំង (សូមមើលតួលេខទី២០) និង៧១%ទៀត បានរាយការណ៍ពីផលប៉ះពាល់អវិជ្ជមានយ៉ាងតិចមួយ ។

អ្នកឆ្លើយតបភាគច្រើន បានរាយការណ៍ពីភាពភ័យខ្លាចនៃសុវត្ថិភាពបុគ្គលរបស់ពួកគេ ឬសុវត្ថិភាពមនុស្សដែលស្និទ្ធជាមួយពួកគេ ដោយមានអារម្មណ៍ថាបានដកខ្លួន ឬមិនសូវមានទំនាក់ទំនងជាមួយសង្គម ការបាត់បង់ទំនុកចិត្តលើខ្លួនឯងជាងមុន ឬមានបញ្ហាជាមួយមិត្តភក្តិ គ្រួសារ ទំនាក់ទំនងដៃគូ ឬសហគមន៍ដោយសារការបៀតបៀនតាមប្រព័ន្ធអនឡាញ ។ អ្នកខ្លះ បានរាយការណ៍ពីផលប៉ះពាល់ធ្ងន់ធ្ងរពាក់ព័ន្ធនឹងការបៀតបៀនតាមប្រព័ន្ធអនឡាញដូចជាគ្រោះថ្នាក់លើរូបរាងកាយ ឬអំពើហិង្សាដោយផ្ទាល់ បញ្ហាលំបាកក្នុងការស្វែងរកការងារធ្វើ ការសិក្សា កន្លែងស្នាក់នៅ ឬសេវាកម្ម ឬបទពិសោធន៍នៃការគិតធ្វើអត្តឃាត ជាដើម ។ យុវជន និងក្រុមអ្នកស្រឡាញ់ភេទដូចគ្នា បានរាយការណ៍ពីផលប៉ះពាល់អវិជ្ជមានញឹកញាប់ជាងគេ (សូមមើលតួលេខទី២១) ។

ភាគច្រើនអ្នកឆ្លើយតបជាស្ត្រី ទំនងជារាយការណ៍ពីការបាត់បង់ទំនុកចិត្តជាងមុន ច្រើនជាងបុរស (២២%នៃស្ត្រី ប្រៀបធៀបនឹងបុរស ១២%) ឬការឃ្លាតឆ្ងាយពីសង្គម (២៩%នៃស្ត្រី ប្រៀបធៀបនឹងបុរស ១៤%) ដោយសារការបៀតបៀនតាមប្រព័ន្ធអនឡាញ ។ ភាគច្រើនអ្នកឆ្លើយតបជាសកម្មជន ទំនងជាព្រួយបារម្ភពីបញ្ហាសុវត្ថិភាពបុគ្គលច្រើនជាងគេ ដោយ៣៩%នៃអ្នកដែលធ្លាប់ត្រូវបានធ្វើទុក្ខបុកម្នេញតាមប្រព័ន្ធអនឡាញ មានការភ័យខ្លាចពីសុវត្ថិភាពបុគ្គលរបស់ពួកគេ ឬសុវត្ថិភាពមនុស្សដែលជិតស្និទ្ធជាមួយពួកគេ ។

ខណៈដែលប្រភេទមួយចំនួននៃការបៀតបៀនតាមប្រព័ន្ធអនឡាញត្រូវបានរាយការណ៍ដោយអ្នកឆ្លើយតបមួយចំនួនតូច ពួកគេបានរាយការណ៍ពីបទពិសោធន៍នៃផលប៉ះពាល់ធ្ងន់ធ្ងរ ។ ផលប៉ះពាល់ទាំងនេះ អាចអូសបន្លាយរយៈពេលវែង ដោយសារវាជាការលំបាកក្នុងការលុបអ្វីមួយពីអ៊ីនធឺណិតជាអចិន្ត្រៃយ៍ ។ ឧទាហរណ៍ អ្នកឆ្លើយតប៣០នាក់ បានរាយការណ៍ថា ព័ត៌មានឯកជនរបស់ពួកគេត្រូវបានទម្លាយ ។ ពួកគេយ៉ាងតិចណាស់ពាក់កណ្តាល បានរាយការណ៍ពីភាពភ័យខ្លាចនៃសុវត្ថិភាពបុគ្គលរបស់ពួកគេ មានបញ្ហាជាមួយមិត្តភក្តិ គ្រួសារ ទំនាក់ទំនងដៃគូ ឬសហគមន៍ និងចាប់អារម្មណ៍ជាមួយសង្គមតិចជាងមុន ដោយសារការបៀតបៀនតាមប្រព័ន្ធអនឡាញ ។ មួយភាគប្រាំនៃពួកគេ ធ្លាប់មានគំនិតចង់ធ្វើអត្តឃាត និងស្ទើរតែពាក់កណ្តាលកាត់បន្ថយការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម ។

ក្នុងចំណោមមនុស្ស៣០នាក់ ដែលបានរាយការណ៍ថាត្រូវបានបៀតបៀនតាមប្រព័ន្ធអនឡាញ ៥នាក់ធ្លាប់បានទទួលរងគ្រោះថ្នាក់ ឬអំពើហិង្សាលើរូបរាងកាយ ហើយជាងពាក់កណ្តាលមានការភ័យខ្លាចពីសុវត្ថិភាពបុគ្គលរបស់ពួកគេ ឬអ្នកដែលជិតស្និទ្ធជាមួយពួកគេ ។

អ្នកឆ្លើយតបស្ទង់មតិ១០នាក់ បានរាយការណ៍ថា រូបភាព ឬវីដេអូឯកជនរបស់ពួកគេ ត្រូវបានចែករំលែកដោយគ្មានការអនុញ្ញាតពីពួកគេ និង/ឬពួកគេត្រូវបានគំរាមកំហែងក្នុងការចែករំលែកនេះ ។ ៥នាក់ក្នុងចំណោមពួកគេ ១០នាក់ បានរាយការណ៍ពីការគិតចង់ធ្វើអត្តឃាតដោយសារតែការបៀតបៀនតាមប្រព័ន្ធអនឡាញ និង៧នាក់ភ័យខ្លាចពីសុវត្ថិភាពបុគ្គលរបស់ពួកគេ ឬអ្នកដែលជិតស្និទ្ធជាមួយពួកគេ ។

ការរំពឹងចង់បានក្នុងសង្គម ដែលគ្រប់គ្រង និងកម្រិតការសម្តែងមតិ និងសេរីភាពខាងផ្លូវភេទរបស់ស្ត្រី អាចធ្វើឱ្យផលប៉ះពាល់នៃការបៀតបៀនតាមប្រព័ន្ធអនឡាញទៅលើស្ត្រី កាន់តែមានស្ថានភាពអាក្រក់ថែមទៀត ។ ស្ត្រីម្នាក់ អាយុជាង២០ឆ្នាំ បានប្រាប់អង្គការលីកាដូថា នាងបានឃើញក្រុមផ្ញើសារតាមហ្វេសប៊ុក ដែល សមាជិកក្រុមជាបុរសជនជាតិខ្មែរជាង១០នាក់ បានចែករំលែករូបភាពអាសអាភាសរបស់ស្ត្រីយ៉ាងតិច ៤នាក់ ដោយទំនងជាពុំមានការអនុញ្ញាតពីពួកគេទេ រួមមានការចែកចាយដោយមិត្តប្រុសរបស់ស្ត្រីម្នាក់ក្នុងចំណោមពួកគេ៤នាក់នោះផងដែរ ។ នាងបានរៀបរាប់ថា "ម្នាក់ប្រុសនឹងក៏យករូបថតម្នាក់ស្រីនឹងទាំងអាក្រាត ដាក់ចូលក្នុងគ្រុបដើម្បីឱ្យពួកម៉ាក គាត់ឆ្លើយឆ្លងគ្នា...ពេលឃើញ ចឹងហើយភ័យដល់ខ្លួនឯង ប៉ុន្តែបើថាខ្ញុំមានរូបថតអាក្រាត ខ្ញុំអត់មានទេ ខ្ញុំខ្លាចមានរឿងនឹងកើតឡើង ឧទាហរណ៍គេយករូបថតយើងធម្មតា គេយកទៅ Edit" ។

**តួលេខទី២១៖ ភាគរយនៃអ្នកឆ្លើយសំណួរស្ទង់មតិ ដែលធ្លាប់ត្រូវបានបៀតបៀនតាមប្រព័ន្ធអនឡាញ ដោយគិតពីផលប៉ះពាល់អវិជ្ជមានដែលពួកគេបានរាយការណ៍**




*អនុញ្ញាតឱ្យមានចម្លើយច្រើន ការឆ្លើយសំណួរមិនមែនជាកាតព្វកិច្ចទេ*

> **[ក្រុមហ៊ុនផ្តល់ប្រាក់កម្ចី] វា add telegram ទៅគេ...ឱ្យតែមានខាងគេប្រើTelegram វាadd គេចូល ហើយវាផ្ញើរូបភាពចូល**

ភាព[៤៣] ជាស្ត្រីម្នាក់អាយុជាង៣០ឆ្នាំ បានចំណាយពេលឥតការងារធ្វើជាងកន្លះឆ្នាំ បន្ទាប់ពីនាងបាត់បង់ការងារនៅរោងចក្រកាត់ដេរ ។ នាងចាប់ផ្តើមខ្ចីប្រាក់កម្ចីខ្នាតតូចពីក្រុមហ៊ុនមួយចំនួន ដែលនាងបានស្គាល់តាមហ្វេសប៊ុក ។ ដោយប្រឈមនឹងការរឹតត្បិតនៃជំងឺកូវីដ-១៩ ភាព បានជួបការលំបាកក្នុងការបង់សងប្រាក់កម្ចីវិញ ហើយក្រុមហ៊ុនបានចាប់ផ្តើមដាក់សម្ពាធសមាជិកគ្រួសារនាង ។ ភាព បានទាក់ទងក្រុមហ៊ុនផ្តល់ប្រាក់កម្ចីមួយទៀតតាមហ្វេសប៊ុក ដោយចុះឈ្មោះលើកម្មវិធីទូរស័ព្ទដៃរបស់ពួកគេ ហើយបន្ទាប់មកបានទំនាក់ទំនងជាមួយពួកគេតាមរយៈកម្មវិធីថេលេក្រាម និងទូរស័ព្ទដៃ ។ កម្មវិធីនោះបានផ្តល់សិទ្ធិឱ្យក្រុមហ៊ុនអាចចូលប្រើប្រាស់បញ្ជីទំនាក់ទំនងរបស់ភាពបាន ។

ក្រុមហ៊ុនផ្តល់ប្រាក់កម្ចីថ្មី បានស្នើផ្តល់ប្រាក់កម្ចីឱ្យភាពចំនួន ១០០០ដុល្លារ ដែលនាងបានគ្រោងថានឹងយកទៅប្រើប្រាស់ ដើម្បីបង់សងបំណុលតូចៗទាំងនោះ ។ បន្ទាប់ពីភាពផ្តល់ឯកសារបញ្ជាក់អត្តសញ្ញាណ និងទីតាំងរបស់នាងរួចមក នាងត្រូវបានប្រាប់ឱ្យផ្ញើរូបអាក្រាតខ្លួនរបស់នាងបីសន្លឹកឱ្យពួកគេ ។ ភាព មានការស្ទាក់ស្ទើរ ប៉ុន្តែបុគ្គលិកក្រុមហ៊ុនបានធានាអះអាងចំពោះនាង ។ ភាព និយាយឡើងវិញថា "គាត់ថាមានអ្នកផ្សេងទៀតក៏គេធ្វើអ៊ីចឹងដែរ...គេនិយាយថាគ្រាន់តែតម្កល់ទេ គេអត់ធ្វើអីយើងទេអូន" ។ បន្ទាប់ពីក្រុមហ៊ុនបានបញ្ជាក់ប្រាប់ថា រូបភាពអាក្រាតទាំងនោះនឹងត្រូវលុបចោលវិញនៅពេលនាងបានសងប្រាក់អស់ ភាពបានផ្ញើរូបទាំងនោះតាមថេលេក្រាម ។ ក្រោយមក ក្រុមហ៊ុនបានទាមទារវីដេអូអាក្រាតមួយរបស់នាង និងទំនាក់ទំនងលម្អិតរបស់សមាជិកគ្រួសារជិតស្និទ្ធមិត្តភក្តិ និងសហការី សរុបចំនួន៨នាក់ ។ ចុងក្រោយ ក្រុមហ៊ុនបានទាមទារវីដេអូមួយរបស់ភាព ដែលនិយាយយល់ព្រមឱ្យពួកគេប្រើប្រាស់រូបភាព និងបញ្ជីទំនាក់ទំនងរបស់មិត្តភក្តិ និងគ្រួសារនាង ប្រសិនបើនាងមិនសងប្រាក់វិញទេ ។ ក្រោយមក ភាព បានទទួលប្រាក់តិចជាង ៥០០ដុល្លារ ដោយក្រុមហ៊ុនអះអាងថា ចំណែកផ្សេងទៀតនៃប្រាក់សរុបចំនួន ១០០០ដុល្លារ ត្រូវបានកាត់ជាថ្លៃសេវារត់ការ ។

នៅពេល ភាព គ្មានលទ្ធភាពបង់សងបំណុលវិញ ក្រុមហ៊ុនបានទាក់ទងទៅនាងជាបន្តបន្ទាប់ដោយប្រើប្រាស់លេខទូរស័ព្ទប្រហែល១០ខ្សែផ្សេងគ្នា ។ ពួកគេបានបដិសេធសំណើរបស់ភាពក្នុងការបង់សងប្រាក់មួយចំនួនតូចក្នុងរយៈពេលយូរ ហើយចាប់ផ្តើមទាក់ទងមិត្តភក្តិ និងគ្រួសាររបស់នាង ។ នាងបានរៀបរាប់ថា "ពេលយើង អត់reply វាទាក់ទងទៅអ្នកផ្សេងរំខានគេ...ឱ្យតែយើងឆ្លើយតប វាអត់ខលទៅអ្នកផ្សេងទេ" ។

ភាព បានឃើញស្ត្រីម្នាក់ទៀត បង្ហោះអំពីបញ្ហាដូចគ្នានៅលើហ្វេសប៊ុក ។ ស្ត្រីម្នាក់នោះ បាននិយាយថា នាងបានបង់ប្រាក់សងក្រុមហ៊ុនគ្រប់ចំនួនហើយ ប៉ុន្តែក្រុមហ៊ុននៅតែបន្តគំរាមកំហែងនាង និងបានបដិសេធប្រាប់នាងពីចំនួនប្រាក់សរុបដែលបានជំពាក់ ។ ភាព បានដាក់ពាក្យបណ្តឹងទៅកាន់នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យានៃក្រសួងមហាផ្ទៃ ។

នាងបាននិយាយថា "ប៉ុន្តែចាប់ពីថ្ងៃនោះមក សូម្បីតែម្តងក៏អត់បានទទួល[ដំណឹង]អីដែរ...ខ្ញុំមានអារម្មណ៍ថាអស់សង្ឃឹមណាស់" ។

ដើម្បីដាក់សម្ពាធលើ ភាព ក្រុមហ៊ុនបានបង្កើតក្រុមថេលេក្រាមដោយមនុស្ស៧នាក់ តាមរយៈបញ្ជីទំនាក់ទំនងទូរស័ព្ទរបស់ភាព និងបានចែកចាយរូបថតស្រ្តីននៃរូបអាក្រាតរបស់នាងទាំងបីសន្លឹក ។ ប្រតិកម្មដំបូងរបស់ប្តីនាងគឺ គាត់ចង់លែងលះគ្នា ប៉ុន្តែក្រោយពីគាត់ដឹងថា ភាព ត្រូវបានដាក់គោលដៅដោយអយុត្តិធម៌ គាត់ក៏បានផ្លាស់ប្តូរចិត្តវិញ ។ ក្រោយមក ភាព បានដាក់ពាក្យបណ្តឹងអំពីក្រុមហ៊ុនទៅកាន់កងរាជអាវុធហត្ថ ដែលត្រូវបានស្គាល់ថាជា អាវុធហត្ថ ដែលមានកាតព្វកិច្ចលើករណីស៊ីវិលនៅកម្ពុជា ។ ប៉ុន្តែក្រុមហ៊ុនបានបន្តគំរាមកំហែងភាព ។ ចាប់ពីពេលនោះមក ពួកគេបានបង្ហោះរូបរបស់ភាព និងគ្រួសារនាង រួមមានកូនៗរបស់នាង នៅលើហ្វេសប៊ុក ដោយ

---

[៤៣] ឈ្មោះត្រូវបានប្តូរ ដើម្បីធានាឯកជនភាព និងការការពារអ្នកចូលរួម ពីការធ្វើទុក្ខបុកម្នេញដែលអាចកើតមានឡើង ។

*ចោទប្រកាន់នាងថាជាមនុស្សបោកប្រាស់ និងបានចែករំលែកតំណភ្ជាប់នោះជាមួយគ្រួសារនាង ។ នាងបាននិយាយថា "បើសិនជាខ្ញុំម្នាក់ឯងខ្ញុំអត់សូវខ្វល់ទេ... និយាយរួមទៅប៉ះដល់គ្រួសារខ្ញុំ ប៉ះពាល់ដល់កូនៗខ្ញុំ អារម្មណ៍មួយនេះខ្ញុំទទួលយកអត់ទាន់បាន់ទេ" ។ សារនោះត្រូវបានបង្ហោះសារជាថ្មីលើហ្វេសប៊ុក ប៉ុន្តែមិនមានភស្តុតាងថាក្រុមហ៊ុនហ្វេសប៊ុកបានចាត់វិធានការណាមួយលើករណីនេះទេ ហើយហ្វេសប៊ុកក៏មិនបានធ្វើបច្ចុប្បន្នភាពដ៏គួរឱ្យកត់សម្គាល់ណាមួយអំពីបណ្តឹងដែរ ។*

*ពេលនេះ ភាព បានលុបចោលគណនីហ្វេសប៊ុករបស់នាង ។ ពេលខ្លះ នាងគិតចង់ធ្វើអត្តឃាត ។ នាងបាននិយាយថា "ខ្ញុំមានសង្ឃឹម ប៉ុន្តែអត់ដឹងថាខ្លួនឯងស៊ូបានអត់ ព្រោះពេលមានសម្ពាធខ្លាំងពេក... ខ្ញុំពេលខ្លះឮសំឡេងពួកវាតេមក ខ្ញុំចាប់ផ្តើមអស់ល្បើងពីខ្លួន ខ្ញុំអត់មានកម្លាំងអីទៀតទេ" ។ ភាព ចង់ឱ្យអាជ្ញាធរចាត់វិធានការឱ្យបានឆាប់រហ័សចំពោះករណីដូចនាង ដោយសារនាងភ័យខ្លាចថា មនុស្សច្រើនទៀតនឹងត្រូវដាក់គោលដៅដែរ ។ នាងលើកទឹកចិត្តអ្នកផ្សេងទៀត ដែលរងគ្រោះដោយស្ថានភាពស្រដៀងគ្នានេះ ឱ្យដើរឆ្ពោះទៅមុខ និងស្វែងរកការគាំទ្រ ។*


**របាយការណ៍របស់អ្នក**

សូមអរគុណសម្រាប់ការឲ្យយើងដឹងអំពីអ្វីមួយដែលអ្នកមិនចង់ឃើញនៅលើ Facebook។ អ្នកនឹងទទួលបានបច្ចុប្បន្នភាពនៅទីនេះនៅក្នុងប្រអប់សារចូលសម្រាប់ជំនួយគាំទ្ររបស់អ្នក ពេលការរាយការណ៍របស់អ្នកត្រូវបានពិនិត្យឡើងវិញ។

ប្រសិនបើអ្នកកំពុងត្រូវបានគេប្រើអំពើហិង្សាលើរាងកាយឲ្យចងចាំថាមានជំនួយ។ សូមចូលមើល **មជ្ឈមណ្ឌលការពារការអំពើហិង្សាលើរាង្គកាយ** របស់យើង ដើម្បីស្វែងយល់អំពីកម្មវិធីផ្សេងៗនៅលើ Facebook ដែលអាចជួយអ្នកបាន។

សូមមើលជម្រើស

*ការឆ្លើយតបរបស់ក្រុមហ៊ុនហ្វេសប៊ុកចំពោះការដាក់បណ្តឹង រយៈពេលជិត៣ខែបន្ទាប់ពីពេលដាក់បណ្តឹង ។*

## ការឆ្លើយតបដើម្បីដោះស្រាយបញ្ហាបៀតបៀនតាមប្រព័ន្ធអនឡាញគឺមិនគ្រប់គ្រាន់

ការរាយការណ៍ពីបទពិសោធន៍នៃការបៀតបៀនតាមប្រព័ន្ធអនឡាញទៅកាន់គេហទំព័រ ឬកម្មវិធីប្រព័ន្ធផ្សព្វផ្សាយសង្គម មិនមែនជាយុទ្ធសាស្ត្រដោះស្រាយចម្បងក្នុងចំណោមអ្នកចូលរួមស្ទង់មតិនោះទេ ។ ករណីនេះបង្ហាញថា យន្តការរាយការណ៍នៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម មិនត្រូវបានស្គាល់ទូលំទូលាយ ឬខ្វះទំនុកចិត្ត ឬប្រសិទ្ធភាព ។ ការចងក្រងហេតុការណ៍នៃការបៀតបៀនតាមប្រព័ន្ធអនឡាញ ដោយការថតចម្លងអ្វីដែលបានកើតមានឡើង ក៏មិនមែនជាការអនុវត្តទូទៅដែរ ទោះបីជាវិធីសាស្ត្រនេះអាចផ្តល់ភស្តុតាងសំខាន់ប្រឆាំងនឹងជនល្មើស នៅពេលដាក់ពាក្យបណ្តឹងទៅអាជ្ញាធរក៏ដោយ ។

ថ្វីត្បិតតែការប្លុក ឬឈប់ធ្វើជាមិត្តជាមួយជនល្មើស ដែលអាចទប់ស្កាត់បានខ្លះ ប៉ុន្តែអ្នកផ្តល់បទសម្ភាសន៍ជាច្រើនបានលើកឡើងថា មិនគ្រប់គ្រាន់ ។ ការប្លុក ឬឈប់ធ្វើជាមិត្តជាមួយនរណាម្នាក់ អាចធ្វើបានជាមួយជនល្មើសណាម្នាក់ ប៉ុន្តែវាមិនបានទប់ស្កាត់ប្រឆាំងនឹងការដាក់គោលដៅដោយអ្នកផ្សេងទៀតនៅពេលខាងមុខនោះទេ ។ ការប្លុក ឬឈប់ធ្វើជាមិត្តជាមួយនរណាម្នាក់ ក៏ត្រូវបានលើកឡើងថា គ្មានប្រសិទ្ធភាព ប្រសិនបើជនរងគ្រោះស្គាល់អ្នកបៀតបៀននោះក្រៅប្រព័ន្ធអនឡាញ ។ ជនល្មើស ក៏អាចបង្កើតគណនីថ្មីជាច្រើន ហើយជារឿយៗតែងដាក់គោលដៅមនុស្សតាមរយៈកម្មវិធីប្រព័ន្ធផ្សព្វផ្សាយសង្គមផ្សេងៗ មានន័យថាការប្លុកឬឈប់ធ្វើជាមិត្តអាចផ្តល់ការការពារតិចតួចប៉ុណ្ណោះ។

**លេខទី២២៖ ភាគរយនៃអ្នកចូលរួមស្ទង់មតិ ដែលធ្លាប់ត្រូវបានបៀតបៀនតាមប្រព័ន្ធអនឡាញតាមរយៈប្រតិកម្មរបស់ពួកគេទៅលើការបៀតបៀន**




*អនុញ្ញាតឱ្យមានចម្លើយច្រើន ការឆ្លើយសំណួរមិនមែនជាកាតព្វកិច្ចទេ*

បុរសម្នាក់ អាយុជាង ២០ឆ្នាំ បានសម្តែងការមិនពេញចិត្តជាមួយ កម្មវិធីផឹកចុក ដែលគ្រាន់តែផ្អាកសកម្មភាពគណនីដែលបំពាន គោលការណ៍របស់កម្មវិធី ។ លោកបាននិយាយថា "អ្នកមួយចំនួន គេបិទអាខោនគាត់ គាត់ទៅបើកអាខោនមួយទៀត ផុសអារឿងហ្នឹង អាដែល ជួនកាលផុសអារឿងហ្នឹងដដែលបង្កើតអាខោនទីបី ចឹងវា នៅតែមានរឿងហ្នឹងដដែល" ។

ស្ត្រីម្នាក់ទៀត អាយុ ២០ឆ្នាំជាងបន្តិច បានរាយការណ៍ថា ត្រូវបានតាមដានលើប្រព័ន្ធអនឡាញ និងគំរាមកំហែងដោយអតីតមិត្តស្រីរបស់មិត្តភក្តិនាង ។ ទោះបីជាបានប្លុកស្ត្រីនោះលើហ្វេសប៊ុក និងបង្កើតគណនីហ្វេសប៊ុកថ្មី ក៏ដូចជាប្តូរលេខទូរស័ព្ទទាំងពីរខ្សែក្តី អតីតមិត្តស្រីរបស់មិត្តភក្តិនាងនៅតែរកឃើញលេខថ្មី និងគណនីហ្វេសប៊ុកថ្មីរបស់នាង ព្រមទាំងបានហៅទូរស័ព្ទមកនាងឥតឈប់ឈរ ។ នាងបានរៀបរាប់ថា "នាងតែងតែcall មកលេខទូរស័ព្ទទាំងពីរប្រព័ន្ធរបស់ខ្ញុំរៀងរាល់ថ្ងៃ ដើម្បីរំខាននិងគំរាមខ្ញុំ" ។ នៅពេលដែលអតីតមិត្តស្រីរបស់មិត្តភក្តិនាងបង្ហោះសារគំរាមសម្លាប់ជាច្រើនដងនៅផ្នែកប្រវត្តិរូបក្នុងថេលេក្រាម នាងប្រាកដចិត្តថា សារទាំងនោះគឺសំដៅលើនាង ។ "ខ្ញុំរស់នៅក្នុងការគំរាមកំហែងរបស់នាងរហូតដល់ពេលបច្ចុប្បន្ន" ។

មនុស្សភាគច្រើនដែលធ្លាប់ត្រូវបានបៀតបៀនតាមប្រព័ន្ធអនឡាញ បានប្រាប់ទៅមិត្តភក្តិ សមាជិកគ្រួសារ ឬមនុស្សដែលជឿទុកចិត្តផ្សេងទៀត ប៉ុន្តែមួយភាគបួននៃពួកគេមិនបានប្រាប់ទៅនរណាម្នាក់ឡើយ ។ បុរសម្នាក់ អាយុជាង៣០ឆ្នាំ បានសួរថា "បើមានបញ្ហាកើតឡើងតាមសង្គមអនឡាញ Facebook ឬ Messenger មកលើFacebook របស់ខ្ញុំ តើត្រូវរាយការណ៍យ៉ាងដូចម្តេចដើម្បីរកយុត្តិធម៌បានយ៉ាងពិតប្រាកដ" ? ស្ត្រីអាយុជាង ៤០ឆ្នាំ អ្នកឆ្លើយតបក្នុងការស្ទង់មតិម្នាក់ទៀត បានសួរថា "បើមានអ្នករងគ្រោះ តើយើងត្រូវទាក់ទងទៅអ្នកណា" ? មនុស្សតិចតួចប៉ុណ្ណោះបានប្រាប់ទៅអាជ្ញាធរ អង្គការមិនមែនរដ្ឋាភិបាល ឬសាលារៀន សាកលវិទ្យាល័យ ឬអ្នកគ្រប់គ្រងរបស់ពួកគេ (សូមមើលតួលេខទី២៣) ។ យុវជនទំនងជាមិនសូវស្វែងរកជំនួយទេ ដោយ៣៩%នៃពួកគេមិនជឿទុកចិត្តនរណាម្នាក់សោះ ។

**តួលេខទី២៣៖ ភាគរយនៃអ្នកចូលរួមស្ទង់មតិដែលធ្លាប់ត្រូវបានបៀតបៀនតាមប្រព័ន្ធអនឡាញ ផ្អែកលើអ្នកដែលពួកគេបានរាយការណ៍ប្រាប់**









## “ខ្ញុំមានអារម្មណ៍ថាគេអត់ឱ្យតម្លៃខ្ញុំ”

ពេជ្រ[៤៤] អាយុ ២២ឆ្នាំ ជានិស្សិតនិងជាបុរសស្រឡាញ់ភេទដូចគ្នា ដែលជាញឹកញាប់ ត្រូវបានបៀតបៀនផ្លូវភេទតាមប្រព័ន្ធអនឡាញ ។ លោកបាននិយាយថា “ភាគច្រើនគឺគេឆាតមកយើង សុំមើលប្រដាប់ភេទ ។ វាធ្វើឱ្យអារម្មណ៍យើងមិនល្អ ដូចថាអារម្មណ៍យើងកំពុងសប្បាយចឹងស្រាប់តែមានគេឆាតមកអ៊ីចឹង យើងឃើញភ្លាម យើងលែងសប្បាយ” ។

មានពេលមួយ ជនប្លែកមុខម្នាក់ បានហៅទូរស័ព្ទមក ពេជ្រ តាមឆាត ដើម្បីស្នើសុំរូបភាពអាសអាភាស ។ លោកបាននិយាយថា “ពេលខ្ញុំទៅជប់លៀងជាមួយមិត្តហើយគាត់តេមក តេមែនទែន ទាល់តែយើងប្លុកចោលបានឈប់ ចឹងវារំខានដល់យើង” ។ ការប្លុកគឺមានប្រយោជន៍ ប៉ុន្តែពេជ្របាននិយាយថា “វាយុត្តិធម៌សម្រាប់ខ្ញុំនៅពេលដែលខ្ញុំបានប្លុកម្នាក់ហ្នឹងចោល ប៉ុន្តែនៅតែមានអ្នកផ្សេងទៀតដែលមិនមែនជាគាត់” ។ ពេជ្រ បានរំលឹកពីស្ថានភាពស្រដៀងគ្នាជាច្រើន ដែលលោកត្រូវបានបៀតបៀនដោយមនុស្សខុសៗគ្នា ។

ពេជ្រ គិតថាមិនមានវិធីសាស្ត្រច្រើន ដើម្បីបញ្ឈប់ការផ្ញើសារទាំងនេះទេ ជាពិសេសដោយសារការនិយមសន្មត់តគ្នាថា បុរសគឺតែងតែចាប់អារម្មណ៍ខ្លាំងជាមួយការរួមភេទ ។ លោកក៏បានចុះបញ្ជាំងថា វាជាការលំបាកសម្រាប់ក្រុមអ្នកស្រឡាញ់ភេទដូចគ្នា ដើម្បីស្វែងរក ឬផ្តល់ការគាំទ្រ ទៅអ្នកផ្សេងទៀត ប្រសិនបើពួកគេមិនស្វែងរកជំនួយពីសហគមន៍របស់ពួកគេទេ ។ លោកបាននិយាយថា “សូម្បីតែខ្ញុំជាអ្នក LGBT ក៏យើងអត់ហ៊ានបង្ហាញអ្នកគ្រប់គ្នាថាយើងជាមនុស្សចឹងដែរ ។ សូម្បីគ្រួសារក៏អត់ដឹង រឿងអីយើងប្រាប់គេរបៀបការពារយ៉ាងម៉េច អ៊ីចឹងវាពិបាក” ។

[៤៤] ត្រូវឈ្មោះត្រូវបានប្តូរ ដើម្បីធានាពីឯកជនភាព និងការការពារអ្នកចូលរួម ពីការធ្វើទុក្ខបុកម្នេញដែលអាចកើតមានឡើង ។

ជារឿយៗ អ្នកផ្តល់បទសម្ភាសន៍ តែងចែករំលែកថា ពួកគេជឿជាក់ថា សុវត្ថិភាពរបស់ពួកគេលើប្រព័ន្ធអនឡាញ គឺជាទំនួលខុសត្រូវរបស់ពួកគេខ្លួនឯង ។ មនុស្សជាច្រើនបានបង្ហាញការស្តីបន្ទោសខ្លួនឯង ដែលមិនបានប្រុងប្រយ័ត្នគ្រប់គ្រាន់ ដើម្បីការពារខ្លួនឯងពីការបៀតបៀនតាមប្រព័ន្ធអនឡាញ និងបានឆ្លុះបញ្ចាំងពីការកើនឡើងនៃសមត្ថភាពរបស់ពួកគេក្នុងការការពារខ្លួនលើប្រព័ន្ធអនឡាញ ។ មនុស្សជាច្រើន បាននិយាយពីការប្រើប្រាស់មុខងារផ្ទៀងផ្ទាត់ពីរជំហាន កូដសម្ងាត់រឹងមាំ និងការមិនចែករំលែកគណនី ឬព័ត៌មានឯកជនរបស់ពួកគេជាមួយអ្នកដទៃ ។ អ្នកខ្លះទៀត បានឆ្លុះបញ្ចាំងពីសារៈសំខាន់នៃវគ្គបណ្តុះបណ្តាលសម្រាប់អ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ ដើម្បីរៀនសូត្រពីរបៀបការពារខ្លួន និងណែនាំអ្នកដទៃកុំឱ្យប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម ប្រសិនបើពួកគេមិនយល់ច្បាស់ពីរបៀបប្រើប្រាស់វាដោយប្រុងប្រយ័ត្នទេ ។ ប៉ុន្តែដូចបង្ហាញក្នុងរឿងរ៉ាវជាច្រើនខាងលើ ជារឿយៗពុំមានទំហំនៃការប្រុងប្រយ័ត្នណាដែលអាចការពារប្រឆាំងគ្រប់ប្រភេទនៃការបៀតបៀនតាមប្រព័ន្ធអនឡាញទេ ដូច្នេះតម្រូវឱ្យមានយន្តការដោះស្រាយប្រសើរជាងនេះ ។

ភាគរយតិចតួចប៉ុណ្ណោះនៃអ្នកឆ្លើយតបដែលធ្លាប់ជួបការបៀតបៀនតាមប្រព័ន្ធអនឡាញ ហើយមានអារម្មណ៍ថា ពួកគេទទួលបានដំណោះស្រាយពេញលេញ និងយុត្តិធម៌ ខណៈដែលពួកគេភាគច្រើនមានអារម្មណ៍ថា ពួកគេទទួលបានដំណោះស្រាយតិចតួច ឬមិនបានដោះស្រាយសោះតែម្តង (សូមមើលតួលេខទី២៤) ។

**តួលេខទី២៤៖ ភាគរយនៃអ្នកចូលរួមស្ទង់មតិ ដែលធ្លាប់ជួបការបៀតបៀនតាមប្រព័ន្ធអនឡាញ ហើយមានអារម្មណ៍ថា បញ្ហារបស់ពួកគេត្រូវបានដោះស្រាយពេញលេញ និងយុត្តិធម៌**




**តួលេខទី២៥៖ ភាគរយនៃអ្នកចូលរួមស្ទង់មតិទាំងអស់ ដែលជឿជាក់ថា តួអង្គជាក់លាក់គួរចាត់វិធានការច្រើនជាងនេះ ដើម្បីបញ្ឈប់ការបៀតបៀនតាមប្រព័ន្ធអនឡាញ**



# ទំនួលខុសត្រូវរបស់ក្រុមហ៊ុនប្រព័ន្ធផ្សព្វផ្សាយសង្គម និងអាជ្ញាធរកម្ពុជា

ទាំងអាជ្ញាធរកម្ពុជា និងក្រុមហ៊ុនប្រព័ន្ធផ្សព្វផ្សាយសង្គម គួរដើរតួជាអ្នកដឹកនាំក្នុងការបញ្ឈប់ការបៀតបៀនតាមប្រព័ន្ធអនឡាញ ។ សកម្មភាពខ្លះនៃការបៀតបៀនតាមប្រព័ន្ធអនឡាញ ទោះបីជាមានគ្រោះថ្នាក់ខ្លាំង ក៏មិនគួរត្រូវបានផ្តន្ទាទោស ឬលុបចោលទាំងស្រុងដែរ ។ ប៉ុន្តែសកម្មភាពតូចៗខ្លះទៀតនៃការបៀតបៀន អាចរុញច្រានមនុស្សឱ្យឃ្លាតឆ្ងាញពីប្រព័ន្ធអនឡាញ និងអាចរឹតត្បិតសិទ្ធិរបស់ពួកគេ ។ យុទ្ធសាស្ត្របែបទូលំទូលាយ និងចម្រុះគ្នា គួរត្រូវបានធ្វើឡើងជាមួយគោលនយោបាយដ៏ល្អដោយប្រុងប្រយ័ត្នពាក់ព័ន្ធនឹងការលុបចោលមាតិកា និងវិធានការព្រហ្មទណ្ឌចំពោះករណីធ្ងន់ធ្ងរ ឬបន្តកើតមានឥតឈប់ឈរនៃការបៀតបៀនតាមប្រព័ន្ធអនឡាញ ជាមួយនឹងការការពារត្រឹមត្រូវជាធរមាន ។ សំខាន់ជាងនេះទៀត ទាំងការលុបចោលមាតិកាដោយក្រុមហ៊ុនប្រព័ន្ធផ្សព្វផ្សាយសង្គម និងវិធានការព្រហ្មទណ្ឌរបស់រដ្ឋ ត្រូវតែគោរពតាមគោលការណ៍ច្បាប់ ភាពស្របច្បាប់ ភាពចាំបាច់ និងភាពសមស្រប ។

## ក្រុមហ៊ុនប្រព័ន្ធផ្សព្វផ្សាយសង្គម

របាយការណ៍នេះ មិនពិចារណាលើគោលការណ៍ និងការអនុវត្តនៃក្រុមហ៊ុនប្រព័ន្ធផ្សព្វផ្សាយសង្គមទាំងអស់ទេ ប៉ុន្តែវានឹងផ្តល់ការយកចិត្តទុកដាក់លើក្រុមហ៊ុនរបស់ហ្វេសប៊ុក និងថេលេក្រាម ដោយសារកម្មវិធីទាំងនេះត្រូវបានប្រើប្រាស់ច្រើនជាងគេ និងជាកម្មវិធីចម្បងគេនៃការបៀតបៀនតាមប្រព័ន្ធអនឡាញនៅកម្ពុជា ផ្អែកតាមការរកឃើញរបស់យើង ។ ចំណុចខ្វះខាតជាច្រើន ដែលត្រូវបានពិភាក្សាខាងក្រោមនេះ គឺអាចអនុវត្តបានប្រហាក់ប្រហែលគ្នា សម្រាប់កម្មវិធីផ្សេងៗទៀតផងដែរ ។

បញ្ហាជាច្រើនដែលបានលើកឡើងនៅក្នុងរបាយការណ៍នេះ គឺត្រូវបានចងក្រងជាឯកសារ និងដឹងឮដោយក្រុមហ៊ុនប្រព័ន្ធផ្សព្វផ្សាយសង្គមរួចហើយ ។ កាលពីឆ្នាំ២០១៨ ហ្វេសប៊ុកបានបង្កើតគណៈកម្មការវាយតម្លៃផលប៉ះពាល់សិទ្ធិមនុស្សអំពីវត្តមានរបស់ក្រុមហ៊ុននេះនៅក្នុងប្រទេសកម្ពុជា ។ ក្រុមហ៊ុនហ្វេសប៊ុកមិនបានបញ្ចេញរបាយការណ៍ពេញលេញទេ ប៉ុន្តែបានទទួលស្គាល់ការរកឃើញដូចជា កម្រិតគួរឱ្យកត់សម្គាល់នៃការត្រួតពិនិត្យចាប់ពិរុទ្ធខ្លួនឯងនៅកម្ពុជា ការកើនឡើងនៃការចាប់ខ្លួនមនុស្សដោយសារការបង្ហោះមាតិកាលើហ្វេសប៊ុក ភាសាអសុរោះគួបផ្សំនឹងការចាក់ឫសនៃការរើសអើងជាតិសាសន៍ និងការបៀតបៀនលើស្ត្រីភេទ និងអសមភាពសម្រាប់ស្ត្រី ក្រុមអ្នកស្រឡាញ់ភេទដូចគ្នា និងក្រុមផ្សេងទៀតក្នុងចំណោមផលប៉ះពាល់ជាច្រើន ។អនុសាសន៍ជាច្រើនមិនត្រូវបានអនុវត្តហើយការអនុវត្តរបស់ក្រុមហ៊ុនហ្វេសប៊ុក គឺមិនមានតម្លាភាពនោះទេ ។

ជាពិសេស ហ្វេសប៊ុកមិនបានបង្ហាញពីអនុសាសន៍ចម្បងៗដែលត្រូវបានអនុវត្តដូចជា ការចេញផ្សាយរបាយការណ៍នៃការអនុវត្តស្តង់ដាសហគមន៍ដែលផ្តោតសំខាន់ជាក់លាក់លើប្រទេសកម្ពុជា ការបង្កើតមាតិកាសង្ខេបដែលអាចស្វែងរកបាននិងច្បាស់លាស់ ដើម្បីចែករំលែកនៅលើហ្វេសប៊ុក ដែលកំណត់ពីមូលដ្ឋាននៃរបៀបប្រើប្រាស់ហ្វេសប៊ុកដោយសុវត្ថិភាពសម្រាប់អ្នកប្រើប្រាស់ជាជនជាតិខ្មែរ ឬប្រកាន់ជំហរសាធារណៈលើក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិនៅកម្ពុជា ដែលទាក់ទងនឹងកម្មវិធីប្រព័ន្ធផ្សព្វផ្សាយសង្គម ។ ហ្វេសប៊ុក ក៏មិនធ្លាប់បានធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈស្តីពីការតាមដានពីសំណាក់អាជ្ញាធរកម្ពុជា និងសមត្ថភាពក្នុងការអនុវត្តច្បាប់ ដែលផ្តល់ព័ត៌មានច្បាស់លាស់អំពីបញ្ហារបស់អ្នកប្រើប្រាស់ ដូចដែលត្រូវបានណែនាំនៅក្នុង ការវាយតម្លៃផលប៉ះពាល់លើសិទ្ធិមនុស្ស។

លក្ខខណ្ឌប្រើប្រាស់ ស្តង់ដាសហគមន៍ ការកំណត់សុវត្ថិភាពនិងឯកជនភាព និងមុខងាររាយការណ៍ របស់ក្រុមហ៊ុនប្រព័ន្ធផ្សព្វផ្សាយសង្គម ជារឿយៗ គួរឱ្យភាន់ច្រឡំ មិនអាចស្វែងរកបាន គ្មានប្រសិទ្ធភាព និងខ្វះខាតទាំងការពិចារណាលើបរិបទ និងតម្លាភាព ។ មុខងារទាំងនេះ មិនងាយស្រួលក្នុងការស្វែងរក ប្រើប្រាស់ ឬឈ្វេងយល់ទេ និងមិនទាន់មានដំណើរការជាភាសាខ្មែរនៅឡើយ ។ ក្នុងឆ្នាំ២០២០ ក្រុមហ៊ុនហ្វេសប៊ុកបានរាយការណ៍ពីប្រាក់ចំណេញសុទ្ធចំនួន ២៩,១៥ ពាន់លានដុល្លារ នៅទូទាំងពិភពលោក ដែលកើនឡើងចំនួន ៥៨% បើធៀបនឹងឆ្នាំ២០១៩ ប៉ុន្តែក្រុមហ៊ុននេះមិនបានធ្វើឱ្យមុខងារសុវត្ថិភាព និងប្រតិបត្តិការមូលដ្ឋានរបស់ខ្លួន អាចប្រើប្រាស់ជាភាសារបស់អ្នកប្រើប្រាស់ទាំងអស់នោះទេ ។ ថ្វីត្បិតតែហ្វេសប៊ុកបានបកប្រែស្តង់ដារសហគមន៍របស់ខ្លួន និងភាគច្រើននៃការកំណត់សុវត្ថិភាពនិងឯកជនភាពទៅជាភាសាខ្មែរក្តី ហ្វេសប៊ុកមិនទាន់បានបកប្រែមុខងារបន្ទាប់បន្សំ ការណែនាំ និងរបាយការណ៍ប្រកបដោយតម្លាភាពទេ ។ កម្មវិធីថេលេក្រាម ការកំណត់សុវត្ថិភាពនិងឯកជនភាព ក៏ដូចជាការពន្យល់ពីការកំណត់ទាំងនោះ ក៏មិនទាន់មានជាភាសាខ្មែរដែរ ។ នេះអាចនាំឱ្យអ្នកប្រើប្រាស់ជាច្រើនមិនអាចគ្រប់គ្រងទៅលើគណនី ការកំណត់សុវត្ថិភាព និងឯកជនភាពរបស់ពួកគេ ។ ឧទាហរណ៍ អង្គការកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិថ្មីៗនេះបានចេញរបាយការណ៍ថា ចំនួនអ្នកប្រើប្រាស់គួរឱ្យកត់សម្គាល់នៅកម្ពុជា មានគណនីអនឡាញដូចជាអ៊ីម៉ែល បង្កើតឡើងដោយអ្នកដទៃដោយសារការភ័យខ្លាចនៃកំហុស ដំណើរការស្មុគស្មាញ និងកម្រិតចំណេះដឹងភាសាអង់គ្លេស ។ បញ្ហាប្រឈមនេះ គួរផ្សំគ្នា សម្រាប់មនុស្សដែលប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមច្រើន និងអ្នកដែលទាមទារឱ្យយល់ដឹង និងគ្រប់គ្រងមុខងារដែលផ្លាស់ប្តូរញឹកញាប់ជាមួយនឹងមធ្យោបាយផ្សេងៗគ្នាសម្រាប់សេវាកម្មជាច្រើនទាំងនោះ ។

ការរាយការណ៍ និងដំណើរការដាក់បណ្តឹង គឺមានភាពពិបាកស្រដៀងគ្នាក្នុងការប្រើប្រាស់ ។ ជារឿយៗការឆ្លើយតបមានភាពយឺតយ៉ាវ ហើយអ្នកប្រើប្រាស់ទទួលបានបច្ចុប្បន្នភាពតិចតួចប៉ុណ្ណោះអំពីដំណើរការរបស់ពួកគេ ។ កម្មវិធីខ្លះដូចជា ថេលេក្រាម អះអាងថា ក្រុមហ៊ុន

គ្មានទំនួលខុសត្រូវសម្រាប់មាតិកា ឬការបៀតបៀន ដែលបានចែករំលែកនៅក្នុងក្រុម ឬការផ្ញើសារទេ និងគ្រាន់តែផ្តល់មុខងារមួយចំនួនដូចជា ការប្លុក តែប៉ុណ្ណោះ ។

ចាំបាច់ត្រូវមានតម្លាភាពប្រសើរជាងនេះជាបន្ទាន់ ។ របាយការណ៍អនុវត្តស្តង់ដារសហគមន៍របស់ហ្វេសប៊ុក គឺមានលក្ខណៈជាសកល ។ វាមិនត្រូវបានបែងចែកតាមប្រទេស ឬកម្រិតភាសានោះទេ ដែលមិនបានផ្តល់ព័ត៌មានសំខាន់ៗអំពីស្ថានភាពនៅក្នុងប្រទេសកម្ពុជា ។ ក្រោយមកហ្វេសប៊ុកគ្រាន់តែរាយការណ៍ពីចំនួនមាតិកាដែលត្រូវបានចាត់វិធានការ ប៉ុន្តែមិនបានរាយការណ៍ពីទិន្នន័យទាំងអស់ទេ ។ ទោះបីជារបាយការណ៍របស់ហ្វេសប៊ុកទាក់ទងនឹងសំណើរបស់រដ្ឋាភិបាលក្នុងការស្នើសុំទិន្នន័យរបស់អ្នកប្រើប្រាស់ និងការរឹតត្បិតលើមាតិកាដោយផ្អែកលើច្បាប់ក្នុងតំបន់ត្រូវបានបែងចែកតាមប្រទេសក្តី ប៉ុន្តែរបាយការណ៍ទាំងនោះមិនបានផ្តល់ព័ត៌មានសំខាន់ៗអំពីប្រធានបទនៃការស្នើសុំ (ឧទាហរណ៍៖ ដូចជាពាក់ព័ន្ធនឹងកិច្ចការពារកុមារ សុខភាពសាធារណៈ អំពើញុះញង់ អំពើភេរវកម្ម ។ល។) ឬវិធានការជាក់លាក់ដោយក្រុមហ៊ុន (ដូចជាប្រភេទព័ត៌មានដែលត្រូវបានបង្ហាញ ការលុបចោលមាតិកា ការផ្អាកដំណើរការគណនី ជាដើម) ។

នៅខែតុលា និងខែវិច្ឆិកា ឆ្នាំ២០២១ អង្គការលីកាដូ បានផ្ញើសារទៅក្រុមហ៊ុនហ្វេសប៊ុក ដើម្បីចែករំលែកការរកឃើញសំខាន់ៗនៃរបាយការណ៍នេះ ព្រមទាំងស្នើសុំព័ត៌មាន និងតម្លាភាពបន្ថែមទៀត ។ ក្រុមហ៊ុនហ្វេសប៊ុក មិនបានឆ្លើយតបប្រកបដោយអត្ថន័យនោះទេ ។ អង្គការលីកាដូ បានស្នើសុំរបាយការណ៍ជាក់លាក់ស្តីពីកម្ពុជាពាក់ព័ន្ធនឹងការអនុវត្តស្តង់ដារសហគមន៍ថ្មីៗនេះរបស់ក្រុមហ៊ុនហ្វេសប៊ុក ក៏ដូចជាព័ត៌មានបន្ថែមអំពីការរឹតត្បិតមាតិកាថ្មីៗនេះរបស់ក្រុមហ៊ុនហ្វេសប៊ុកដោយផ្អែកលើច្បាប់កម្ពុជា ការអនុវត្តរបស់ក្រុមហ៊ុនហ្វេសប៊ុកឆ្លើយតបនឹងសំណើរបស់អាជ្ញាធរកម្ពុជាដើម្បីស្នើសុំទិន្នន័យរបស់អ្នកប្រើប្រាស់ ក៏ដូចជាកិច្ចព្រមព្រៀងទ្វេភាគីរវាងក្រុមហ៊ុន និងអាជ្ញាធរកម្ពុជា ក្នុងការចែករំលែកព័ត៌មាន ។ ហ្វេសប៊ុកមិនបានផ្តល់ព័ត៌មានដើម្បីឆ្លើយតបទៅនឹងសំណើទាំងនេះទេ ។ ហ្វេសប៊ុកក៏មិនបានបង្ហាញពីចំនួនអ្នកត្រួតពិនិត្យមើលមាតិកាជាជនជាតិខ្មែរ ដែលកំពុងបម្រើការឱ្យក្រុមហ៊ុន ហើយថាតើម៉ាស៊ីនបច្ចេកវិទ្យា និងសមត្ថភាពចាប់យកជាស្វ័យប្រវត្តិ ដែលស្វែងរកឬលុបចោល មាតិកាដែលមានលក្ខណៈគ្រោះថ្នាក់ អាចប្រើប្រាស់បានជាភាសាខ្មែរឬយ៉ាងណា ។ ហ្វេសប៊ុកមិនបានផ្តល់ព័ត៌មានថាតើ ឬរបៀបដែលក្រុមហ៊ុនដំណើរការត្រួតពិនិត្យមាតិកា មានការឆ្លើយតបទៅនឹងទំនៀមទំលាប់ប្រពៃណីជាក់លាក់សម្រាប់បរិបទកម្ពុជា ឬយ៉ាងណានោះទេ ។ ហ្វេសប៊ុកក៏មិនបានបញ្ជាក់ថាតើពេលណាទើបក្រុមហ៊ុនអាចបកប្រែពេញលេញជាភាសាខ្មែរនូវការកំណត់ឯកជនភាព សុវត្ថិភាព និងព័ត៌មានតម្លាភាពរបស់ខ្លួន ។ ចុងក្រោយ ហ្វេសប៊ុកមិនបានចែករំលែកពីរបៀបដែលអ្នកប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា ត្រូវបានបញ្ចូលនៅក្នុងប្រព័ន្ធពិនិត្យផ្ទៀងផ្ទាត់ បញ្ជីស ឬកម្មវិធីស្រដៀងគ្នានេះ ។

នៅឆ្នាំនេះ ហ្វេសប៊ុក បានចេញផ្សាយ គោលនយោបាយសិទ្ធិមនុស្សសាជីវកម្ម របស់ខ្លួនលើកដំបូង ។ ខណៈដែលគោលនយោបាយនេះផ្តល់ក្តីសង្ឃឹមថា ហ្វេសប៊ុកនឹងធ្វើឱ្យប្រសើរឡើងនូវការរួមបញ្ចូលបញ្ហាសិទ្ធិមនុស្សនៅក្នុងក្រុមហ៊ុនទាំងមូល គោលនយោបាយនេះទើបតែមានក្រោយពីហ្វេសប៊ុកបានរីកចម្រើនជាមួយប្រជាប្រិយភាពនៅទូទាំងពិភពលោក ។ យើងនៅមិនទាន់បានឃើញនៅឡើយទេថាតើ គោលនយោបាយនេះ នឹងត្រូវបានអនុវត្តដោយពេញលេញ និងត្រឹមត្រូវ ដើម្បីដោះស្រាយផលប៉ះពាល់លើសិទ្ធិមនុស្សនៅក្នុងតំបន់ ឬយ៉ាងណា និងថាតើហ្វេសប៊ុកនឹងដោះស្រាយឱ្យបានគ្រប់គ្រាន់នូវចំណុចខ្វះខាត និងបញ្ហាប្រឈមដែលកើតមានឡើង ដែរឬទេ ។ មកដល់បច្ចុប្បន្ននេះ កម្មវិធីប្រព័ន្ធផ្សព្វផ្សាយសង្គម កំពុងធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់អ្នកប្រើប្រាស់របស់ពួកគេ ព្រមទាំងអនុញ្ញាតឱ្យមានបរិយាកាសនៃការបៀតបៀនតាមប្រព័ន្ធអនឡាញបែបយូរអង្វែងនៅកម្ពុជាផងដែរ ។




*មុខងារមធ្យោបាយត្រួតពិនិត្យសុវត្ថិភាពរបស់ក្រុមហ៊ុនហ្វេសប៊ុក ដែលបកប្រែជាភាសាខ្មែរដោយផ្នែកតែប៉ុណ្ណោះ ។*

## អាជ្ញាធរកម្ពុជា

ដើម្បីដោះស្រាយបញ្ហានៃការបៀតបៀនតាមប្រព័ន្ធអនឡាញនៅក្នុងប្រទេសកម្ពុជា អាជ្ញាធរផ្ទាល់ គួរបញ្ឈប់ការធ្វើទុក្ខបុកម្នេញតាមប្រព័ន្ធអនឡាញ ។ ផ្ទុយទៅវិញ អាជ្ញាធរគួរនិរាករណ៍ច្បាប់ដែលមានន័យទូលំទូលាយ ស្រពេចស្រពិល និងហួសប្រមាណ និងបញ្ឈប់ការអនុវត្តច្បាប់ទាំងនោះតាមបែបជ្រើសរើស ដើម្បីដាក់ទោសមនុស្សដែលសម្តែងមតិរបស់ពួកគេនៅលើប្រព័ន្ធអនឡាញ ។

ក្នុងករណីបៀតបៀនតាមប្រព័ន្ធអនឡាញធ្ងន់ធ្ងរ អាជ្ញាធរគួរអនុវត្តច្បាប់ដែលមានស្រាប់ ដើម្បីយកជនល្មើសមកផ្តន្ទាទោស ។ ក្រមព្រហ្មទណ្ឌ និងច្បាប់ផ្សេងៗទៀត ហាមឃាត់រួចហើយនូវទម្រង់ខ្លះនៃអំពើបៀតបៀនតាមប្រព័ន្ធអនឡាញ ។ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ អាចត្រូវបានប្រើប្រាស់ស្រដៀងគ្នានេះ ដើម្បីដោះស្រាយករណីមួយចំនួន នៃការបៀតបៀនតាមប្រព័ន្ធអនឡាញដូចជា ការចែកចាយរូបភាពអាសអាភាស ឬរូបភាពអាសអាភាសនៃកុមារ ។បទប្បញ្ញត្តិទាំងនេះ អាចផ្តល់មធ្យោបាយដែលអាចធ្វើទៅបាន ដើម្បីផ្តល់យុត្តិធម៌នៅក្នុងករណីស្រាល ឬធ្ងន់ធ្ងរនៃការបៀតបៀនតាមប្រព័ន្ធអនឡាញ ។ សេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាក្នុងទម្រង់បច្ចុប្បន្ននេះ បង្កើតឱ្យមានការគំរាមកំហែងធ្ងន់ធ្ងរទៅលើឯកជនភាព និងសេរីភាពនៃការបញ្ចេញមតិតាមប្រព័ន្ធអនឡាញ ដែលមិនសូវផ្តល់ការការពារបន្ថែមប្រឆាំងនឹងការបៀតបៀនតាមប្រព័ន្ធអនឡាញទេ ដោយសារបទល្មើសជាច្រើននៅក្នុងច្បាប់នេះ ត្រូវបានចែងជាបទល្មើសនៅក្នុងច្បាប់ផ្សេងៗដែលមានស្រាប់រួចហើយ (ដូចជាការលួចចូលប្រើប្រាស់ដោយគ្មានការអនុញ្ញាត និងការកាន់កាប់រូបភាពអាសអាភាស ឬរូបភាពអាសអាភាសនៃកុមារ ជាដើម) ។

លើសពីនេះ នគរបាល ព្រះរាជអាជ្ញា ចៅក្រម មេធាវី និងគ្រូបង្រៀន គួរត្រូវបានទទួលឱកាសក្នុងការអភិវឌ្ឍខ្លួនពាក់ព័ន្ធនឹងអក្ខរកម្មឌីជីថល និងការយល់ដឹងអំពីការបៀតបៀនតាមប្រព័ន្ធអនឡាញ ផលប៉ះពាល់អវិជ្ជមាននៃអំពើបៀតបៀននោះ ការទប់ស្កាត់ ការឆ្លើយតប និងក្របខ័ណ្ឌផ្លូវច្បាប់ដែលអាចអនុវត្តបាន ។ កម្មវិធីសិក្សារបស់រដ្ឋនៅថ្នាក់វិទ្យាល័យស្តីពីបច្ចេកវិទ្យាទំនាក់ទំនងព័ត៌មាន និងអក្ខរកម្មឌីជីថល គួរត្រូវបានបន្ថែមដើម្បីដាក់បញ្ចូលការពិភាក្សាអំពីរបៀបប្រាស្រ័យទាក់ទងជាមួយមនុស្សតាមប្រព័ន្ធអនឡាញដោយការគោរព ក៏ដូចជារបៀបប្រើប្រាស់ការកំណត់សុវត្ថិភាព និងឯកជនភាពនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម ជាអតិបរមា។ ដើម្បីកាត់បន្ថយការបៀតបៀនតាមប្រព័ន្ធអនឡាញ វិធានការទាំងនេះគួរតែត្រូវបានផ្សារភ្ជាប់ជាមួយនឹងកម្មវិធីសិក្សាស្តីពីសិទ្ធិខាងផ្លូវភេទនិងការបន្តពូជ ដែលផ្តោតលើការសន្ទនាអំពីសមភាពយេនឌ័រ និងការព្រមព្រៀងគ្នា ។ រាល់ការបណ្តុះបណ្តាលនិងកម្មវិធីសិក្សាគួរតែត្រូវបានធ្វើបច្ចុប្បន្នភាពជាប្រចាំ ដើម្បីឆ្លើយតបទៅនឹងទិដ្ឋភាពបច្ចេកវិទ្យាដែលកំពុងផ្លាស់ប្តូរយ៉ាងឆាប់រហ័ស ។



# សេចក្តីសន្និដ្ឋាន

ប្រព័ន្ធផ្សព្វផ្សាយសង្គម មានសក្តានុពលធំធេង ដើម្បីជាលំហនៃភាពរីករាយ និងការលើកកម្ពស់សិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា ។ ទោះបីជាយ៉ាងណា អាជ្ញាធរកម្ពុជា កំពុងធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សក្តានុពលនេះ ហើយក្រុមហ៊ុនប្រព័ន្ធផ្សព្វផ្សាយសង្គមកំពុងខកខានក្នុងការចាត់វិធានការទាំងអស់ ដើម្បីធានាថាកម្មវិធីរបស់ពួកគេ គ្មានការរំខាន ពីការធ្វើទុក្ខបុកម្នេញ ការរំលោភបំពាននិងការរើសអើង ។ នេះតម្រូវឱ្យមានវិធានការចាំបាច់ច្រើនទៀត ដើម្បីធានាថា អ៊ីនធឺណិត និងប្រព័ន្ធផ្សព្វផ្សាយសង្គម គឺជាកន្លែងនៃការផ្សារភ្ជាប់ទំនាក់ទំនង ការចូលរួម និងការសម្តែងមតិដោយសេរីនៅក្នុងប្រទេសកម្ពុជា ។

ខណៈដែលជីវិតរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជា កាន់តែមានទំនាក់ទំនងនឹងគ្នា និងពឹងផ្អែកលើលំហអនឡាញ អត្រានៃការឈប់ប្រើប្រាស់ប្រព័ន្ធអនឡាញដោយសារការប្រឈមនឹងការបៀតបៀនតាមប្រព័ន្ធអនឡាញក៏មានខ្ពស់ណាស់ដែរ ។ ប្រព័ន្ធផ្សព្វផ្សាយសង្គមគឺជា ប្រភពចម្បងនៃព័ត៌មាន និងការពិភាក្សា នៅក្នុងប្រទេសកម្ពុជា ក្នុងពេលដែលមានការរឹតត្បិតខ្លាំងលើលំហសេរីភាពសារព័ត៌មាននៅក្នុងប្រទេស ។ ផលប៉ះពាល់នៃការបៀតបៀនតាមប្រព័ន្ធអនឡាញ មិនត្រឹមតែរឹតត្បិតនៅលើលំហអ៊ុនធឺណិតទេ ប៉ុន្តែមានផលប៉ះពាល់យ៉ាងខ្លាំងដល់ជីវភាពរស់នៅរបស់មនុស្សដែលត្រូវបានដាក់គោលដៅផងដែរ ។ របាយការណ៍នេះ គ្រាន់តែជាការចាប់ផ្តើម ដើម្បីបង្ហាញគ្រោះថ្នាក់ដែលប្រជាពលរដ្ឋកម្ពុជាជាច្រើនបានជួបប្រឈមនៅលើប្រព័ន្ធអនឡាញ ជាពិសេសសេវាកម្មដែលជាកម្មសិទ្ធិរបស់ក្រុមហ៊ុនហ្វេសប៊ុក និងប្រព័ន្ធផ្សព្វផ្សាយសង្គមផ្សេងទៀត ។ ការសិក្សា និងការសន្ទនាបន្ថែមទៀតស្តីពីការបៀតបៀនតាមប្រព័ន្ធអនឡាញ គឺមានភាពចាំបាច់ ។ ច្បាប់ គោលនយោបាយ ឥរិយាបថ អាកប្បកិរិយា ចាំបាច់ត្រូវមានការកែសម្រួល ដើម្បីឱ្យលំហអ៊ីនធឺណិតក្លាយជាកន្លែងដែលសិទ្ធិមនុស្សត្រូវបានការពារ និងរីករាយយ៉ាងពិតប្រាកដ ។



# អនុសាសន៍

## ក្រុមហ៊ុនប្រព័ន្ធផ្សព្វផ្សាយសង្គម

- បង្កើនការការពារលំនាំដើមជាអតិបរមា ។ អនុវត្តការកំណត់ឯកជនភាព និងសុវត្ថិភាពជាលំនាំដើមដែលផ្តល់ការការពារជាអតិបរមាប្រឆាំងនឹងការបៀតបៀនតាមប្រព័ន្ធអនឡាញ ។
- កំណត់ទីតាំងមុខងារសុវត្ថិភាព និងធ្វើឱ្យមុខងារទាំងនោះងាយស្រួលក្នុងការស្វែងរក និងប្រើប្រាស់ ។ ធ្វើឱ្យលក្ខខណ្ឌប្រើប្រាស់ ស្តង់ដារសហគមន៍ គោលនយោបាយ ការកំណត់ឯកជនភាពនិងសុវត្ថិភាព យន្តការនៃការរាយការណ៍ សម្ភារៈគាំទ្រ និងរបាយការណ៍ប្រកបដោយតម្លាភាពជាភាសាខ្មែរ និងងាយស្រួលរក ជាពិសេសតាមរយៈឧបករណ៍ចល័ត ។ សកម្មក្នុងការលើកកម្ពស់ការយល់ដឹងអំពីចំណេះដឹងទាំងនេះ ។ កំណត់មុខងារសុវត្ថិភាពដោយលើកកម្ពស់ការយល់ដឹងអំពីមុខងារទាំងនេះ ដោយមាតិកាដែលមានការចូលរួមសកម្មទៅវិញទៅមក រួមមានវីដេអូ ដែលជាទូទៅត្រូវបានចែកចាយជាញឹកញាប់នៅកន្លែងដែលអាចចូលប្រើប្រាស់បានដូចជានៅផ្នែក ទំព័រដើម និងការជូនដំណឹង ។
- ធ្វើឱ្យប្រសើរឡើងនៃមុខងាររាយការណ៍ ។ បង្កើតដំណើរការនៃការរាយការណ៍ និងបណ្តឹងជំទាស់ ដែលងាយស្រួលក្នុងការប្រើប្រាស់ និងដែលផ្តល់បច្ចុប្បន្នភាពទាប់ហ័ស និងលម្អិត ទៅកាន់ម្ចាស់បណ្តឹង និងម្ចាស់មាតិកាដែលត្រូវបានរាយការណ៍ ដោយបង្ហាញពីវិធានការរបស់ក្រុមហ៊ុន ។
- បង្កើនតម្លាភាព៖ ចេញផ្សាយរបាយការណ៍ប្រកបដោយតម្លាភាពស្តីពីប្រទេសកម្ពុជា ជាមួយព័ត៌មានលម្អិតអំពីចំនួនរាយការណ៍ពីអ្នកប្រើប្រាស់ សកម្មក្នុងការចាត់វិធានការលើមាតិកា សំណើរបស់រាជរដ្ឋាភិបាល ការរឹតត្បិតផ្អែកតាមច្បាប់កម្ពុជា ប្រភេទនៃរបាយការណ៍ សំណើ ការរឹតត្បិត ឬមាតិកា និងវិធានការដាក់លាក់របស់ក្រុមហ៊ុន ។
- ពង្រឹងភាពសកម្មក្នុងការចាប់យកមាតិកាដែលមានលក្ខណៈគ្រោះថ្នាក់ ។ ធានាថាការត្រួតពិនិត្យមាតិកា រួមមានកំហុសរបស់មនុស្ស និងម៉ាស៊ីនចាប់យក គឺមានប្រសិទ្ធភាពជាភាសាខ្មែរ និងឆ្លើយតបនឹងភាពខុសៗគ្នានៃវប្បធម៌ ។
- ប្រកាន់យកសិទ្ធិមនុស្ស ។ ដាក់បញ្ចូលគោលការណ៍សិទ្ធិមនុស្សដោយផ្ទាល់ ទៅក្នុងលក្ខខណ្ឌប្រើប្រាស់ និងស្តង់ដារសហគមន៍ ដើម្បីធានាថា សកម្មភាពពាក់ព័ន្ធនឹងមាតិកា ត្រូវបានណែនាំដោយស្តង់ដារដូចគ្នានៃផ្លូវច្បាប់ ភាពចាំបាច់ ភាពសមស្រប និងភាពស្របច្បាប់ដែលភ្ជាប់ជាមួយបទប្បញ្ញត្តិរបស់រដ្ឋស្តីពីការសម្តែងមតិ ។
- ផ្តល់អាទិភាពដល់អ្នកប្រើប្រាស់ ។ ចូលរួមជាមួយអ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម សកម្មជន និងសង្គមស៊ីវិល ដើម្បីអភិវឌ្ឍវិធានការទប់ស្កាត់ និងការឆ្លើយតបឱ្យបានប្រសើរឡើងចំពោះការបៀតបៀនតាមប្រព័ន្ធអនឡាញ ។

## អនុសាសន៍ចំពោះរាជរដ្ឋាភិបាលកម្ពុជា

- សូមបញ្ឈប់ការធ្វើទុក្ខបុកម្នេញ ។ សូមដោះលែងឱ្យបានឆាប់រហ័ស និងដោយគ្មានលក្ខខណ្ឌនូវសកម្មជនទាំងអស់ និងអ្នកផ្សេងទៀត ដែលត្រូវបានឃុំខ្លួនក្នុងពន្ធនាគារ ដោយសារការប្រើប្រាស់សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិរបស់ពួកគេតាមប្រព័ន្ធអនឡាញ ។ សូមបញ្ឈប់ការធ្វើទុក្ខបុកម្នេញលើស្ត្រីភេទ ដោយសារតែជម្រើសសម្លៀកបំពាក់ ឬការសម្តែងមតិរបស់ពួកគេលើប្រព័ន្ធអនឡាញ ។
- សូមបញ្ឈប់ការតាមដានដ៏លើសលប់ និងគ្មានតម្លាភាព ។ សូមនិរាករណ៍ ឬធ្វើវិសោធនកម្មច្បាប់ស្តីពីទូរគមនាគមន៍ ប្រកាសអន្តរក្រសួងលេខ ១៧០ និងអនុក្រឹត្យលេខ២៣ស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ ។ សូមលុបចោលសេចក្តីព្រាងច្បាប់ស្តីពី បទល្មើសបច្ចេកវិទ្យាព័ត៌មាន និងសេចក្តីព្រាងច្បាប់ស្តីពីសណ្តាប់ធ្នាប់សាធារណៈ ។
- សូមនិរាករណ៍ ឬធ្វើវិសោធនកម្មច្បាប់ដែលមានលក្ខណៈទូលំទូលាយ និងស្រពេចស្រពិល ។ សូមអនុវត្ត ក្រមព្រហ្មទណ្ឌឱ្យស្របតាមស្តង់ដាសិទ្ធិមនុស្សអន្តរជាតិ ជាពិសេសមាត្រាពាក់ព័ន្ធនឹងបទបរិហារកេរ្តិ៍និងបទជេរប្រមាថជាសាធារណៈ (មាត្រា៣០៥ ដល់មាត្រា៣០៨) បទប្រមាថចំពោះអង្គព្រះមហាក្សត្រ (មាត្រា ៤៣៧ស្ទួន) បទរួមគំនិតក្បត់ (មាត្រា៤៥៣) និងបទញុះញង់ (មាត្រា៤៩៤ និងមាត្រា៤៩៥) ។

- សូមពង្រឹងសមត្ថភាពដើម្បីបញ្ឈប់ការបៀតបៀនតាមប្រព័ន្ធអនឡាញ ។ សូមបណ្តុះបណ្តាលជាប្រចាំចំពោះអាជ្ញាធរមូលដ្ឋាន នគរបាល ព្រះរាជអាជ្ញា ចៅក្រម មេធាវី និងគ្រូបង្រៀន ស្តីពីអក្ខរកម្មប្រព័ន្ធឌីជីថល ការបៀតបៀនតាមប្រព័ន្ធអនឡាញ ការទប់ស្កាត់ ការឆ្លើយតប និងក្របខ័ណ្ឌច្បាប់ដែលមានស្រាប់ ។
- សូមបន្ថែមកម្មវិធីសិក្សារបស់រដ្ឋនៅថ្នាក់វិទ្យាល័យ ។ សូមបញ្ចូលការពិភាក្សាអំពីរបៀបប្រាស្រ័យទាក់ទងជាមួយមនុស្សតាមប្រព័ន្ធអនឡាញ និងរបៀបប្រើប្រាស់ការកំណត់សុវត្ថិភាព និងឯកជនភាពនៅក្នុងកម្មវិធីសិក្សាបច្ចេកវិទ្យាទំនាក់ទំនងព័ត៌មាន ។ សូមផ្តោតសំខាន់លើការពិភាក្សាអំពីការព្រមព្រៀងនៅក្នុងកម្មវិធីសិក្សាអំពីសុខភាពផ្លូវភេទនិងការបន្តពូជ ។
- សូមដឹកនាំឱ្យមានការផ្លាស់ប្តូរអាកប្បកិរិយា ។ សូមធ្វើយុទ្ធនាការលើកកម្ពស់ការយល់ដឹងពីការបៀតបៀនតាមប្រព័ន្ធអនឡាញតាមរយៈប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី និងសង្គម ៕

# ឧបសម្ព័ន្ធទី១៖ ការបែងចែកប្រភេទនៃការបៀតបៀនតាមប្រព័ន្ធអនឡាញ ដែលត្រូវបានរាយការណ៍ដោយអ្នកចូលរួមស្ទង់មតិ

| ប្រភេទនៃការបៀតបៀនតាមប្រព័ន្ធអនឡាញ | អ្នកឆ្លើយតបទាំងអស់(៧១៨នាក់) | | ស្ត្រី(៤៦៧នាក់) | | បុរស(២៣៨នាក់) | | យុវជនអាយុ ពី ១៨ ដល់ ២៤ឆ្នាំ(១៦៩នាក់) | | សកម្មជន(១៤២នាក់) | | អ្នកស្រឡាញ់ភេទដូចគ្នា(៦៤នាក់) | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចំនួនមនុស្ស | ភាគរយនៃក្រុម | ចំនួនមនុស្ស | ភាគរយនៃក្រុម | ចំនួនមនុស្ស | ភាគរយនៃក្រុម | ចំនួនមនុស្ស | ភាគរយនៃក្រុម | ចំនួនមនុស្ស | ភាគរយនៃក្រុម | ចំនួនមនុស្ស | ភាគរយនៃក្រុម |
| បានទទួលមាតិកាផ្លូវភេទដែលពុំបានស្នើសុំ | ១២២ | ១៧% | ៩៥ | ២០% | ២៧ | ១១% | ៣៥ | ២១% | ២០ | ១៤% | ១៨ | ២៨% |
| លួចចូលប្រើប្រាស់ ឬចូលប្រើប្រាស់ដោយគ្មានការអនុញ្ញាត | ៩០ | ១៣% | ៥៤ | ១២% | ៣៤ | ១៤% | ២៥ | ១៥% | ២៤ | ១៧% | ១០ | ១៦% |
| ការរើសអើង ឬភាសាបែបរើសអើង | ៦០ | ៨% | ៣២ | ៧% | ២៦ | ១១% | ២៤ | ១៤% | ២៤ | ១៧% | ១៥ | ២៣% |
| ការធ្វើឱ្យខ្មាសគេដោយចេតនា | ៥៣ | ៧% | ៣៥ | ៧% | ១៧ | ៧% | ២២ | ១៣% | ១៨ | ១៣% | ១០ | ១៦% |
| ការផ្សព្វផ្សាយពាក្យកុហកអំពីខ្ញុំ | ៤៦ | ៦% | ២៥ | ៥% | ១៩ | ៨% | ១៤ | ៨% | ១៥ | ១១% | ១០ | ១៦% |
| ការគំរាមកំហែង | ៣០ | ៤% | ១៤ | ៣% | ១៦ | ៧% | ៦ | ៤% | ១៤ | ១០% | ៤ | ៦% |
| ការបែកធ្លាយ | ៣០ | ៤% | ២១ | ៤% | ៩ | ៤% | ១២ | ៧% | ៦ | ៤% | ៤ | ៦% |
| ការក្លែងបន្លំអត្តសញ្ញាណ | ២៦ | ៤% | ១៥ | ៣% | ៩ | ៤% | ១០ | ៦% | ៥ | ៤% | ៨ | ១៣% |
| ប្រតិកម្មដោយអាជ្ញាធរ (ការកោះហៅទៅសាកសួរ ការបង្ខាប់ឱ្យលុបសារបង្ហោះ ឬឱ្យសុំទោស) | ១៤ | ២% | ៣ | <១% | ១១ | ៥% | ២ | ១% | ៨ | ៦% | ៣ | ៥% |
| ការគំរាមចែកចាយវីដេអូ ឬរូបភាពឯកជនដោយគ្មានការយល់ព្រម | ៩ | ១% | ៥ | ១% | ៤ | ២% | ២ | ១% | ៤ | ៣% | ២ | ៣% |
| ការចែកចាយវីដេអូ ឬរូបភាពឯកជនដោយគ្មានការយល់ព្រម | ៥ | <១% | ៤ | <១% | ១ | <១% | ២ | ១% | ២ | ១% | ១ | ២% |

មនុស្សម្នាក់អាចស្ថិតនៅក្នុងក្រុមច្រើន ។ អ្នកឆ្លើយតបអាចរាយការណ៍ពីការបៀតបៀនច្រើនប្រភេទតាមប្រព័ន្ធអនឡាញ ។ សំណួរមិនមែនជាកាតព្វកិច្ចទេ ។ អ្នកឆ្លើយតបខ្លះមិនបានបង្ហាញយេនឌ័ររបស់ពួកគេទេ ដូចនេះចំនួនបុរស និងស្ត្រី មិនអាចដាក់បញ្ចូលនៅក្នុងចំនួនអ្នកឆ្លើយតបសរុបទេ ។

"សូមអប់រំអ្នកបំពានឱ្យឈប់បំពាន" ។
ស្ត្រីម្នាក់ អាយុជាង ២០ឆ្នាំ

"គួរតែគ្មានការបៀតបៀន និងគំរាមកំហែងតាមបណ្តាញសង្គម" ។
ស្ត្រីម្នាក់ អាយុជាង ២០ឆ្នាំ

"មនុស្សគ្រប់រូបគួរមានសិទ្ធិស្មើគ្នាក្នុងការបញ្ចេញមតិក្នុងបណ្តាញសង្គម" ។
ស្ត្រីម្នាក់ អាយុជាង ២០ឆ្នាំ

"ខ្ញុំស្នើសុំទៅរដ្ឋាភិបាលឱ្យបើកទូលាយនូវអ៊ីនធឺណិតហ្នឹង និងការប្រើប្រាស់បណ្តាញសង្គមហ្នឹង កុំឱ្យធ្វើទុក្ខបុកម្នេញទៅដល់ប្រជាពលរដ្ឋដែលគាត់បង្ហោះព័ត៌មានពាក់ព័ន្ធទៅនឹងការរំលោភសិទ្ធិមនុស្សអី" ។
បុរសម្នាក់ អាយុជាង ៣០ឆ្នាំ

"ប្រសិនបើរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលដែលធ្វើការទៅលើការបៀតបៀនតាមរយៈឌីជីថល អាចផ្តល់វគ្គបណ្តុះបណ្តាលជាច្រើន ជាពិសេសសម្រាប់សិស្សវិទ្យាល័យ ហើយនិងនៅតាមជនបទ ពីព្រោះវាជាការល្អសម្រាប់ពួកគាត់រៀនអំពីប្រព័ន្ធសុវត្ថិភាពឌីជីថល និងការបៀតបៀនតាមអនឡាញ" ។
ស្ត្រីម្នាក់ អាយុជាង ៣០ឆ្នាំ

"សូមជួយពង្រឹងប្រព័ន្ធអនឡាញឱ្យមានសុវត្ថិភាពខ្ពស់" ។
បុរសម្នាក់ អាយុជាង ៣០ឆ្នាំ

"ខ្ញុំចង់ឱ្យខាងសមត្ថកិច្ច និងខាងអង្គការជួយដល់ពួកខ្ញុំផង ព្រោះពួកខ្ញុំបានរងនូវសម្ពាធនឹងការគំរាមកំហែងខ្លាំងណាស់" ។
ស្ត្រីម្នាក់ អាយុជាង ៣០ឆ្នាំ

"មន្ត្រីក្រសួងព័ត៌មាន ត្រូវផ្សព្វផ្សាយអប់រំពលរដ្ឋឱ្យយល់ដឹង ។ រីឯមន្ត្រីនៅក្រសួងកិច្ចការនារី ក៏មានកាតព្វកិច្ចទទួលខុសត្រូវផងដែរ" ។
បុរសម្នាក់ អាយុជាង ៣០ឆ្នាំ

"សូមចាត់វិធានការឱ្យមានប្រសិទ្ធភាពបំផុត" ។
ស្ត្រីម្នាក់ អាយុជាង ២០ឆ្នាំ

"យើងត្រូវបញ្ឈប់ការបៀតបៀនតាមប្រព័ន្ធអនឡាញ" ។
បុរសម្នាក់ អាយុជាង ២០ឆ្នាំ

www.licadho-cambodia.org